ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលឯកសារ ឈ្មោះ ភូសែម

◆ តើថ្ងៃ២០ ឧសភា ២០១៨ ជាសំណងជាលើកដំបូងរបស់រាជរដ្ឋាភិបាលកម្ពុជាជូនដល់ជនរងគ្រោះនៃរបបខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២២១ ខែឧសភា ឆ្នាំ២០១៨

# ស្វែងរកការពិត

លេខ២២១ ខែឧសភា ឆ្នាំ២០១៨


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រ៖ ២០ ឧសភា ជាថ្ងៃប្រវត្តិសាស្រ្ត ........................................ ៣

### ផ្នែកឯកសារ

◆ ការតស៊ូគ្មានតម្លៃ ......................................................................៤

### ផ្នែកប្រវត្តិសាស្រ្ត និងការស្រាវជ្រាវ

◆ ឯកសាររបស់អតីតឧត្តមសេនីយ៍ ឡោះ កូសែម....................................៨

◆ ការប្រារព្ធទិវាចងកំហឹង ២០ ឧសភា ..............................................៩

◆ អត្ថន័យនៃទិវាចងចាំចំពោះឪពុកខ្ញុំ ............................................. ១២

◆ ២០ ឧសភា អតីតកាលមិនត្រូវបានបំភ្លេច....................................... ១៣

◆ នាង សាលីម ៖ ជីវិតជាប់គុកខ្មែរក្រហម ខ្ញុំចាំមិនភ្លេចទេ..................... ១៤

◆ កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្រ្តី"រ៉ក់» ......................................... ១៨

◆ សារសំខាន់នៃការសិក្សាប្រវត្តិសាស្រ្តកម្ពុជា ................................ ២០

◆ ដោគវាសនានិស្សិតកម្ពុជាដែលបានទៅសិក្សា................................ ២២

### ផ្នែកច្បាប់

◆ សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល .......................................២៥

### វេទិកាពិភាក្សាសាធារណៈ

◆ តើថ្ងៃ២០ ឧសភា ២០១៨ ជាសំណាងលើកដំបូង.............................៣៧

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ ព្រលឹងមាសម្តាយ.....................................................................៤០

◆ រឿងគុកក្នុងគុក ......................................................................៤៩

◆ បញ្ជីឈ្មោះសៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ ...................... ៥៨



កងកុមារកំពុងសែងដី


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ៖** ដារ៉ាវឌ្ឍ មេត្តា, ហូ ថុនា, សោម ប៊ុនថន, ផេង ពង្សរ៉ាស៊ី, អ៊ុន សុដាវី, អ៊ិន វណ្ណារ៉ា, កូលីន គ្រាសគុន, វ៉ាន់ថាន់ ពៅដារ៉ា, អ៊ុង វណ្ណា និង ទុយ វណ្ណារ័ត្ន **អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដារ៉ាវឌ្ឍ មេត្តា, អ៊ុន សុដាវី និង ហូ ថុនា **អ្នកបកប្រែ៖** អ៊ិន វណ្ណារ៉ា **និពន្ធនាយកទូទៅ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ៖** គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វេង



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ២០ ឧសភា ជាថ្ងៃប្រវត្តិសាស្ត្រ

រៀងរាល់ថ្ងៃទី២០ ខែឧសភា ប្រជាជនកម្ពុជាទាំងមូល រួមទាំងអ្នកដែលបានឆ្លងកាត់ និងរស់រានមានជីវិតពីរបបខ្មែរក្រហម តែងតែនឹកឃើញទៅដល់ទិវាចងកំហឹង ដែលរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានប្រារព្ធរៀបចំឡើងដំបូងនៅឆ្នាំ១៩៨៤ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានបណ្តេញចេញពីក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ការប្រារព្ធទិវាចងកំហឹង ត្រូវបានរៀបចំធ្វើនៅតាមបូជនីយដ្ឋាន ដែលជាអតីតទីតាំងសម្លាប់រណ្តៅសាកសព និងអតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហមក្នុងគោលបំណងរំឭកទៅដល់ទុក្ខវេទនា ការឈឺចាប់ ការកាប់សម្លាប់ និងជាការប្រមូលផ្តុំនូវសំឡេងមួយ ដើម្បីលាតត្រដាងពីអំពើឃោរឃៅរបស់ខ្មែរក្រហម ដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាស្លូតត្រង់ បង្ហាញទៅសហគមន៍អន្តរជាតិ។

ដោយសាររបត់នយោបាយនៅប្រទេសកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ទិវាចងកំហឹង ត្រូវបានប្តូរមកជាទិវានៃការចងចាំ ដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់ភាគី ចូលក្នុងដំណើរការផ្សះផ្សា និងសន្តិភាពនៅក្នុងប្រទេស។ ទិវានៃការចងចាំនេះ ត្រូវបានរាជរដ្ឋាភិបាលប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ហើយនៅឆ្នាំ២០១៨នេះ រាជរដ្ឋាភិបាលក៏បានប្រកាសកំណត់យកថ្ងៃ២០ ខែឧសភា ជាថ្ងៃរំឭកទៅដល់ជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្មនៅក្នុងរបបខ្មែរក្រហម និងជាថ្ងៃឈប់សម្រាកជាផ្លូវការ។ ជាមួយគ្នានេះ សាលាក្តីខ្មែរក្រហមក៏បានកំណត់យកថ្ងៃ២០ ខែឧសភា ជាថ្ងៃសំណង ផ្នែករដ្ឋប្បវេណីដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ដែលរាជរដ្ឋាភិបាលបានធ្វើរួចមកហើយ។

ទោះបីមានការផ្លាស់ប្តូរពី ទិវាចងកំហឹង ២០ ឧសភា មកជាទិវានៃការចងចាំ និងការយកថ្ងៃ២០ ខែឧសភា ជាសំណងផ្នែករដ្ឋប្បវេណីរបស់សាលាក្តីខ្មែរក្រហម ក៏ដោយ ក៏ថ្ងៃនេះនៅតែជាថ្ងៃប្រវត្តិសាស្ត្រ ដែលប្រជាជនកម្ពុជាទូទៅធ្លាប់បានដឹងឮអស់រយៈពេល៣៨ឆ្នាំមកហើយ។

**សោម ប៊ុនថន**



តុលាការប្រជាជនបដិវត្តន៍ ឆ្នាំ១៩៧៩

# ការតស៊ូគ្មានតម្លៃ

វ៉ែន សុន ជាកូនកាត់លាវនិងទំពួនមានស្រុកកំណើតនៅភូមិកោះម៉ាយើល ឃុំពាមជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ឪពុកឈ្មោះ វ៉ែន ជាជនជាតិលាវ និងម្តាយឈ្មោះ ម៉ាញ់ ជន ជាតិទំពួននិងមានបងប្អូនបង្កើត៥នាក់ (ស្រី២នាក់ ប្រុស៣នាក់)។ សុន មានប្រពន្ធ២នាក់។ ប្រពន្ធទី១ ឈ្មោះ ផាយ ស៊ីន ជនជាតិលាវ (ស្លាប់ឆ្នាំ២០១០) និងមានកូន៧នាក់ (ស្រី៣នាក់ និងប្រុស៤នាក់)។ ប្រពន្ធទី២ ឈ្មោះ ថន ថា ជនជាតិខ្មែរ។ សព្វថ្ងៃ សុន និងប្រពន្ធទី២ រស់នៅក្នុងភូមិទំនប់លើ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

**ចន្លោះពីចុងឆ្នាំ១៩៦០-១៩៧៥**

កាលពីសង្គមចាស់ សុន រៀនបានត្រឹមថ្នាក់ទី៨ នៅសាលាក្នុងឃុំជីមៀត។ នៅពេលខ្មែរក្រហមចូលមកដល់មណ្ឌលគិរី ឆ្នាំ ១៩៦៧-៦៨ សុន ក៏បានឈប់រៀន និងចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅមន្ទីរភ្នំក្រោល។ នៅមន្ទីរភ្នំក្រោលកាលនោះមានទាំងខ្មែរ និងជនជាតិភាគតិច ប្រហែល ២០០-៣០០នាក់ ដែលមានឈ្មោះ ឡាំង ជនជាតិលាវ ជាអ្នកដឹកនាំ។ នៅខែមិនា ឆ្នាំ១៩៧០ក៏កើតមានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ចេញពីតំណែងដោយសេនាប្រមុខ លន់ នល់។ ក្នុងឆ្នាំ១៩៧០នេះដែរ ខេត្តមណ្ឌលគិរី និងខេត្តផ្សេងៗនៅភូមិភាគឦសានបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ នៅខណៈពេលនោះក្រុមគ្រួសារ សុន និងអ្នកភូមិកោះម៉ាយើល បានរត់ចូលព្រៃគេចចេញពីការទម្លាក់គ្រាប់បែករបស់កងទ័ពអាមេរិក។ កងទ័ពអាមេរិកយល់ថាភូមិរបស់ សុន មានកងទ័ពវៀតកុងស្នាក់នៅ។ នៅពេលដែលអ្នកភូមិរស់នៅលាក់ខ្លួនក្នុងព្រៃ ក៏មានកងទ័ពវៀតកុងរស់នៅលាយឡំជាមួយអ្នកភូមិដែរ។ ការលាក់ខ្លួននៅក្នុងព្រៃនោះបានបណ្តាលឲ្យអ្នកភូមិមានជំងឺ និងស្លាប់អស់ជាច្រើននាក់។ មានគ្រួសារខ្លះ ស្លាប់គ្មានសល់សូម្បីតែម្នាក់។ សុន បន្តថា ការណ៍ដែលវៀតកុងចូលមកកម្ពុជា គឺមកក្នុងគោលបំណងសហការជាមួយខ្មែរក្រហមធ្វើការឃោសនាឲ្យប្រជាពលរដ្ឋតស៊ូ ហើយត្រូវធ្វើបដិវត្តន៍ប្រឆាំងនឹងសហរដ្ឋអាមេរិក និងរដ្ឋាភិបាល លន់ នល់។ សុន និងអ្នកភូមិបានលាក់ខ្លួននៅក្នុងព្រៃអស់រយៈពេលជាង៣ឆ្នាំ ទើបវិលត្រឡប់មកភូមិវិញ នៅពេលដែលកងទ័ពអាមេរិកឈប់ទម្លាក់គ្រាប់បែកនៅឆ្នាំ១៩៧៣។

នៅឆ្នាំ១៩៧៣ សុន ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចូលធ្វើកងទ័ពខ្មែរក្រហមក្នុងតំបន់១០៥។ ក្រោយមក សុន ត្រូវបានអង្គការបញ្ជូនឲ្យទៅរៀនវគ្គកាំភ្លើងធំនៅសាលាគ-៩២ របស់មជ្ឈិមនៅក្បែរភូមិក្រយាដងក្តារ ស្ថិតក្នុងខេត្តកំពង់ធំ ព្រមទាំងមានអ្នកបង្ហាត់បង្រៀនឈ្មោះ សុន សេន និង សោ ភឹម ដែលការរៀនសូត្រនេះមានរយៈពេល៣ខែ។ សុន រៀបរាប់ថា អ្នកដែលចូលរួមរៀនវគ្គកាំភ្លើងធំនេះ មានសុទ្ធតែយោធាមកពីគ្រប់តំបន់នៃប្រទេសកម្ពុជា ហើយកាលណោះគឺរៀនផ្នែកយុទ្ធសាស្ត្រយោធា និងនយោបាយ។ មួយរយៈក្រោយមកអង្គការខ្មែរក្រហមបានចាត់តាំង សុន និងកងទ័ព



វ៉ែន សុន

ខ្មែរក្រហមផ្សេងទៀត ឲ្យសហការណ៍ជាមួយវៀតកុងចូលរួមប្រយុទ្ធទប់ទល់នឹងទាហាន លន់ នល់ នៅ សមរភូមិចេនឡាទី២ ស្ថិតនៅតាមផ្លូវជាតិលេខ៦ចន្លោះ ពីស្រុកបារាយណ៍មកទីរួមខេត្តកំពង់ធំ។ នេះជាការសាកល្បងចំណេះដឹងកងទ័ពបញ្ចប់វគ្គហ្វឹកហាត់។ បន្ទាប់ពីបញ្ចប់វគ្គហ្វឹកហាត់បាញ់កាំភ្លើងធំមក សុន ត្រូវបញ្ជូនត្រឡប់មកតំបន់១០៥ (មណ្ឌលគិរី) វិញ។ បន្ទាប់មក សុន ត្រូវជ្រើសតាំងឲ្យធ្វើជាប្រធានមន្ទីរស្រុកកែវសីមា ដែលមានឈ្មោះ កាស៊ី ជាលេខាស្រុក។ ក្នុងឆ្នាំ១៩៧៤ សុន បានស្នើអង្គការដើម្បីរៀបការជាមួយសមនារីឈ្មោះ ដាយ ស៊ួន នៅមន្ទីរស្រុកកែវសីមា។

**ចន្លោះឆ្នាំ១៩៧៥-១៩៧៩**

បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សុន មាននាទីជាប្រធានមន្ទីរស្រុកកែវសីមា ដដែល និងបានបញ្ជាក់ថាស្រុកកែវសីមាក៏ដូចជា ស្រុក តំបន់ផ្សេងៗនៅទូទាំងប្រទេសដែរ បន្ទាប់ពីរំដោះបានភ្លាមៗ ខ្មែរក្រហមក៏បានជម្លៀសប្រជាជនថ្មីមួយ ចំនួនឲ្យមករស់នៅក្នុងស្រុកកែវសីមាដែល។ ប្រជាជនត្រូវបានចាត់តាំងឲ្យធ្វើស្រែ លើកទំនប់ ជីកប្រឡាយដូចប្រជាជនដ៏ទៃទៀតនៅតំបន់ខាងក្រោម ក៏ប៉ុន្តែត្រូវបានអនុញ្ញាតឲ្យហូបចុកគ្រប់គ្រាន់ គឺហូបបាយសុទ្ធមិនមែនហូបបបរ ឬបាយលាយពោតដំឡូងទេ។ សុន បានបន្ថែមថានៅស្រុកកែវសីមា មិនមានគុក ឬមន្ទីរសន្តិសុខឡើយ បើសិនជាមានការចាប់ចងគឺត្រូវបញ្ជូនទៅមន្ទីរសន្តិសុខភ្នំក្រោលដែលជាមន្ទីរសន្តិសុខរបស់តំបន់១០៥។ កាលណោះមន្ទីរ តំបន់១០៥ ស្ថិតនៅភ្នំក្រោល ក្នុងស្រុកកោះញែក។ នៅពេលមានការប្រជុំម្តងៗ សុន តែងតែធ្វើដំណើរទៅទីនោះដោយជិះដំរី ហើយប្រើរយៈពេល២យប់ទើបទៅដល់មន្ទីរតំបន់។

សុន មិនដែលធ្លាប់បានឃើញ ឬក៏ដឹងថាមានការសម្លាប់មនុស្សនៅស្រុកកែវសីមា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩ ឡើយ។ ប៉ុន្តែក្នុងឆ្នាំ១៩៧៨ថ្នាក់លើនៅទីក្រុងភ្នំពេញបានមកស្នើសុំប្រជាជនជនជាតិភាគតិចពីស្រុកកែវសីមា ចំនួន៣០ គ្រួសារយកទៅធ្វើជាកម្មកររោងចក្រនៅភ្នំពេញ ហើយ សុន បានជ្រើសរើសជនជាតិភាគតិចចំនួន៣០គ្រួសារ ប្រគល់ឲ្យថ្នាក់លើតាមការស្នើសុំ។ គ្រួសារទាំងនោះភាគច្រើន ជាជនជាតិភាគតិចក្រោល និងព្នង ដែលមានចិត្តស្លូតបូតស្មោះត្រង់នឹងបដិវត្តន៍។ មួយរយៈក្រោយមក សុន បានឮដំណឹងថា គ្រួសារដែលថ្នាក់លើបានស្នើសុំយកទៅធ្វើកម្មករនៅភ្នំពេញ ត្រូវបានយកទៅសម្លាប់ចោលនៅម៉ុំចម្ការកៅស៊ូក្នុងស្នឹងត្រង់ ខេត្តកំពង់ចាម ដោយពុំដឹងពីមូលហេតុអ្វី។ ប៉ុន្តែមានគ្រួសារជនជាតិពីរគ្រួសារ បានរួចគេចផុតពីការសម្លាប់ (គ្រួសារទី១ មានឈ្មោះ គឹម ញ៉ាន សព្វថ្ងៃជាអនុប្រធានភូមិ១០៥(ថ្នល់កែង) និងគ្រួសារទី២ មិនចាំឈ្មោះ រស់នៅ ភូមិ១០៥ (ថ្នល់កែង) ដែរ។

តំបន់មណ្ឌលគិរី (១០៥) មានឈ្មោះ តាហម ហៅ តាឡាំង លេខាតំបន់ និងឈ្មោះ តាខាំភួន អនុលេខា។ តំបន់១០៥ មានស្រុកចំនួន៥ គឺស្រុកកែវសីមា ដែលមានឈ្មោះ កាស៊ី លេខា, ស្រុកច្បារមានឈ្មោះ តាចាំ លេខា, ស្រុកពេជ្រាដាមានឈ្មោះ តាសារុន លេខា, ស្រុកអូរាំងមានឈ្មោះ តាយឿន លេខា និងស្រុកកោះញែកមានឈ្មោះ តាស្វាយ លេខា។ ប្រធានយោធាតំបន់១០៥ ឈ្មោះ វៀង និងប្រធានមន្ទីរសន្តិសុខតំបន់១០៥ ឈ្មោះ សុភា។

នៅឆ្នាំ១៩៧៨ តំបន់១០៥ មានការច្របូកច្របល់ខ្លាំង ដោយលេខាស្រុកកែវសីមា ឈ្មោះ កាស៊ី ត្រូវបានចាប់ខ្លួន និងដាក់ ជំនួសដោយឈ្មោះ អនស៊ី ដែលត្រូវជាប្អូនតាឡាំង, តាស្វាយ លេខាស្រុកកោះញែក បានចងកសម្លាប់ខ្លួនបន្ទាប់ពីបាញ់សម្លាប់កម្មាភិបាលស្រុកអូរាំងចំនួន២នាក់ គឺឈ្មោះ ដាំង និង គី។ តាចាំ លេខាស្រុកច្បារក៏ត្រូវបានចាប់ខ្លួន។ ចំណែក តាឡាំង និងតាខាំភួន ដែលជាលេខា និងអនុលេខា តំបន់១០៥ ត្រូវបានរាយការណ៍ថាឈ្លោះ និងសម្លាប់គ្នានៅខណៈពេលដែលមេដឹកនាំខ្មែរក្រហម កោះហៅមកប្រជុំនៅទីក្រុងភ្នំពេញ។ នៅចុងឆ្នាំ១៩៧៨ តាសារុន, តាអនស៊ី និង វៀង ត្រូវបានតម្លើងជាលេខា, អនុលេខា និង សមាជិកតំបន់១០៥។

*ក្រោយខ្មែរក្រហមដួលរលំ និងការរស់នៅលើភ្នំដងរែក (ភ្នំ១០០១)*

*នៅឆ្នាំ១៩៧៩របបខ្មែរក្រហមត្រូវបានផ្តួលរំលំដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាសហការជាមួយកងទ័ព វៀតណាម។ ពេលនោះ សុន បានរត់គេចខ្លួន ចូលព្រៃក្នុងខេត្តមណ្ឌលគិរី ដោយរស់នៅទីនោះអស់រយៈពេលជិត៤ឆ្នាំ។ រហូតដល់ឆ្នាំ១៩៨៣ នៅពេលកងទ័ពវៀតណាម បានវាយប្រហារយោធាខ្មែរក្រហម ដែលរស់នៅក្នុងព្រៃកាន់តែខ្លាំងឡើងៗ ពេលនោះ សុន និងបក្ខពួក បានរត់គេចខ្លួនដោយជិះកាណូត ឆ្លងទៅខាងលិចទន្លេមេគង្គឆ្ពោះទៅព្រៃឡង់។ ពេលដល់ត្រើយម្ខាង សុន និងបក្ខពួកបានបន្តមករស់នៅលើភ្នំដងរែក ម៉ុំម៉ុបី (ភ្នំ១០០១)។ ភ្នំ១០០១ មានកងពលខ្មែរក្រហមចំនួន៤ គឺកងពល៨០១, កងពល៤១៧, កងពល៩២០ និងកងពល១០៥ ដែលមាន សុន សេន ជាអ្នកគ្រប់គ្រង។ ចំណែក សុន ដោយសារមានប្រពន្ធនិងកូនតូចៗ២ទៅ៣នាក់ផងនោះ ក៏បានឈប់ពីកងទ័ពមករស់នៅជាប្រជាជនធម្មតានៅក្នុងជំរំស្ទឹងច័ន្ទ (ប្រទេសថៃ)។ ជំរំនេះក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅភ្នំ១០០១ដែរ។ តាអាន អ្នកគ្រប់គ្រងប្រជាជនទាំងអស់នៅជំរំស្ទឹងច័ន្ទ។ សុន និងប្រជាជន រស់នៅក្នុងជំរំស្ទឹងច័ន្ទ អស់រយៈពេលមួយឆ្នាំ។ ក្រោយមកដោយភាគីថៃលែងឲ្យរស់នៅទីនោះ សុន និងប្រជាជនផ្សេងទៀត ក៏បានផ្លាស់មករស់នៅអូរជន្លៀស នៅក្បែរជំរំស្ទឹងច័ន្ទ ដែលរំលងតែភ្នំមួយប៉ុណ្ណោះ។*

**ការរកកើតភូមិ១០៥ និងភូមិទំនប់លើ**

*នៅឆ្នាំ១៩៩០-៩១ សុន និងប្រជាជនផ្សេងទៀត បានចុះមក រស់នៅតំបន់អន្លង់វែងវិញ ពីព្រោះតំបន់អន្លង់វែងត្រូវបានកងទ័ពខ្មែរក្រហមដណ្តើមកាន់កាប់ទាំងស្រុង។ តាម៉ុក បានឈូសផ្លូវ ចុះពីច្រកជាំស្រងាំចុះមកអន្លង់វែង។ ដំបូង សុន ចុះមករស់នៅទីតាំងកងទ័ព និងប្រជាជនដែលមកពីតំបន់មណ្ឌលគិរី (កងពល១០៥) សព្វថ្ងៃភូមិ១០៥ ភូមិថ្មល់កែង។ នៅពេលនោះមេដឹក នាំកងពល១០៥មាន តាអនស៊ី, តាសារុន, វៀង និងតាឃឿន បានសម្រេចបង្កើតជាភូមិដោយបានដាក់ឈ្មោះថា ភូមិ១០៥ តែម្តង។ បន្ទាប់មក កងទ័ពរដ្ឋាភិបាលភ្នំពេញបានវាយចូលដល់ភូមិ១០៥ សុន និងអ្នកភូមិក៏បាននាំគ្នារត់គេចខ្លួនទៅលើភ្នំដងរែក។ រហូតដល់ឆ្នាំ១៩៩៣ សុន និងអ្នកភូមិបានវិលត្រឡប់មករស់នៅក្នុងភូមិ១០៥វិញ ដើម្បីប្រកបរបររធ្វើស្រែចម្ការ។ នៅក្នុងភូមិ១០៥មានចំនួនប្រជាជនរស់នៅច្រើនដូច្នេះ តាអនស៊ី ដែលជាមេដឹកនាំកងពល១០៥, សុន និងប្រជាជនមួយចំនួនទៀតបានសម្រេចចិត្តផ្លាស់ទៅរស់នៅកន្លែងថ្មី។ ក្រោយមក តាអនស៊ី បានដាក់ឈ្មោះកន្លែងដែលទៅរស់ថ្មីនោះថាជាភូមិទំនប់លើ។*

*បន្ទាប់ពីបោះឆ្នោតជ្រើសរើសសភាតំណាងរាស្ត្រអាណត្តិទី១នៅឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជាហៅកាត់ ថា «អ៊ុន តាក់» សុន ក៏ត្រូវបានជ្រើសរើសឲ្យធ្វើជាមេភូមិទំនប់លើ។*

*នៅចុងឆ្នាំ១៩៩៨ ខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាលកម្ពុជាហើយ ភូមិទំនប់លើត្រូវស្ថិតក្នុងឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សុន មានអារម្មណ៍ត្រេកអរសប្បាយរីករាយក្នុងចិត្តជាខ្លាំងដោយគាត់យល់ឃើញថាសង្គ្រាមរវាងខ្មែរ និងខ្មែរត្រូវបានបញ្ចប់។ ប្រទេសកម្ពុជានឹងមានការបង្រួបបង្រួមជាតិឡើងវិញ ហើយប្រជាជនមានសិទ្ធិសេរីភាព អាចដើរហើរបានគ្រប់ទីកន្លែង និងប្រកបរបររកស៊ីតាមចិត្តចង់។ ជាពិសេសក្មេងៗជំនាន់ក្រោយដូចជាកូនៗរបស់គាត់នឹងមានឱកាសបានចូលសាលារៀន ដើម្បីក្រេបជញ្ជក់ចំណេះដឹងហើយរួមគ្នាការពារ និងកសាងប្រទេសជាតិឲ្យបានសម្បូរសប្បាយ ជុំថ្កើនរុងរឿង ជៀសឲ្យផុតពីគ្រោះវេទនាទាំងឡាយ ដែលប្រជាជនកម្ពុជាធ្លាប់បានឆ្លងកាត់ និងគ្រោះមហន្តរាយដែលបង្កឡើងដោយរបបខ្មែរក្រហម ក្រោមការដឹកនាំដ៏មហាលោភឆ្អោះមហាអស្ចារ្យរបស់ ប៉ុល ពត អៀង សារី និង ខៀវ សំផន។*

***ហូ ថុនា***

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៨ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្ដី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្ដី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្ដុះបណ្ដាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ១មួយច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប១ច្បាប់ (Resume) ។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល truthbunthorn.s@dccam.org ។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ ០២៣ ២១៤ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

**សូមអរគុណ!**

# ឯកសាររបស់អតីតឧត្តមសេនីយ៍ ឡេះ កូសែម ច្រើនសន្លឹកសន្ធាប់ត្រូវបានប្រគល់មកមជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលឯកសារប្រវត្តិសាស្ត្រជាច្រើនសន្លឹកសន្ធាប់ ពីអ្នកស្រី ណាទីយ៉ា ដែលជាឯកសាររបស់ ឡេះ កូសែម (អតីតឧត្តមសេនីយ៍ក្នុងរបបសាធារណរដ្ឋខ្មែរ)។ ឯកសារទាំងនោះរួមមានជា ប្រភេទក្រដាស ហ្វីល ទស្សនាវដ្តី រូបថត សំបុត្រ ផែនទី និងសៀវភៅមានសរសេរជាភាសាចម្រុះដូចជា ភាសាបារាំង អង់គ្លេស ចាម វៀតណាម និងភាសាខ្មែរ។ ឯកសារភាគច្រើនគឺជាឯកសារទំនាក់ទំនងថ្នាក់ដឹកនាំដែលមួយចំនួនផ្តោតសំខាន់ទៅការងាររបស់ ឡេះ កូសែម។ នៅក្នុងចំណោមឯកសារទាំងនេះក៏មានសំបុត្រឆ្លើយឆ្លងពីលោក ឡេះ កូសែម និងជនជាតិចាមនៅក្រៅប្រទេស (ប្រទេសម៉ាឡេស៊ី និងអារ៉ាប់) និងឯកសារទាក់ទងក្រុមចលនាហ្វូលរ៉ូ (FULRO) ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៦៤ ដឹកនាំដោយជនជាតិភាគតិចនៅតំបន់ខ្ពង់រាបដើម្បីទប់ទល់នឹងរដ្ឋាភិបាលវៀតណាមពីឆ្នាំ ១៩៦៤ដល់ឆ្នាំ ១៩៧៥ និងរដ្ឋាភិបាលកុម្មុយនីស្តវៀតណាម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៩២។

ឯកសាររបស់អតីតឧត្តមសេនីយ៍ ឡេះ កូសែមត្រូវបានអ្នកស្រី ណាទីយា ជាប្រពន្ធថែរក្សា ទុកអស់រយៈ ជាង៤០ឆ្នាំ បន្ទាប់ពីប្តីរបស់អ្នកស្រីបានស្លាប់នៅប្រទេសម៉ាឡេស៊ី ហើយ ឯកសារទាំងនេះ ក៏មិនដែលបានផ្សព្វផ្សាយទៅដល់សាធារណជនដែរ។ ដោយសារបារម្ភខ្លាចពីការបាត់បង់ឯកសារទាំងនេះ អ្នកស្រីបានពិចារណាអស់រយៈពេលប្រហែល៦ឆ្នាំ មុននឹងផ្តល់ឯកសារទាំងនេះដល់មជ្ឈមណ្ឌលឯកសារកម្ពុជាថែរក្សា។


អ្នកស្រី ណាទីយ៉ា និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌឯកសារកម្ពុជា

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានមានប្រសាសន៍ថា «ឯកសារទាំងនេះ គឺជាឯកសារប្រវត្តិសាស្ត្រដ៏មានតម្លៃ ដែលបានឆ្លុះបញ្ចាំងពីបំណែកប្រវត្តិសាស្ត្រមួយនៅកម្ពុជា ដែលហាក់ដូចជាត្រូវបានបំភ្លេច»។ លោក ឆាំង យុ បន្ថែមថា «គាត់ពិតជាសប្បាយរីករាយខ្លាំងណាស់ដែលមានឱកាសទទួលបានឯកសារទាំងនេះយកមកចងក្រងរក្សាទុកជាប្រវត្តិសាស្ត្រដើម្បីជាផ្នែកមួយជួយដល់អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិសិក្សាស្វែង យល់។

លោក ឆាំង យុ ក៏បានថ្លែងអំណរគុណដល់អ្នកស្រី ណាទីយា ដែលបានផ្តល់ឯកសារដ៏មានសារសំខាន់របស់ឧត្តមសេនីយ៍ ឡេះ កូសែម ដែលចុះកាលបរិច្ឆេទចាប់តាំងពីទសវត្សរ៍៥០ ដល់ ៧០ នៃរបបសាធារណរដ្ឋខ្មែរ។

**អ៊ុន សុដារី និង ហូ ចុនា**

# ការប្រារព្ធទិវាចងកំហឹង ២០ ឧសភា លើកដំបូងនៅឆ្នាំ១៩៨៤ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩

ក្រោយរបបខ្មែរក្រហមបានដួលរលំ ថ្ងៃទី៧ ខែមករា ឆ្នាំ ១៩៧៩ ប្រជាជនកម្ពុជាស្ថិតនៅក្នុងស្ថានភាពគួរឲ្យសង្វេគ។ ប្រជាជនបានបាត់បង់សាច់ញាតិ ហើយអ្នកខ្លះទៀតមិនដឹងថា គ្រួសាររបស់ខ្លួនបាត់បង់ជីវិតឬយ៉ាងណាទេ។ ក្នុងរយៈ-ពេលពាឆ្នាំ ៨ខែ ២០ថ្ងៃ ប្រជាជនកម្ពុជាបានបាត់បង់ជីវិតចំនួនប្រមាណជា ២លាននាក់ ហើយបានបន្សល់ទុកជនពិការបាក់កម្លាំង ១៩១.៨៤៨នាក់, កុមារកំព្រា ២០០.០០០នាក់ និងស្ត្រីមេម៉ាយរាប់សែននាក់។ ចំណែកហេដ្ឋារចនាសម្ព័ន្ធ សាលារៀនចំនួន៥.៨៥៧ មន្ទីរពេទ្យចំនួន៧៩៦ វត្តអារាម ១.៩៦៨ ក៏ត្រូវបានបំផ្លាញ (យោងតាមស្ថិតិរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា, ញត្តិ១៩៨៣)។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅជាង ៤ឆ្នាំ នៅថ្ងៃទី១៥-១៨ ខែសីហា ឆ្នាំ១៩៨៣ ក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី១ រដ្ឋសភានៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានអនុម័តយកថ្ងៃ ២០ ឧសភា ជារៀងរាល់ឆ្នាំជា «ទិវាចងកំហឹង» ចំពោះរបបប្រល័យពូជសាសន៍ប៉ុលពត, អៀងសារី,



តុលាការប្រជាជនបដិវត្តន៍ ឆ្នាំ១៩៧៩

ខៀវ សំផន ពីព្រោះនៅក្នុងថ្ងៃទី២០ ឧសភា ឆ្នាំ១៩៧៣ របបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្ដើមបង្កើតសហករណ៍ នៅតាមតំបន់ដែលខ្លួនបានគ្រប់គ្រងទូទាំងប្រទេស ហើយក៏ជាថ្ងៃដែលខ្មែរក្រហមបង្ខំប្រជាជនឲ្យរស់នៅជាសមូហភាព ដោយធ្វើការផាររួម ហូបរួម ធ្វើទារុណកម្ម និងសម្លាប់ៗ ក្នុងនោះដែរក៏មានញត្តិរបស់ជនរងគ្រោះទូទាំងប្រទេស គាំទ្ររបបរដ្ឋាភិបាលសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ដែលកំណត់យកថ្ងៃ២០ ខែឧសភា ជារៀងរាល់ឆ្នាំជាទិវាចងកំហឹង ក្នុងគោលបំណងឲ្យសកលលោកបានដឹង និងចង់ឲ្យអង្គការសហប្រជាជាតិដកកៅអីរបស់ ប៉ុល ពត ពីអង្គការសហប្រជាជាតិ ហើយប្រគល់មកប្រជាជនកម្ពុជាវិញ ក្រោមការដឹកនាំរបស់លោកប្រធាន ហេង សំរិន ដៀសវាងអសន្តិសុខពិភពលោក និងកសាងបូជនីយដ្ឋាន គោរពដល់ជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងរបបដ៏ខ្មៅងងឹតនេះ។ បន្ទាប់ពីមានការអនុម័តច្បាប់ពីសភាក្នុងឆ្នាំ១៩៨៣ រដ្ឋាភិបាលរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានចេញសារាចរលេខ ០៩.ស.រ.ណ.ន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៤ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីឲ្យមានការប្រារព្ធទិវាចងកំហឹង ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៨៤ ដែលជាទិវាចងកំហឹងលើកទី១ នៅទូទាំងប្រទេសចាប់ពីភូមិ, ឃុំ, ស្រុក, ខណ្ឌ រហូតដល់ថ្នាក់ខេត្ត រាជធានី។ ក្នុងការប្រារព្ធពិធីចងកំហឹងរាល់សកម្មភាពសប្បាយទាំងឡាយបានផ្អាកពេញមួយថ្ងៃដើម្បីសម្ដែងការកាន់ទុក្ខចំពោះជនរងគ្រោះ។ រាល់ការចាត់តាំងមីទ្ទីងតាមបណ្ដាខេត្តក្រុង បានរៀបចំនៅកន្លែងដែលរបបខ្មែរក្រហម


តុលាការប្រជាជនបដិវត្តន៍ ឆ្នាំ១៩៧៩

*ធ្លាប់បានបន្តវិនាសកម្ម ដូចជា នៅតាមវត្តអារាមមន្ទីរពេទ្យ សាលារៀនជាដើម។*

*ក្នុងការប្រារព្ធពិធីនៃការចងកំហឹងលើកដំបូងក្នុងឆ្នាំ១៩៨៤ក្នុងឱកាសនោះរដ្ឋាភិបាលបានចាត់តាំងដូចតទៅ៖*

*នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៨៤ រដ្ឋាភិបាលបានចាត់តាំងកម្មាភិបាលបុគ្គលិក ចំនួន២០នាក់ឲ្យចូលរួមគោរពវិញ្ញាណក្ខ័ន្ធ ដាក់កម្រងផ្កានៅវិមានជ័យជម្នះ និងវិមានសពយុទ្ធជនវៀតណាម។*

*នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៨៤ រដ្ឋាភិបាលបានចាត់តាំងកម្មាភិបាល បុគ្គលិកចំនួន២នាក់ ជាសម្ព័ន្ធយុវជន ទៅចូលរួមមីទ្ទីងចងកំហឹងឈឺចាប់ និងថ្កោលទោសបនប្រល័យពូជសាសន៍ ប៉ុល ពត នៅកន្លែងរណ្តៅសាកសពរួមនៅបឹងជើងឯក។*

*នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៨៤ រដ្ឋាភិបាលបានចាត់តាំងកម្មាភិបាល បុគ្គលិក ចំនួន២០នាក់ ទៅចូលរួមមីទ្ទីងចងកំហឹង ឈឺចាប់បនប្រល័យពូជសាសន៍ នៅមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។*

*នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៨៤ នាពេលព្រឹក កម្មាភិបាល បុគ្គលិក កម្មករ នៅក្នុងទីស្តីការគណៈ សង្គមកិច្ចបេក្ខជន សម្ព័ន្ធយុវជន អង្គការមហាជន ជនជាតិ បញ្ញវន្តសរុបទាំងអស់មានគ្នាប្រមាណ ១៣២នាក់បានប្រារព្ធធ្វើមីទ្ទីងរំឭកថ្ងៃអនុស្សាវរីយ៍ ទិវាចងកំហឹងឈឺចាប់អំពីបនប្រល័យពូជសាសន៍ ប៉ុល ពត «២០ ឧសភា» ក្រោមអធិបតីភាពរបស់លោក សា ប៊ុន ប្រធានគណៈសង្គមកិច្ច។ ក្នុងឱកាសនោះ លោក សា ប៊ុន បានធ្វើការចាប់អារម្មណ៍ ចំពោះរដ្ឋសភាជាតិដែលបានអនុម័តថ្ងៃ២០ ឧសភា សម្រាប់ធ្វើការចងកំហឹងឈឺចាប់ខ្លោចផ្សា ថ្កោលទោសអំពីឧក្រិដ្ឋកម្មឃោរឃៅ ព្រៃផ្សៃយង់ឃ្នងក្នុងរយៈកាល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ក្រោមរបបប្រល័យពូជសាសន៍ ប៉ុល ពត។ បន្ទាប់មកនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៨៤ លោក សា ប៊ុន បានរំឭកពីអតីតកាលឈឺចាប់ខ្លោចផ្សាពោរពេញដោយឈាម និងទឹកភ្នែក បានអង្រួនបេះដូង, សតិសម្បជញ្ញៈប្រជាជនគ្រប់រូបឲ្យខ្លោចផ្សាក្រៃលែង។ លោកបានបន្តទៀតថា ប្រជាជនទទួលរងភាពលំបាកវេទនា ហូបចុកមិនគ្រប់គ្រាន់ ធ្វើការប្រមូលផ្តុំគ្នានៅការដ្ឋាន ជីកទំនប់ ប្រឡាយ ព្រែក ធ្វើស្រែ គ្មានស្គាល់ថ្ងៃយប់ គ្មានពេលសម្រាក។ ពេលដែលអង្គការចង់ហៅប្រជាជនយកទៅសម្លាប់គ្រាន់តែប្រើពាក្យថា យកទៅរៀនសូត្រ ទៅបោចវល្លិ៍ ទៅជីកអង្កុរ ផ្លាស់ប្តូរភូមិស្រុកប៉ុណ្ណោះ ប៉ុន្តែសុទ្ធតែជាល្បិចបោកប្រាស់របស់អង្គការ។ ប្រជាជនដែលជាអ្នកទោសជាប់ចំណង ត្រូវបានខ្មែរក្រហមធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ទាត់ធាក់ ចងព្យួរជើងឡើងលើហើយក្បាលជ្រមុជទឹកពាង ដុតដែកក្តៅរួចហើយយកអុជលើខ្លួនប្រាណ យកដង្កាប់ចាប់ដកក្រចក រួចហើយជ្រលក់អាល់កុល រុំស្បោងកៅស៊ូធ្វើឲ្យថប់ដង្ហើម ចងឆ្កាងពន្លះសាច់ពុះទ្រូង កាត់យកថ្លើម ចំណែកនារីត្រូវខ្មែរក្រហមចាប់រំលោភ ហើយត្រូវសម្លាប់ដោយបុកនឹងចំពុះទុង អាទម្ពុះដោះ វាយសំពងនឹងដំបងកាំបិត ពូថៅ ត្បូងចប ជាដើម។ «ប្រជាជន ទាំងអស់គ្នារស់ក្នុងគុកឥតជញ្ជាំង រស់ដូចសត្វតិរច្ឆានរស់បានមួយយប់នៅព្រួយមួយថ្ងៃរស់ដោយក្តីភ័យខ្លាច រស់ដោយគ្មានសង្ឃឹមថានឹងរស់បន្តទៀត»។ បន្ទាប់មក មានការឡើងចាប់អារម្មណ៍សម្តែងការឈឺចាប់ ពីគ្រប់តំណាងអង្គភាពបញ្ញាជនកុមារកំព្រា។ ពេលនោះលោកទែនរាំ បានឡើងថ្លែងពីទុក្ខទារុណកម្មដែលខ្មែរក្រហមបានប្រព្រឹត្តមកលើរូបលោកដែលគ្មានកំហុស។ ក្រោយមកអង្គមីទ្ទីងនេះត្រូវបានបញ្ចប់ទៅនៅម៉ោង១១ ដោយដក់ជាប់នូវកំហឹងចំពោះបនប្រល័យពូជសាសន៍ ប៉ុល ពត។*

*រដ្ឋាភិបាល បានប្តេជ្ញាប្រយុទ្ធការពារមិនអនុញ្ញាតឲ្យបនប្រល័យពូជសាសន៍វិលត្រឡប់មកវិញជាលើកទី២បានឡើយ។ ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈ គ្រប់ជនជាតិ ព្រះសង្ឃ បញ្ញវន្ត ពិសេសកម្លាំងនគរបាលទាំងមូលភ្ញាក់រឭកក្នុងក្រអៅបេះដូងចំពោះឧក្រិដ្ឋកម្មរបប ប៉ុល ពត, អៀង សារី, ខៀវ សំផន ដែលបានធ្វើឲ្យប្រទេសជាតិវិនាសអន្តរាយ។*

***ដារ៉ារដ្ឋ មេត្តា***

# អត្ថន័យនៃទិវាចងចាំចំពោះឪពុកខ្ញុំ

ចំពោះឪពុកខ្ញុំ ទិវាចងចាំ គឺជាថ្ងៃដ៏សំខាន់មួយជួយរំឭកពីអនុស្សាវរីយ៍ដ៏ជូរចត់ស្ទើរតែធ្វើឲ្យគាត់បាត់បង់ជីវិត។ ចំណែកប្រជាជនខ្មែរ អាចចូលរួមរំលែកទុក្ខដល់គ្រួសារ បាត់បង់សាច់ញាតិក្នុងរបបខ្មែរក្រហម។ មិនត្រឹមតែប៉ុណ្ណោះវាក៏ជាថ្ងៃមួយអាចបង្រៀនឲ្យមនុស្សគ្រប់រូបចេះ អត់ខិនអធ្យាស្រ័យ និង សិក្សាកុំឲ្យរបបនេះវិលត្រឡប់មកវិញ។

នៅថ្ងៃទី២០ ឧសភា ឆ្នាំ២០១៨ នេះ គឺជាការចូលរួមលើកទីបីរបស់ឪពុកខ្ញុំដើម្បីប្រារព្ធទិវាចងចាំនៅក្នុងបរិវេណ «មន្ទីរតាមន្ត» ដែលជាកន្លែងសម្លាប់មនុស្សយ៉ាងរង្គាលនៅក្នុងរបបខ្មែរក្រហម។ ទីតាំងនេះត្រូវបានអាជ្ញាធរ និងប្រជាពលរដ្ឋ រៀបចំកសាងចេតិយដើម្បីដាក់ឆ្អឹងជនរងគ្រោះ និងសង់សាលាសំណាក់តូច មួយសម្រាប់ព្រះសង្ឃគង់ និងប្រជាជនមកប្រារព្ធពិធីសាសនាផ្សេងៗដើម្បីឧទ្ទិសដល់អ្នកដែលបានស្លាប់ទៅក្នុងរបបខ្មែរក្រហម។ មន្ទីរតាមន្តមានទីតាំងស្ថិតនៅក្នុងភូមិឫស្សីដុំ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ដែលមានរយៈចម្ងាយប្រហែល១០០គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ។ ឪពុកខ្ញុំរៀបរាប់ថា នៅក្នុងកម្មវិធីប្រារព្ធ ទិវាចងចាំនេះ មានការចូលរួមពីប្រជាពលរដ្ឋ គ្រូបង្រៀន មន្ត្រីរាជការ និងព្រះសង្ឃ ដោយមានមតិស្វាគមន៍ពីមន្ត្រី គណៈបក្សស្រុកមតិចូលរួមពីតំណាងឲ្យយុវជន ការប្រគេន ចង្ហាន់ដល់ព្រះសង្ឃ និងពិធីបង្សុកូល តាមព្រះពុទ្ធសាសនា ដើម្បីឧទ្ទិសកុសលជូនដល់ជនរងគ្រោះដែលខ្មែរក្រហម បានសម្លាប់នៅក្នុងមន្ទីរតាមន្តនេះ។

ឪពុកខ្ញុំបានរំឭកថា នៅក្នុងឆ្នាំ១៩៩៣ គាត់បានចូលរួមប្រារព្ធទិវាចងកំហឹងនៅ«មន្ទីរតាមន្ត»ជាលើកដំបូង ដែលក្នុងពេលនោះគាត់គឺជាគ្រូបង្រៀនម្នាក់នៅវិទ្យាល័យសម្តេចជាស៊ីមអង្គរជ័យ។ ឪពុកខ្ញុំរៀបរាប់ថា មានមនុស្សយ៉ាងច្រើនបានចូលរួមពិធីនេះ ដែលភាគច្រើនគឺជាសាច់ញាតិជនរងគ្រោះ មន្ត្រីរាជការ និងព្រះសង្ឃ។ នៅក្នុងឆ្នាំ១៩៩៧ គាត់បានចូលរួមប្រារព្ធទិវាចងកំហឹងជាលើកទីពីរ ដែលពេលនោះទិវាចងកំហឹង ត្រូវបានផ្លាស់ឈ្មោះមកជា «ទិវាចងចាំ»វិញ ហើយការប្រារព្ធពិធីនេះមិនមានលក្ខណៈខុសប្លែកគ្នាប៉ុន្មានទេពីឆ្នាំមុនៗដែលមានការចូលរួមពីមន្ត្រីរាជការ ប្រជាជន សិស្សានុសិស្ស និងព្រះសង្ឃ។

ឪពុកខ្ញុំក៏បានរំឭករឿងរ៉ាវរបស់គាត់ថាក្នុងវ័យ១៥ឆ្នាំ ខ្មែរក្រហមបានចាត់តាំងគាត់ឲ្យធ្វើការក្នុងកងយុវជន ដែលមានទីតាំងក្នុងស្រុកអង្គរជ័យ ខេត្តកំពត។ ដំបូងឡើយ កម្មាភិបាលខ្មែរក្រហមបានចាត់តាំងឲ្យគាត់ឃ្វាលគោលើកទំនប់ ជីកប្រឡាយ កាប់ឆ្ការព្រៃ និងធ្វើការចល័តពីមួយកន្លែងទៅមួយកន្លែង។ ទោះបីជាការងារហត់នឿយយ៉ាងណាតែរបបអាហារ ដែលគាត់ទទួលបានគឺមិនគ្រប់គ្រាន់ឡើយ។ ទោះបីរបបខ្មែរក្រហមបានកន្លងផុតទៅ តែឪពុករបស់ខ្ញុំនៅតែចងចាំរឿងរ៉ាវ ដែលបានកើតឡើងចំពោះគាត់នៅក្នុងសម័យខ្មែរក្រហម។

ឪពុកខ្ញុំនឹងបាត់បង់ជីវិត ប្រសិនបើគាត់មិនសម្រេចចិត្តរត់ត្រឡប់មកផ្ទះវិញ នៅពេលដែលខ្មែរក្រហមជម្លៀសគាត់ឲ្យចូលក្នុងព្រៃសំដៅទៅកាន់ព្រំដែនថៃ នៅឆ្នាំ១៩៧៩។ ឪពុកខ្ញុំបានសម្រេចចិត្តថា គាត់សុខចិត្តស្លាប់នៅស្រុកកំណើតប្រសើរជាងស្លាប់ជាមួយខ្មែរក្រហមនៅក្នុងព្រៃ និងនៅស្រុកគេ។ រឿងរ៉ាវទាំងនេះ នៅតែដក់ជាប់ក្នុងអារម្មណ៍របស់ឪពុកខ្ញុំរហូតមកដល់សព្វថ្ងៃ។

**អ៊ុន សុដារី**

# ២០ ឧសភា អតីតកាលមិនត្រូវបានបំភ្លេច

ទិវាជាតិនៃការចងចាំ ២០ ឧសភា ប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំបាននាំមកនៅការផ្សះផ្សាជាតិសាសន៍ខ្មែរ និងគោរពទៅដល់វិញ្ញាណក្ខន្ធ ប្រជាជនខ្មែរប្រមាណជាង២លាននាក់ ដែលបានបាត់បង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ទិវាជាតិនេះបានធ្វើឲ្យប្រជាជនខ្មែរលើកយករឿងរ៉ាវប្រវត្តិសាស្ត្រដ៏ឈឺចាប់នេះមក ធ្វើការពិភាក្សាឡើងវិញពីជំនាន់មួយទៅជំនាន់មួយ ដើម្បីទប់ស្កាត់របបខ្មែរក្រហមកុំឲ្យកើតឡើងម្តងទៀត។ ទោះបីមានការរិះគន់ ឬចោទប្រកាន់ខាងផ្នែកនយោបាយយ៉ាងណាក៏ដោយ ក៏ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះមិនត្រូវបានបំភ្លេច ពីព្រោះប្រជាជនខ្មែរទូទាំងប្រទេសធ្លាប់បានទទួលរងផលប៉ះពាល់ពីរបបនេះ។

នួន ណារ៉ែល អាយុ ៦៨ ជាក្រុមប្រឹក្សាសង្កាត់ស្ទឹងមានជ័យទី៣ បានចូលរួមកម្មវិធីនេះជារៀងរាល់ឆ្នាំនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍បឹងជើងឯក។ ណារ៉ែល មានប្រសាសន៍ថា ទិវាជាតិនៃការចងចាំគឺជារឿងត្រឹមត្រូវមួយ ដើម្បីរំឭក និងបង្រៀនទៅដល់ក្មេងជំនាន់ក្រោយឲ្យយល់ដឹងពីរបបខ្មែរក្រហមដែលសម្លាប់មនុស្សយ៉ាងរង្គាល សម្លាប់ក្រុមបញ្ញវន្ត កុមារ៉ា កុមារី រួមទាំងប្រជាជនទូទៅ។ ណារ៉ែល បន្តថា យើងជាប្រទេសកាន់ព្រះពុទ្ធសាសនាមិនគួរមានការសម្លាប់គ្នានោះទេ។

មុល ចន្ទី អាយុ៣០ឆ្នាំ មានស្រុកកំណើតមកពីខេត្តមណ្ឌលគិរី សព្វថ្ងៃជាសណ្ឋាប់ធ្នាបខណ្ឌ ព្រែកព្នៅ មានប្រ-សាសន៍ថា នេះជាលើកទីមួយរបស់គាត់ដែលបានចូលរួមទិវាជាតិនៃការចងចាំ។ ចន្ទី បានសម្តែងអារម្មណ៍ សោកស្តាយចំពោះរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយក្រុមគ្រួសាររបស់គាត់ក៏បានទទួលការឈឺចាប់ពីរបបនេះដែរ។ គាត់មានភាពតក់ស្លុត នៅពេលដែលគាត់បានឃើញរណ្តៅសាកសពទាំងនោះ។

ឈឿន ចាន់ណា អាយុ២៣ ជានិស្សិតផ្នែកធនាគារ ឆ្នាំទី៤ មានប្រសាសន៍ថា ទិវាជាតិនៃការចងចាំ ២០ ឧសភា ២០១៨ គឺជាលើកទីមួយរបស់គាត់ដែលបានចូលរួម។

ចាន់ណា មានអារម្មណ៍ក្តុកក្តួលដែលបានចូលរួមក្នុងទិវាជាតិនៃការចងចាំ ពីព្រោះបានធ្វើឲ្យគាត់គិតស្រមៃទៅដល់ប្រជាជនខ្មែរ ដែលបានឆ្លងកាត់របបខ្មែរក្រហម តើអ្នកទាំងនោះមានសភាពរងទុក្ខវេទនាយ៉ាងណា។ ចាន់ណា បន្តថា គាត់ចូលរួមទិវាជាតិនេះ គឺដើម្បីសិក្សា និងស្វែងយល់បន្ថែមអំពីរបបខ្មែរក្រហមដែលធ្លាប់តែនិយាយតៗគ្នាពីក្រុមគ្រួសារនិងចាស់ៗ។ ចាន់ណា ជឿថាទិវាជាតិនៃការចងចាំនឹងនាំមកនៅសាមគ្គីភាពនិងការផ្សះផ្សាជាតិ។

**អ៊ិន វណ្ណារ៉ា**


អដ្ឋិធាតុជនរងគ្រោះនៅសារមន្ទីរប្រល័យពូជសាសន៍បឹងជើងឯក

# ណាង សាលីម ៖ ជីវិតជាប់គុកខ្មែរក្រហម ខ្ញុំចាំមិនភ្លេចទេ

ណាង សាលីម គឺជាមេភូមិត្រពាំងរុន ឃុំសង្កែ។ ឆ្នាំនេះគាត់មានអាយុ៧៨ឆ្នាំហើយ។ អង្គុយនៅក្រោមដើមជ្រៃចំហៀងផ្ទះគាត់ជាមួយសម្លៀកបំពាក់អ្នកស្រែចម្ការ សាលីម បានរំឭករឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមដែលគាត់មិនអាចបំភ្លេចបាននៅក្នុងជីវិតរបស់គាត់។ នោះគឺជា ជីវិតក្នុងគុកខ្មែរក្រហម។

ខាងក្រោមនេះ ជាសម្ដីទាំងស្រុងរបស់គាត់ក្នុងពេលជួបជាមួយក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖

«ខ្ញុំឈ្មោះ ណាង សាលីម អាយុ៧៨ឆ្នាំ រស់នៅភូមិត្រពាំងរុន ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង។ កាលពីជំនាន់ ប៉ុល ពត ស្រុករំដួល មានឈ្មោះថា ស្រុកសំរោង។ ឪពុករបស់ខ្ញុំឈ្មោះ ណាង ង៉ូយ និងម្ដាយ ឡោ ថុង។ ឪពុកខ្ញុំស្លាប់នៅឆ្នាំ១៩៧៨ ដោយអត់អាហារ។ ឯម្ដាយខ្ញុំស្លាប់នៅឆ្នាំ១៩៨១ ដោយជំងឺ។ ខ្ញុំមិនបានរៀនជ្រៅជ្រះនឹងគេទេ ប៉ុន្តែខ្ញុំអាចអាននិងសរសេរបាន។ ក្រោយពីឈប់រៀននៅថ្នាក់បឋមសិក្សាខ្ញុំបានជួយធ្វើកិច្ចការផ្ទះជំនួសដៃជើងឪពុកម្ដាយ រហូតដល់ខ្ញុំធំល្មម អាចចេញរកប្រាក់ចិញ្ចឹមគ្រួសារបាន។ ខ្ញុំលក់ការ៉េម លក់ ប្រហុក និងលក់ត្រីងៀត រហូតដល់ខ្ញុំមានអាយុ១៩ឆ្នាំ ទើបឪពុកម្ដាយខ្ញុំរៀបចំឲ្យមានប្រពន្ធ។ កាលនោះប្រហែលជាឆ្នាំ១៩៦១។ ខ្ញុំ និងប្រពន្ធ បានទៅរស់នៅផ្ទះឪពុកម្ដាយក្មេកអស់រយៈពេល១ឆ្នាំ មុននឹងចេញទៅធ្វើការនៅក្នុងរោងម៉ាស៊ីនកិនស្រូវនៅជីភូ។ ខ្ញុំនៅទីនោះបាន៦ឆ្នាំ។ ខ្ញុំបានសន្សំលុយទិញដីបានចំនួន៥ហិកតា និងមានមុខរបរផ្ទាល់ខ្លួនមួយ។ ប៉ុន្តែខ្ញុំបានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្ដម សីហនុ ឆ្នាំ១៩៧០។ កាលនោះ ស្រុកទេសមានសភាពចលាចលកើតឡើងកាន់តែខ្លាំងទៅៗ ហើយយន្តហោះបានទម្លាក់គ្រាប់បែកជាច្រើនគ្រាប់មកលើភូមិនេះ (ភូមិត្រពាំងរុន) ដោយសារតែមានប្រជាជនក្នុងភូមិមួយចំនួន បានប្ដូរគំនិតចូលរួមគាំទ្រចលនារំដោះជាតិរបស់ខ្មែររំដោះ។ ខ្ញុំក៏ដូចអ្នកភូមិឯទៀតដែលមិនបានចុះចូលជាមួយខ្មែររំដោះ តែងតែចេញមកក្រៅផ្ទះ និងលើកដៃសំពះយន្តហោះដើម្បីសុំសេចក្ដីសុខ នៅពេលដែលឮសំឡេងយន្តហោះហោះមកម្ដងៗ។

នៅដើមឆ្នាំ១៩៧៥ខ្ញុំត្រូវបានចាប់ខ្លួនមកដាក់នៅមន្ទីរសន្តិសុខស្រុកសំរោង(បច្ចុប្បន្នស្រុករំដួល) ឈ្មោះ ទួលប្រោះ ពីបទចោទប្រកាន់ថា បានលួចគោក្របីអ្នកស្រុកទៅលក់ឲ្យវៀតណាម។ កងឈ្លបអាយុជាង១០ឆ្នាំបួនប្រាំនាក់មកពីភូមិពោន ឃុំកំពង់អំពិលបានមកហៅថាឲ្យទៅកាន់មន្ទីរឃុំ ដើម្បីសាកសួរពីបញ្ហាមួយចំនួន។ កងឈ្លបទាំងនោះបានបណ្ដើរខ្ញុំកាត់ភូមិត្រពាំងរុននេះឆ្ពោះទៅកាន់មន្ទីរឃុំ។ ដើរបានពាក់កណ្ដាលផ្លូវ កងឈ្លបបានឲ្យ ខ្ញុំឈប់ រួចស្នើខ្ញុំថា គេសុំចងដៃនិងរុំមុខខ្ញុំ។ ខ្ញុំនៅចាំបានថា ខ្ញុំបានទៅដល់ជ្រុងពពេលហើយក្នុងពេលនោះ។ ចាប់តាំងពីពេលនោះមក ខ្ញុំលែងដឹងថាខ្ញុំនៅកន្លែងណាទៀតហើយ។ ឈ្លបឲ្យខ្ញុំជិះលើចង្កើរកង់ រួចឈ្លបបណ្ដើរកង់ចេញទៅ។ ពេលទៅដល់មន្ទីរសន្តិសុខ ខ្ញុំត្រូវកងសន្តិសុខរុញចូលទៅក្នុងរួចវាយធ្វើបាបខ្ញុំទាំងមិនស្រាយមុខ។ បន្ទាប់មក ឈ្លបសួរចម្លើយខ្ញុំ។ ខ្ញុំបានឮអ្នកទោសផ្សេងទៀតស្រែកនៅក្បែរៗខ្ញុំ។ ខ្ញុំត្រូវកងសន្តិសុខសួរចម្លើយ៣ដងហើយ សួរតែសំណួរមួយគត់គឺ **តើអ្អែងមានបានលួចគោក្របីរបស់អ្នកភូមិយកទៅលក់ឲ្យវៀតណាមអត់?** សួរលើកទី១ ខ្ញុំឆ្លើយបដិសេធថា មិនបានលួចគោក្របីរបស់នរណាទេ។ សួរលើកទី២ខ្ញុំនៅតែឆ្លើយបដិសេធដដែល ព្រោះខ្ញុំពិតជាមិនបានលួចរបស់គេមែន។ នៅពេលដែលឈ្លបយកចម្លើយពីខ្ញុំមិនបាន ឈ្លបវាយខ្ញុំនឹងគល់ឫស្សី និងដាងត្នោត។ ខ្ញុំមិនខ្លាចគល់ឫស្សីទេ តែខ្ញុំខ្លាចដាងត្នោត។ ឈ្លបចងជើងខ្ញុំទាំង២ភ្ជាប់ នឹងគ្រែ។ ឈ្លបចងរិតត្រកៀកខ្ញុំ។ ឈ្លបចងស្ពាបសេកដៃខ្ញុំទាំង២ទៅ

ក្រោយភ្ជាប់នឹងរនូតគ្រែឫស្សី។ ចំណែកក្រមា ចងមុខខ្ញុំវិញ ឈ្លបមិនដែលស្រាយចេញឡើយ។ ខ្ញុំមិនបានមើលឃើញអ្វីសោះអស់រយៈពេល១ខែកន្លះ។ ខ្ញុំត្រូវកងសន្តិសុខនាំយកទៅសួរចម្លើយលើកទី៣ទៀត។ លើកនេះខ្ញុំបានឆ្លើយសារភាពថា ខ្ញុំនិងបក្ខពួក២នាក់ទៀតគឺ តឹក ផេង និង អ៊ុំាង ពិតជាបានលួចគោក្របីអ្នកស្រុកទៅលក់ឲ្យវៀតណាមមែន។ ចាប់តាំងពីពេលនោះមក ពួកឈ្លបលែងសួរចម្លើយខ្ញុំទៀតហើយ។ ឈ្លបស្រាយក្រមាដែលចងមុខខ្ញុំអស់រយៈពេល១ខែកន្លះកន្លងមក។ ខ្ញុំស្រវាំងភ្នែកមួយសន្ទុះ ទម្រាំអាចមើលឃើញឡើងវិញ។ ខ្ញុំបានមើលឃើញអ្នកទោសប្រហែល១០នាក់ដាប់នៅក្បែរខ្ញុំ។ នៅខាងចុងជើងអ្នកទោស ខ្ញុំឃើញមានកងសន្តិសុខប្តូរវេណគ្នាយាម។ ពេលយប់វាអុជចង្កៀង ប្រេងកាតមួយបំភ្លឺមើលអ្នកទោស។ មិនយូរប៉ុន្មានខ្ញុំបានឃើញ តឹក ផេង និងអ៊ុំាង ត្រូវចាប់ខ្លួនបញ្ជូនមកកាន់ទីនេះដែរ ហើយទទួលទណ្ឌកម្មនិងសួរចម្លើយដូចខ្ញុំអញ្ចឹង។ ក្រោយមក ខ្ញុំត្រូវកងសន្តិសុខបញ្ជូនទៅកាន់មន្ទីរអប់រំកែប្រែ មុននឹងវាអនុញ្ញាតិឲ្យវិលត្រឡប់មកផ្ទះវិញ។ កម្មាភិបាលធំៗ៣នាក់គឺ សៅ សារ៉េត ជាគណៈស្រុកសំរោង ឈុំ ជាអនុ(គណៈស្រុក) និង យក្ស ជាអ្នកគ្រប់គ្រងមន្ទីរ គឺជាអ្នកទូន្មានខ្ញុំថាឲ្យឈប់លួចគោក្របីអ្នកស្រុកទៀត។ ខ្ញុំស្តាប់និងយល់ព្រមទទួលពាក្យទូន្មានទាំងនោះ។ បន្ទាប់មក ពួកឈ្លបដោះលែងខ្ញុំជាមួយអ្នកទោស ៦ នាក់ផ្សេងទៀត។

នៅឆ្នាំ១៩៧៨ ខ្ញុំនិង អ្នកឯទៀតត្រូវជម្លៀសចេញពីស្រុកកំណើត។ ខ្មែរក្រហមមិនបានប្រាប់យើងថា ត្រូវទៅកាន់កន្លែងណាឡើយ ប៉ុន្តែឈ្លបចេះតែឲ្យយើងធ្វើដំណើរទៅមុខរហូត។ ខ្ញុំនិងគ្រួសារឈប់សម្រាកនៅស្រុកស្វាយជ្រុំ ចំនួន ៣យប់ ទើបបន្តដំណើរទៅកាន់តាគោក ក្នុង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ពួកខ្ញុំនៅទីនោះ ប្រហែល ២ខែ។ បន្ទាប់មកខ្ញុំបន្តដំណើរទៅកាន់អ្នកលឿង។ គោក្របីដែលខ្ញុំយកទៅជាមួយ ត្រូវទុកចោលនៅតាគោកទាំងអស់។ នៅអ្នកលឿង កម្មាភិបាលខ្មែរក្រហមចែកអង្ករឲ្យម្នាក់១កំប៉ុងក្នុង១ថ្ងៃ។ ខ្ញុំសប្បាយចិត្តបន្តិច ព្រោះបានហូបគ្រាន់បើជាងនៅភូមិ។ ខ្ញុំបន្តដំណើរតាមកាណូតពីអ្នកលឿងមកកាន់ច្បារអំពៅ រួចឆ្ពោះទៅផ្សារថ្មី ដើម្បីត្រៀមខ្លួនជិះរថភ្លើងបន្តទៀត។ ទៅដល់



នាង សាលីម





នាង សាលីម ធ្វើត្រាប់តាមឈ្លបខ្មែរក្រហមដែលបានវាយ និងចងគាត់

ផ្សារថ្មី ខ្ញុំគ្មានឃើញអ្វីក្រៅពីលាមកមនុស្ស នៅពាសពេញក្នុងផ្សារ។ ពិបាកដក ដង្ហើមណាស់។ ស្អុយផង ឆ្អេះផង។ នៅទីនោះម្នាក់ៗមកពីស្វាយរៀងទាំងអស់បានទទួលសម្លៀកបំពាក់ខ្មៅម្នាក់ ១កំប្លេ និងក្រមាស-ខៀវ១។ ខ្ញុំសម្រាកនៅផ្សារថ្មី១យប់១ថ្ងៃ មុននឹងចេញដំណើរតាមរថភ្លើងបន្តនៅម៉ោងជាង៧ល្ងាច។ ខ្ញុំទៅដល់ស្ថានីយ៍ស្វាយដូនកែវនៅម៉ោងប្រមាណ ៤ទៀបភ្លឺ។ ខ្ញុំដាំបាយហូបជាមួយគ្រួសារនៅក្បែររ៉ាវរថភ្លើង។ ប្រជាជននៅក្នុងរថភ្លើងទាំងអស់ត្រូវបែងចែកឲ្យទៅកាន់ត្រពាំងជង និងមោងឫស្សី។ ខ្ញុំត្រូវកម្មាភិបាលចាត់តាំងឲ្យទៅមោងឫស្សី។ ទៅដល់មោងឫស្សីប្រហែលម៉ោង៦យប់។ ខ្ញុំបានសុំថ្នាំជក់អ្នកស្រុកខ្លះដើម្បីជក់។ អ្នកស្រុកឲ្យខ្ញុំច្រើនណាស់។ ខ្ញុំសប្បាយចិត្ត ព្រោះដូចអ្វីដែលខ្ញុំបានគិតមែន គឺបានហូបឆ្អែតមានថ្នាំជក់គ្រប់គ្រាន់ និងមានការរាក់ទាក់ជាងកម្មាភិបាលនៅឯស្រុកកំណើត។ ក្រោយមក គេបែងចែកខ្ញុំឲ្យទៅនៅកង្គួរ ហើយប្រពន្ធខ្ញុំនៅសហករណ៍។ តាប៉ក់ និងតាប៉េងគឺជាអ្នកគ្រប់គ្រងសហករណ៍។ពួកគាត់មិនកាចសាហាវដូចគេប្រាប់ខ្ញុំឡើយ។ រយៈពេលបីបួនខែក្រោយមក ខ្ញុំឮស្គរស្នូកាំភ្លើងធំនៅប៉ែកខាងកើត។ ប្រជាជននិងកម្មាភិបាលខ្មែរក្រហមចាប់ផ្តើមជ្រួលច្របល់លែងធ្វើការ។ ខ្ញុំត្រូវទៅតាមខ្មែរក្រហមទៅកាន់ភ្នំធិបតីដើម្បី គេចពីគ្រាប់ផ្លោងរបស់យួន។ នៅតាមផ្លូវ ខ្ញុំត្រូវពស់ពិសចឹកចំដៃស្តាំ។ ខ្ញុំវិលមុខ គ្រុនក្តៅខ្លាំងណាស់។ ខ្ញុំគិតថា ខ្ញុំប្រហែលជាស្លាប់នៅទីនោះហើយ តែសំណាងល្អមាន កងចល័តម្នាក់មកមើលស្នាមពស់ចឹកនៅលើដៃខ្ញុំ រួចប្រាប់ ថាកុំភ័យអី ព្រោះពស់ដែលចឹកខ្ញុំនោះ គឺមិនមែនជាពស់ស្រកាចាស់ទេ។ ខ្ញុំមានសង្ឃឹមបន្តិចឡើងវិញ។ គាត់បានលាយលាមកមនុស្សជាមួយនឹងទឹកនោមឲ្យខ្ញុំផឹក។ គ្រាន់តែផឹកចូលដល់ពោះភ្លាម ខ្ញុំក្អួតចេញវិញទាំងអស់។ ក្រោយមក ខ្ញុំក៏បានធូរ និងអាចបន្តដំណើរទៀតបានរហូតដល់ស្រុកកំណើត។ មកដល់ភ្លាម គ្មានមនុស្សម្នាក់សោះនៅក្នុងភូមិនេះ។

**ផេង ពង្សរ៉ាស៊ី**

# ដំណឹងជ្រើសរើសអ្នកស្រាវជ្រាវ

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន៣០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរពីប្រវត្តិសាស្ត្ររឿងរ៉ាវចេញពីភូមិឃុំកំណើត ឬភូមិឃុំដែលខ្លួនកំពុងរស់នៅ ដែលជាប់ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្តីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់លោកគ្រូអ្នកគ្រូ នឹងត្រូវបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនលោកគ្រូអ្នកគ្រូវិញដើម្បីប្រើប្រាស់ជាសម្ភារៈឧបទ្ទេសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។

   

*លក្ខខណ្ឌជ្រើសរើស*

១) អ្នកស្រាវជ្រាវ គឺត្រូវតែជាគ្រូមុខវិជ្ជាប្រវត្តិវិទ្យានៅក្នុងខេត្តព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ កណ្ដាល (ស្រុកមុខកំពូល ល្វាឯម និងខ្សាច់កណ្ដាល) និងក្រចេះ (ស្រុកឆ្លូង) ដែលមិនជាប់តួនាទីជានាយកឬនាយករងនៃវិទ្យាល័យដែលខ្លួនកំពុងធ្វើការ។

២) មានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការធ្វើកិច្ចការស្រាវជ្រាវដូចជាការធ្វើបទសម្ភាសន៍,ទំនាក់ទំនងជាមួយអ្នកដែលត្រូវសម្ភាសន៍ វិភាគលើទិន្នន័យដើម និងសរសេរ។

៣) មានចំណេះដឹងសមរម្យក្នុងការប្រើប្រាស់កុំព្យូទ័រលើកម្មវិធី Microsoft Word Excel និងមានកុំព្យូទ័រផ្ទាល់ខ្លួន។

៤) មានការប្ដេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចបាននូវសំណេរតាមការកំណត់។

៥) មានភាពច្នៃប្រឌិតចំពោះការប្រើប្រាស់ឧបករណ៍ (ថតសម្លេង និងម៉ាស៊ីនថត) សម្រាប់កិច្ចការស្រាវជ្រាវ។

៦) មានសមត្ថភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

*លក្ខខណ្ឌការងារ*

១) ធ្វើកិច្ចការស្រាវជ្រាវដោយមិនឲ្យប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សនៅតាមវិទ្យាល័យដែលខ្លួនកំពុងបង្រៀន។

២) ប្រើប្រាស់ពេលវិស្សមកាល ឬពេលទំនេរពីការបង្រៀន ដើម្បីធ្វើកិច្ចការនេះ។

៣) បែងចែកពេលវេលាច្បាស់លាស់ពីដំណើរការប្រព្រឹត្តទៅនៃកិច្ចការស្រាវជ្រាវ រួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីការសហការ។ ឧទាហរណ៍៖ បង្ហាញគម្រោងផែនការជាដំណាក់កាលៗដូចជា៖ ប្រមូលធនធានសម្រាប់ឯកសារយោង កំណត់គោលដៅសម្រាប់សម្ភាសន៍ ការសម្ភាសន៍ វិភាគទិន្នន័យសម្ភាសន៍ និងសំណេរ។

៤) សរសេរពីកិច្ចការស្រាវជ្រាវឲ្យបានយ៉ាងហោចណាស់២០ទំព័រ។

៥) ផ្ញើសំណេរ និងកិច្ចសម្ភាសន៍ជាសម្លេងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុកនិងងាយស្រួលក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ព។

ប្រសិនបើលោកគ្រូអ្នកគ្រូចាប់អារម្មណ៍លើកិច្ចការនេះ សូមដាក់ពាក្យស្នើសុំមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយភ្ជាប់មកជាមួយនូវ៖ ១) ពាក្យស្នើសុំធ្វើកិច្ចការស្រាវជ្រាវប្រវត្តិភូមិ។ ២) ប្រវត្តិរូបសង្ខេប១ច្បាប់ និង ៣) សេចក្ដីអធិប្បាយត្រួសៗពីប្រធានបទដែលចង់សរសេរចេញពីភូមិកំណើតរបស់ខ្លួន តាមអស័យដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬផ្ញើមកកាន់អ៊ីម៉ែល truthrasy.p@dccam.org។ ការទទួលពាក្យផុតកំណត់ត្រឹម ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមទូរសព្ទ ០១២ ៦៩៦ ៩៦១ ឬអ៊ីម៉ែល truthrasy.p@dccam.org ។

# «កុំស្មានបងភ្លេច៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់» បានឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រកម្ពុជាដល់ជនបរទេស

ក្រុមនិស្សិតមួយក្រុមមកពីសាកលវិទ្យាល័យណរឌិន អ៊ីលីណយស៍ ភាគខាងជើងរបស់សហរដ្ឋអាមេរិកក្រោមការដឹកនាំរបស់សាស្ត្រាចារ្យបណ្ឌិតដូឌីលីដហ្សរវូដ នៅរសៀលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ បានមកធ្វើទស្សនកិច្ចសិក្សានៅវិចិត្រសាលសិល្បៈសហសម័យ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

បន្ទាប់ពីការស្វាគមន៍និងធ្វើបទបង្ហាញពីកិច្ចការទូទៅទាក់ទងវិចិត្រសាលពីលោក ស៊ាង ចិន្តា ក៏មានការបញ្ចាំងភាពយន្តឯកសារ «កុំស្មានបងភ្លេច៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់» ដល់ក្រុមនិស្សិតទស្សនា។ ភាពយន្តឯកសារនេះ បានចាក់បញ្ចាំងជាបន្តបន្ទាប់ ឲ្យទស្សនិកជនទស្សនានៅក្នុងប្រទេសកម្ពុជារយៈពេល៤ឆ្នាំកន្លងមកហើយហើយនៅតែទាក់ទាញចំណាប់អារម្មណ៍ពីប្រជាជន សិស្ស និស្សិត មន្ត្រីរាជការ និងគ្រូបង្រៀន។

ភាពយន្តឯកសារ «កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់» ជាភាពយន្តមួយដែលឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រពាក់ព័ន្ធនឹងភាពសម្បូរបែបនៃបទចម្រៀង និងតន្ត្រីខ្មែរនាអំឡុងទស្សវត្សរ៍ឆ្នាំ១៩៦០ និងឆ្នាំ១៩៧០ និងជាតន្ត្រីមួយដ៏ពេញនិយមក្នុងសម័យនោះ។ ភាពយន្តឯកសារ «កុំស្មានបងភ្លេច» មិនត្រឹមបង្ហាញពីការរីកចម្រើនសិល្បៈបែបបស្ចិមប្រទេស



ក្រុមនិស្សិតទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច»

នាសម័យនោះទេ ប៉ុន្តែក៏បានបង្ហាញពីសោកនាដកម្មភាពរន្ធត់តក់ស្លុត ដែលខ្មែរក្រហមបានប្រព្រឹត្តទៅលើសិល្បៈករ និងប្រជាជនខ្មែរស្លូតត្រង់ៗ ដូចទៅនឹងទាហាននិងមន្ត្រីរដ្ឋការនៅក្នុងសង្គមចាស់សិល្បៈក៏ជាគោលដៅបោសសម្អាតរបស់ក្រុមខ្មែរក្រហមដែរ។

និស្សិតឈ្មោះ អាឡូរា ហ្គូមេស្ស មកពីសកលវិទ្យាល័យ ណខិន អ៊ីលីណយស៍ ភាគខាងជើងនៃសហរដ្ឋអាមេរិក មានអារម្មណ៍តក់ស្លុត និងភ្ញាក់ផ្អើលយ៉ាងខ្លាំងបន្ទាប់ពីបានទស្សនាភាពយន្តឯកសារ «កុំស្មានបងភ្លេចៈខ្មែរបាត់បង់តន្ត្រីរ៉ក់» នៅរសៀលនេះ ព្រោះគាត់បានឃើញសហរដ្ឋអាមេរិកមានជាប់ពាក់ព័ន្ធជាមួយសង្គ្រាមវៀតណាម និងរបបខ្មែរក្រហមដែរ។ នេះជាលើកដំបូងរបស់គាត់ដែលបានមកដល់ប្រទេសកម្ពុជា ហើយបានដឹងពីរឿងរ៉ាវទាំងនេះ។ គាត់ពិតជាសោកស្ដាយណាស់នៅពេលដែលឮរឿងរ៉ាវទាំងនេះ ហើយគាត់មិនដឹងថា តើប្រជាជនទាំងអស់ ទទួលយក និងដោះស្រាយបញ្ហាទាំងអស់ដោយរបៀបណានៅខណៈពេលនោះ។ គាត់យល់ឃើញថា នេះគឺជាប្រវត្តិសាស្ត្រមួយត្រូវតែនិយាយបន្ត ព្រោះមនុស្សមួយចំនួនមិនបានដឹងដូចគាត់ទេ។ ទោះបីជារបបខ្មែរក្រហមជាប្រវត្តិសាស្ត្រមួយដ៏ជូរចត់ ដែលមិនគួរចង់ឲ្យស្ដាប់ ប៉ុន្តែបច្ចុប្បន្នយើងត្រូវតែនិយាយផ្សព្វផ្សាយបន្តតាមរយៈការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលាសម្រាប់ក្មេងៗជំនាន់ក្រោយ។ គាត់សង្ឃឹមថា ប្រជាជនខ្មែរដែលបានឆ្លងកាត់របបខ្មែរក្រហមទាំងអស់ អាចទទួលបានសន្តិភាព ហើយប្រទេសកម្ពុជាទាំងមូលអាចដោះស្រាយវិបត្តិអតីតកាលនេះបាន។ ទោះបីជា អាឡូរា ហ្គូមេស្ស មានអារម្មណ៍តក់ស្លុតយ៉ាងណា តែគាត់ពិតជាចូលចិត្តខ្សែភាពយន្តនេះយ៉ាងខ្លាំង ហើយក៏សង្ឃឹមថា នឹងបានរៀនសូត្របន្ថែមពីរបបខ្មែរក្រហមតាមរយៈខ្សែភាពយន្តឯកសារនេះនៅថ្ងៃអនាគត។



កាតលិន អេ. វេសម្នេន សាស្ត្រាចារ្យ ផ្នែកសង្គមវិទ្យា នៅសាកលវិទ្យាល័យ ណខិន អ៊ីលីណយស៍ ភាគខាងជើង បាននិយាយថា ភាពយន្តឯកសារ«កុំស្មានបងភ្លេច៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់» ពិតជាភាពយន្តមួយល្អ ព្រោះវាបានឆ្លុះបញ្ចាំងពីភាពជាក់ស្ដែងអំពីប្រវត្តិសាស្ត្រ និងបានធ្វើឲ្យអ្នកទស្សនាយល់ដឹងកាន់តែច្រើនពីការផ្លាស់ប្ដូរបរិបទសង្គម និងតន្ត្រីខ្មែរ។

ចំណែកសាស្ត្រាចារ្យបណ្ឌិត ជូឌី លីដហ្សរវូដ នៅសាកលវិទ្យាល័យ ណខិន អ៊ីលីណយស៍ ភាគខាងជើងបានឲ្យដឹងថាគាត់មិនធ្លាប់បានទស្សនាខ្សែភាពយន្តឯកសារ«កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់» ពីមុនទេ ហើយវាល្អណាស់សម្រាប់ផ្ដល់ចំណេះដឹងបន្ថែមដល់គាត់ ទៅលើរបបខ្មែរក្រហម។ ភាពយន្តឯកសារនេះ ពិតជាជួយដល់ក្មេងៗជំនាន់ក្រោយ ដូចជាសិស្សរបស់គាត់ដែលបានទស្សនានៅទីនេះ ហើយសិស្សទាំងអស់ នឹងស្វែងយល់បន្ថែមទៀតពីរបបខ្មែរក្រហម។

**អ៊ុន សុដាវី**

# សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជា តាមរយៈការទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក់»

នៅព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ និស្សិតផ្នែកនីតិសាស្ត្រ និងផ្នែករដ្ឋបាល ឆ្នាំទី១ ប្រមាណ១០០នាក់ មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ចបានចាប់អារម្មណ៍មកធ្វើទស្សនកិច្ចសិក្សា នៅសាលសិល្បៈសហសម័យនៃវិទ្យាស្ថានស្លឹករឹតក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ។ ការមកធ្វើទស្សនកិច្ចសិក្សានេះគឺមកក្នុងគោលបំណងទស្សនាខ្សែភាពយន្តឯកសារប្រវត្តិសាស្ត្រ ដែលមានចំណងជើងថា «កុំស្មានបងភ្លេច»។ ជាខ្សែភាពយន្តនិយាយអំពីសិល្បៈក្នុងអំឡុងទសវត្សរ៍៦០ និងដើមទសវត្សរ៍៧០ និងអំពីតន្ត្រី រ៉ក អេន រ៉ូល ដែលខ្មែរបានបាត់បង់ក្នុងអំឡុងពេលប្រទេសកើតសង្គ្រាម។ តន្ត្រីមួយនេះ បានចម្លងចេញពីបស្ចិមប្រទេស ដោយរួមបញ្ចូលឫសគល់នៃតន្ត្រីដើមរបស់ខ្មែរ ហើយបង្កើតតន្ត្រីមួយបែបថ្មីខុសពីតន្ត្រីដទៃទៀត។ តន្ត្រីករខ្មែរបានបង្កើតតន្ត្រីមួយបែបនេះ ចេញពីក្បួនខ្នាតដ៏សំខាន់នៃតន្ត្រីរ៉ក់ផ្សេងៗរបស់អាមេរិក អង់គ្លេស និងបារាំង ដោយដាក់បញ្ចូលសំឡេង និងចង្វាក់ តន្ត្រីប្រពៃណីខ្មែរតែមួយគត់



ក្រុមនិស្សិតទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច»

របស់ខ្លួន។ សំឡេងដ៏ពិរោះរបស់អ្នកចម្រៀងស្ត្រីដ៏ល្បីឈ្មោះ បានក្លាយជាចំណុចទាក់ទាញ ហើយធ្វើឲ្យតន្ត្រីថ្នៃប្រឌិតមួយនេះទទួលបានការពេញនិយមយ៉ាងខ្លាំង ពីសំណាក់សាធារណជន។ ប៉ុន្តែនៅពេលដែលសង្គមខ្មែរ ជាពិសេសតន្ត្រីវ័យក្មេងដែលទទួលយកវប្បធម៌បស្ចឹមប្រទេស ហើយបានវិវឌ្ឍន៍ខ្លួនក្រោមឥទ្ធិពលនៃវប្បធម៌នេះប្រទេសកម្ពុជាបានធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាមយ៉ាងឆាប់រហ័ស។ «កុំស្មានបងភ្លេច ៖ ខ្មែរបាត់បង់តន្ត្រីរ៉ក» បានដឹកកកាយនូវលក្ខណៈធាតុផ្សំរបស់តន្ត្រីខ្មែរ ដែលបានប្រែក្លាយទៅជាតន្ត្រី រ៉ក អេន រ៉ូល ហើយបានរីកចម្រើនឆ្ពោះទៅមុខ ប៉ុន្តែស្ទើរត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងនៅក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ខ្សែភាពយន្តឯកសារនេះបានផ្តល់គំហើញថ្មីស្តីពីប្រទេសមួយដែលបង្រៀនផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ



និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំនិស្សិតមកធ្វើទស្សនកិច្ចសិក្សានិងទស្សនាខ្សែភាពយន្តឯកសារ«កុំស្មានបងភ្លេច» ដ៏មានសារសំខាន់ ក្នុងការផ្តល់ជាចំណេះដឹងមួយផ្នែកទៀត បានមានប្រសាសន៍ថា ទស្សនកិច្ចសិក្សានេះ គឺជាផ្នែកមួយសម្រាប់និស្សិតដែលបានចូលរួម។ សាស្ត្រាចារ្យបណ្ឌិត ជា សៀវម៉ី បន្តថា សម្រាប់សិស្សានុសិស្ស ឬនិស្សិត នាពេលបច្ចុប្បន្នក្រៅពី ការអានសៀវភៅ មានតែការធ្វើទស្សនកិច្ចសិក្សា និងទស្សនាខ្សែភាពយន្តឯកសារទើបធ្វើឲ្យពួកគាត់ទទួលបានចំណេះដឹងបន្ថែមទៀត ពីប្រវត្តិសាស្ត្រកម្ពុជា។ ខ្សែភាពយន្តឯកសារនេះ បានឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រ ប្រទេសកម្ពុជាពីសម័យកាលមួយទៅសម័យកាលមួយ។ មិនត្រឹមតែប៉ុណ្ណោះខ្សែភាពយន្តនេះ ក៏មានបទភ្លេងចម្រៀងពិរោះៗដែលធ្វើឲ្យអ្នកទស្សនាមិនមានអារម្មណ៍ជិនណាយ។

បន្ទាប់ពីទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» រួចមក និស្សិត ទៀង មករា ភេទស្រី រៀនផ្នែករដ្ឋបាលឆ្នាំទី១ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានបញ្ចេញយោបល់ថា«ខ្សែភាពយន្តឯកសារនេះបានឆ្លុះបញ្ចាំងពី បរិបទសង្គម កម្ពុជា សិល្បៈ និងការផ្លាស់ប្តូររបបនយោបាយយ៉ាងឆាប់រហ័ស បណ្តាលឲ្យប្រជាជនខ្មែរពិបាកក្នុងការសម្របខ្លួន»។

ដំណើរទស្សនកិច្ចនេះ ក៏មានការចូលរួមពីសំណាក់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាមកធ្វើបទបង្ហាញ ស្តីពីប្រវត្តិនៃការបង្កើតខ្សែភាពយន្តឯកសារនេះឡើង និងបានបង្ហាញពីសារសំខាន់នៃការសិក្សាអំពីសិល្បៈជំនាន់ដើម ក៏ដូចជាខ្សែភាពយន្តឯកសារនេះ។ លោក ឆាំង យុ បន្ថែមថា ខ្សែភាពយន្តឯកសារនេះ បានដាក់បញ្ចូលបទចម្រៀងសម័យដើមចំនួន៧២បទ ព្រោះវាអាចជួយពន្យល់ប្រវត្តិសាស្ត្រកាន់តែមានភាពងាយស្រួលដល់សាធារណជន ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវធ្វើការសិក្សា ស្វែងយល់បន្ថែម។

**ហូ ថុនា**

# ជោគវាសនានិស្សិតកម្ពុជាដែលបានទៅសិក្សានៅប្រទេសជប៉ុន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

***ខៀវ សាគួរ***

*យោងតាមសំណុំបែបបទដាក់ពាក្យប្រលងចូលរៀន នៅសាកលវិទ្យាល័យព្រះពុទ្ធសាសនា។ ប្រហែលជា សាគួរ មកដល់ប្រទេសជប៉ុននៅក្នុងឆ្នាំ១៩៧១ ឬមុននេះដែលបាន ទទួលការឧបត្ថម្ភ ដោយស្ថាប័នពុទ្ធសាសនិកជប៉ុន វត្តអារាម ឬព្រះសង្ឃផ្ទាល់។ ដោយមិនដឹងថាតើ សាគួ ទំនាក់ទំនង ជាមួយពុទ្ធសាសនិកជនជាតិជប៉ុនក្នុងប្រទេសកម្ពុជា ដូចម្តេច អាចធ្វើឲ្យគាត់មានឱកាសបានទៅសិក្សានៅប្រទេសជប៉ុន។ គាត់អាចនិយាយភាសាជប៉ុនបានយ៉ាងល្អ ហើយគាត់ក៏ចេះ ភាសាអង់គ្លេសផងដែរ។ បន្ទាប់ពី សាគួរ បានបញ្ចប់ការ សិក្សាពីសាកលវិទ្យាល័យមួយនាទីក្រុងក្យូតូ គាត់បានចាប់ ផ្តើមបន្តការសិក្សាបន្ថែមទៀត។ សាគួរ បានចាប់ផ្តើមធ្វើការ ជាជំនួយការរបស់លោកសាស្ត្រាចារ្យ សាកាមូតូ នៃសាកល វិទ្យាល័យតូក្យូ សិក្សាពីកិច្ចការបរទេសសម្រាប់ការសិក្សា ភាសាខ្មែរ ប៉ុន្តែភាសាខ្មែរមិនទាន់បានបញ្ចូលក្នុងកម្មវិធីសិក្សា នៅឡើយទេ (សាកាមូតូ ជាអ្នកឯកទេសជនជាតិថៃ) ហើយ ប្រាក់ចំណូលរបស់គាត់គ្មានភាពឋិតថេរឡើយ។ វាហាក់បី ដូចជាគាត់មានក្តីសុបិន្តមួយចង់ក្លាយជាគ្រូបង្រៀនម្នាក់ ក្នុង វិទ្យាស្ថាន ឬសាកលវិទ្យាល័យព្រះពុទ្ធសាសនាមួយប៉ុន្តែ ក្នុង នាមជាជនបរទេសវាហាក់បីដូចជាលំបាកខ្លាំងណាស់ក្នុងការ ទទួលបានការងារសមរម្យមួយក្នុងប្រទេសជប៉ុន នៅពេល នោះ។*

***ឡៅ ស្រេង***

*នៅក្នុងឆ្នាំ១៩៧៤ ឡៅ ស្រេង ត្រូវបានបញ្ជូនពីប្រទេស កម្ពុជាទៅសិក្សានៅប្រទេសជប៉ុន ក្រោមការឧបត្ថម្ភរបស់ រាជរដ្ឋាភិបាលជប៉ុនដល់និស្សិតបរទេស។ គាត់ធ្លាប់សិក្សា មុខវិជ្ជាវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបម្រើការងារនៅក្នុងក្រសួង ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។ ស្រេងមានបំណងចង់បន្តការ សិក្សាផ្នែកសេដ្ឋកិច្ច នៅសាកលវិទ្យាល័យយូកូហាម៉ា ក្នុង ប្រទេសជប៉ុន។ គាត់បានទទួលរងឥទ្ធិពលពីរបបសង្គមនិយម*


花園大学受験票
46年度
※推
受験番号 97
志望学科 文学部 仏教学科
ふりがな 氏名 きゆうさくおう 貴友作桜
受験科目 外国語, 国語 社会 (1 科目選択) 日本史・世界史B・倫理社会

*ខៀវ សាគួរ*

ហើយគាត់បានយកសៀវភៅមួយចំនួនមកជាមួយនិពន្ធដោយ ហ៊ូ យន់ និង ខៀវ សំផន និយាយអំពីអ្នកសេដ្ឋកិច្ចសង្គមនិយម។ ស្រេង បានទទួលការឧបត្ថម្ភដោយ មុមបូហ្ស និងបានចូលរួមវគ្គហ្វឹកហាត់ជប៉ុនអស់រយៈពេល៣ខែនៅអូសាកា។ គាត់អាចនិយាយភាសាបារាំង និងអាចនិយាយភាសាជប៉ុនបានតិចៗ មូលហេតុនេះបានធ្វើឲ្យគាត់ពិបាកក្នុងការទំនាក់ទំនងជាមួយ មនុស្សនៅក្នុងប្រទេសជប៉ុន ហើយថែមទាំងមានអារម្មណ៍ថាឯកា។

គាត់មានប្រពន្ធ និងកូនម្នាក់ដូចច្នេះគាត់ចង់ត្រឡប់មកប្រទេសកម្ពុជាវិញ។ (ប្រពន្ធ និងកូនរបស់គាត់នៅរស់រានមានជីវិតពីរបបខ្មែរក្រហម ហើយរស់នៅក្នុងប្រទេសកម្ពុជា)។

**សុក ធីម**



ខៀវ សាគួរ និង មិត្តភ័ក្តិ



រូប ឈរកណ្តាលជួរខាងក្រោយ ខៀវ សាគួរ និង មិត្តភ័ក្តិ

យោងតាមសំណុំឯកសារបញ្ចប់ការសិក្សា។ ធីម កើតនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៥៣ នៅស្រុកសំរោង (ខេត្តតាកែវ)។

មិត្តរួមថ្នាក់របស់ គីម បានឲ្យដឹងថា គាត់មានជំងឺធ្លាក់ទឹកចិត្ត និងនឹកស្រុកកំណើតយ៉ាងខ្លាំងព្រោះប្រទេសជប៉ុនជាប្រទេសអភិវឌ្ឍនិងរីសអើង។ វាពិតជាលំបាកណាស់សម្រាប់គាត់ចំពោះការសម្របខ្លួនទៅនិងសង្គមជប៉ុន។ មិត្តភ័ក្តិមួយចំនួនរបស់ គីម បានព្យាយាមឃាត់គាត់មិនឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ ប៉ុន្តែ គាត់បានបោះបង់ចោលវគ្គសិក្សាថ្នាក់អនុបណ្ឌិត នៅសាកលវិទ្យាល័យយូកូហាម៉ានៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ហើយបានចាកចេញមកប្រទេសកម្ពុជា។

គាត់បានត្រឡប់មកប្រទេសកម្ពុជា ដោយឆ្លងកាត់ទីក្រុងប៉េកាំង។ គាត់បានធ្វើដំណើរតាមរយៈជើងហោះហើរចុងក្រោយមកទីក្រុងភ្នំពេញ មុនពេលដែលវៀតណាមចូលមកដល់។ គាត់បានរក្សាអត្តសញ្ញាណប័ណ្ណរបស់គាត់ពីសា-

កលវិទ្យាល័យយូកូហាម៉ាក្នុងប្រទេសជប៉ុន និងវិក្កយបត្រគាត់ស៊ីនៅទីក្រុងប៉េកាំង។ ២សប្តាហ៍បន្ទាប់ពីគាត់បានមកដល់ទីក្រុងភ្នំពេញ កងទ័ពវៀតណាមបានវាយចូលប្រទេសកម្ពុជា នៅខែធ្នូ ឆ្នាំ១៩៧៨។ គាត់បានជម្លៀសទៅខេត្តបាត់ដំបង ជាកន្លែងដែលគាត់មិនធ្លាប់បានទៅពីមុន។ គាត់មិនបានសួរអ្នកស្រុកថា ត្រូវធ្វើអ្វីនោះទេគ្រាន់តែបន្តដំណើរទៅមុខទៅកាន់ព្រំដែនថៃ ជាកន្លែងដែលគាត់ត្រូវបានចាប់ខ្លួនដោយវៀតណាម។ ដោយសារតែប័ណ្ណសម្គាល់ខ្លួនពីប្រទេសជប៉ុន និងវិក្កយបត្រគាត់ស៊ីពីទីក្រុងប៉េកាំង។ គាត់ត្រូវបានចាប់ខ្លួន ក្រោមការសង្ស័យថា ជាអ្នកស៊ើបការណ៍ ហើយត្រូវបានបញ្ជូនមកទីក្រុងភ្នំពេញវិញ។ គាត់បានជាប់គុកអស់រយៈពេលជាច្រើនឆ្នាំ។គាត់ត្រូវបញ្ជូនទៅប្រទេសវៀតណាម ហើយបានជាប់គុកនៅទីនោះអស់រយៈពេលច្រើនជាង ៧ឆ្នាំទៀត ហើយចុងក្រោយត្រូវបានដោះលែងនៅពេលដែលការកាន់កាប់របស់វៀតណាម នៅក្នុងប្រទេសកម្ពុជាបានបញ្ចប់។ គាត់បានត្រឡប់មកទីក្រុងភ្នំពេញវិញ ហើយត្រូវបានមជ្ឈមណ្ឌលស្ម័គ្រចិត្តរបស់ជប៉ុនឲ្យចូលបម្រើការសម្រាប់ជំនាញវិស្វកម្មរបស់គាត់ និងបានក្លាយជានាយកសាលាវិស្វកម្មនៅកម្ពុជា។

សុក ធីម ទទួលមរណៈភាពនៅពាក់កណ្តាល ឆ្នាំ២០១៣។ គាត់មានជំងឺថ្លើម និងទឹកនោមផ្អែម។

## ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ

នៅក្នុងឆ្នាំ១៩៧៦ គណៈប្រតិភូក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើដំណើរមកប្រទេសជប៉ុន ដើម្បីជួបប្រជាជនកម្ពុជាដែលរស់នៅក្នុងប្រទេសជប៉ុន។ គណៈប្រតិភូបានអំពាវនាវទៅកាន់និស្សិតវ័យក្មេងកម្ពុជាក្នុងប្រទេសជប៉ុនឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីរួមគ្នាកសាងប្រទេសឡើងវិញបន្ទាប់ពីបញ្ចប់ការសិក្សា។ (ហេតុការណ៍នេះបានកើតឡើងដូចគ្នានៅក្នុងប្រទេសបារាំងផងដែរ)។

មានការសន្មតថាការកិច្ចប្រជុំនេះបានធ្វើឲ្យ ឡៅ ស្រេង មានការចាប់អារម្មណ៍យ៉ាងខ្លាំង។ គាត់តែងតែចង់វិលត្រឡប់មកប្រទេសកម្ពុជាវិញ ដោយសារគាត់មើលមិនឃើញពីអនាគតអ្វីឡើយ សម្រាប់គាត់នៅក្នុងប្រទេសជប៉ុន។ ក្នុងនាមជាមិត្តភ័ក្តិសិក្សាជំនាន់ជាមួយគ្នា ឡៅ ស្រេង និងខៀវ សាគួរ ដែលមានអារម្មណ៍តប់ប្រមល់ និងគ្មានការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា បានយល់ព្រមជាមួយគំនិតដ៏ឆ្លាតមួយ «ត្រឡប់ទៅមាតុភូមិ និងកសាងប្រទេសជាតិឡើងវិញ»។

គ្មានភស្តុតាងណាមួយបញ្ជាក់ច្បាស់ ពីផែនការដែលអ្នកទាំងពីរនាក់នេះវិលត្រឡប់មកប្រទេសកម្ពុជាវិញជាមួយលិខិតឆ្លងដែនដែលចេញដោយរដ្ឋាភិបាល លន់ នល់ ឡើយ និងថាតើអ្នកទាំងពីរទទួលបានទិដ្ឋាការឬធ្វើដំណើរមកប្រទេសកម្ពុជា ដោយឆ្លងកាត់ទីក្រុងបេកាំងយ៉ាងដូចម្តេច។

ខៀវ សាគួរ អាយុ៣២ឆ្នាំ ត្រូវបានកត់ត្រាចូលក្នុងបញ្ជីអ្នកទោសនៅពេលដែលគាត់ចូលមកទួលស្លែង នៅថ្ងៃទី៨ខែធ្នូឆ្នាំ១៩៧៦។

ឡៅ ស្រេង អាយុ២៩ឆ្នាំ បានកត់ត្រាក្នុងបញ្ជីអ្នកទោសពេលដែលគាត់ចូលមកទួលស្លែងនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦។ គ្មានចម្លើយសារភាពណាមួយបានកត់ត្រាឡើយ។ អ្នកទាំងពីរត្រូវបានសម្គាល់ថា «មកពីប្រទេសជប៉ុន»។

**គូលីន គ្រាសគុន**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូប ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួននឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសព្ទលេខ (៨៥៥) (១២) ៩៩៦៧៥០
ទូរសព្ទលេខ (៨៥៥) (២៣) ២១០ ៣៥៨
Email: truthbunthorn.s@dccam.org
Home Page: www.d.dccam.org

# សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង០០២

នៅអំឡុងដំណើរការក្តីសំណុំរឿង០០២ ទាក់ទងជនជាប់ចោទ នួន ជា និង ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យគ្រប់ភាគីក្តីដែលពាក់ព័ន្ធ ដាក់សារណារៀងៗខ្លួនដើម្បីធ្វើការពិភាក្សាដេញដោល។ សហព្រះរាជអាជ្ញាក៏បានដាក់សារណាភ្ជាប់ជាមួយភស្តុតាងទាក់ទងនឹងជនជាប់ចោទទាំងពីរ រួមមានបទសម្ភាសន៍ លិខិតឆ្លើយឆ្លង ទស្សនាវដ្តីទង់បដិវត្តន៍ តួរលេខជនរងគ្រោះ និងឯកសារពាក់ព័ន្ធនានា ដែលបានសង្ខេបដូចខាងក្រោម៖

១.) *ទិដ្ឋភាពទូទៅអំពីភស្តុតាង*

*ខៀវ សំផន*

ចលនាជ្រុលហួសមួយដែលប្រព្រឹត្តអំពើហិង្សាខ្លាំងក្លាលើសពីចលនាបដិវត្តន៍ ដែលមនុស្សធ្លាប់ស្គាល់ជាហូរហែនៅក្នុងសកលលោក បណ្តាលឲ្យស្លាប់បាត់បង់ជីវិតមនុស្ស និងឈឺចាប់ខ្លោចផ្សារកទីបំផុតគ្មាន។

*នួន ជា*

បើទុកពួកហ្នឹង អាហ្នឹងសម្រាប់ជាតិ ផ្ទាល់វាតែងតែមានមនោសញ្ចេតនាអ៊ីខ្លះ។ ខ្ញុំយកជាតិហើយ ឯផ្ទាល់ខ្លួនទុកដោយឡែកសិន។

*សំណួរ៖ ចឹងអ៊ំមានការសោកស្តាយចំពោះអ្នកទាំងនោះទេ?*



នួន ជា

ឆ្លើយ៖ ខ្ញុំដូចជាគ្មានការសោកស្តាយទេ

ជនជាប់ចោទនៅក្នុងរឿងក្តីនេះគឺ នួន ជា «បងធំទី២» និង ខៀវ សំផន «ជាប្រធានរដ្ឋនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិតេយ្យ» បានស្វែងរកគ្រប់វិធី ដើម្បីគេចវេះពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់របបនេះ។ អ្នកទាំងពីរនិយាយឲ្យចំ នួន ជា បានអះអាងថា ការសម្លាប់ក្រៅអំណាចតុលាការ គឺជារឿងចាំបាច់ដើម្បីការពារប្រទេសពីខ្មាំងបរទេស ដូច្នេះវាជារឿងត្រឹមត្រូវ។ ចំណែក ខៀវ សំផន បានអះអាងថា គាត់មិនបានដឹងពីអ្វីដែលបានកំពុងកើតឡើងចំពោះប្រជាជនកម្ពុជាទេ ហើយគាត់ក៏គ្មានអំណាចដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះដែរ។ ប៉ុន្តែភស្តុតាងបានបង្ហាញថា នួន ជា និង ខៀវ សំផន សុទ្ធតែមានតួនាទីសំខាន់បំផុតក្នុងការឃោសនាឲ្យមានឧក្រិដ្ឋកម្ម។ អ្នកទាំងពីរនាក់ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ ប៉ុល ពត ដែលជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា (បកក) និងស្ថិតនៅក្នុងចំណោមក្រុមតូចមួយនៃមេដឹកនាំដែលបានចូលរួមប្រើប្រាស់គោលនយោបាយឧក្រិដ្ឋកម្មដើម្បីរក្សាអំណាចរបស់ខ្លួន និងលាក់កំបាំងភាពបរាជ័យនៃអភិបាលកិច្ចរបស់ខ្លួន។ អ្នកទាំងអស់នេះបានធ្វើអ្វីៗគ្រប់យ៉ាងដើម្បីទម្លាក់ប្រជាជនកម្ពុជាទៅក្នុងសង្គមមួយដែលគ្មានសាសនា និងគ្មានវណ្ណៈ។ ដើម្បីពន្លឿនដល់កម្មវិធីគោលនយោបាយ របបនេះបានប្រឌិតឡើងនូវនយោបាយឧក្រិដ្ឋនានាដែលត្រូវបានអនុវត្តនៅទូទាំងប្រទេស។ របបនេះបានចាប់ផ្សឹកព្រះសង្ឃ ធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនានិកជន និងបានហាមឃាត់ការប្រត្តិបត្តិសាសនាទាំងអស់។ ទីក្រុងនានាត្រូវបានរបបនេះបោសសម្អាតយ៉ាងស្ងាត់ជ្រងំ ហើយអ្នកដែលរស់នៅទីក្រុងទាំងនោះត្រូវបាន បង្ខំឲ្យផ្លាស់ទីលំនៅទៅរស់នៅតាមជនបទ។ ប្រជាជនភាគច្រើនត្រូវបានបញ្ជូនឲ្យទៅធ្វើពលកម្មនៅតាមការដ្ឋាន និងសហករណ៍នៅក្រោមលក្ខខណ្ឌនានា ដែលមានតម្លៃស្មើនឹងការធ្វើឲ្យទៅជាទាសករ។ ប្រជាជនធម្មតាធ្វើការដោយគ្មានប្រាក់កម្រៃ ហើយត្រូវបានរបបនេះផ្តល់អាហារ ការថែទាំអនាម័យ និងថែទាំងវេជ្ជសាស្ត្រមិនគ្រប់គ្រាន់។ កម្មករទាំងនេះត្រូវបានរបបនេះបង្ខំឲ្យហូបរួមបដិសេធសេរីភាពក្នុងការនិយាយស្តី និងការធ្វើដំណើរ។ របបនេះបានបង្ខំឲ្យរៀបការជាមួយប្តី ឬប្រពន្ធដែលត្រូវបានជ្រើសរើសដោយកម្មាភិបាលខ្មែរក្រហម និងត្រូវបានបង្ខំឲ្យធ្វើទំនាក់ទំនងផ្លូវភេទ ដើម្បីបង្កើតកូនឲ្យរបបនេះ។

ប្រសិនបើនរណាម្នាក់ត្រូវបានរបបនេះមើលឃើញថាជាបន្ទុកនោះនឹងត្រូវសម្លាប់ចោលភ្លាម។ មនុស្សទាំងអស់ដែលរបបនេះគិតថា ជាអ្នកប្រឆាំងបានកំណត់គោលដៅសម្រាប់បង្កើតការតាមដាន និងការធ្វើទុក្ខបុកម្នេញ ហើយមនុស្សក្នុងជំពូកជាច្រើនទៀតរួមទាំងវៀតណាមនិងចាមត្រូវបានរបបនេះកំណត់គោលដៅសម្រាប់ការលុបបំបាត់ចោលទាំងស្រុង។

ភស្តុតាងលម្អិតនៅក្នុងសារណានេះ បានបង្ហាញថា ខៀវ សំផន និង នួន ជា បានធ្វើការជារៀងរាល់ថ្ងៃជាមួយ ប៉ុល ពត។ ខៀវ សំផន នួន ជា និង ប៉ុល ពត បានធ្វើដំណើរទូទាំងប្រទេសដូចដែលបានបញ្ជាក់តាមរយៈកំណត់ហេតុរបស់ពួកគេ ដែលបានដឹងអំពីយុទ្ធនាការមហាឃាតកម្មប្រឆាំង «ខ្មាំង»របស់របបនេះ។ អ្នកទាំងនេះបានដើរតួនាទីជាគន្លឹះនៅក្នុងយុទ្ធនាការឧក្រិដ្ឋកម្ម។

នៅក្នុងបទសម្ភាសន៍ជាច្រើន មុនពេលសវនាការនេះបានចាប់ផ្តើម នួន ជា បានទទួលស្គាល់ថា គាត់គឺជាមេដឹកនាំទីពីរក្នុងរបបនេះ និងបានគាំទ្រចំពោះគោលនយោបាយទាំងអស់របស់ខ្លួន។ គាត់បានការពារគោលនយោបាយធ្វើទារុណកម្ម និងសម្លាប់របស់របបនេះថា ជារឿងត្រឹមត្រូវដោយសារខ្មាមកម្មផ្ទៃក្នុង។ នៅក្នុងការដាក់សារណាច្បាប់នៅកំឡុងពេលនៃសវនាការ គាត់បានអះអាងថា ការធ្វើទារុណកម្មមិនមែនជាឧក្រិដ្ឋកម្មអន្តរជាតិទេនៅឆ្នាំ១៩៧៥ និងថាការសម្លាប់ក្រៅអំណាចតុលាការ គឺអនុញ្ញាតឲ្យធ្វើទៅបានដោយសាររបបនេះមាន«ការសង្ស័យ»ថា ជនទាំងនេះ គឺជាការគំរាមកំហែង«ការផ្តន្ទាទោសប្រហារជីវិត» មិនមែនជាការប្រឆាំងនឹងច្បាប់អន្តរជាតិឡើយ។ ទឡ្ហីករណ៍គតិយុត្តរបស់

គាត់មិនអាចការពារបាន ហើយទឡ្ហីករណ៍គតិយុត្តរបស់គាត់ក៏មិនមានភស្តុតាងគាំទ្រដែរ។

ច្បាប់អន្តរជាតិ មិនអនុញ្ញាតឲ្យមានការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ឬការសម្លាប់ក្រៅអំណាចតុលាការទេ សូម្បីតែគិញដែលចាប់បានគ្មានឯកសណ្ឋាន ក៏នៅមានសិទ្ធិទទួលបានការជំនុំជម្រះក្តីដែរ។ រដ្ឋាភិបាលមិនអាចសម្លាប់អ្នកប្រឆាំង ឬអ្នករិះគន់ខ្លួន ដោយគ្មានដំណើរការតុលាការឡើយ។ ខ្មែរក្រហមបានចាប់ខ្លួន និងសម្លាប់មនុស្សដោយគ្មានដំណើរការផ្លូវច្បាប់គ្មានតុលាការ ហើយក៏មិនខ្វល់ពីការធ្វើច្បាប់ព្រហ្មទណ្ឌដែរ។ ការសម្លាប់នៅក្នុងប្រព័ន្ធឥតច្បាប់ដូច្នេះ ត្រូវបានហៅយ៉ាងសាមញ្ញថាជាអំពើមនុស្សឃាត។

លើសពីនេះ គ្មានអ្វីសោះនៅក្នុងភស្តុតាងគាំទ្រដល់ការអះអាងរបស់ នួន ជា ដែលថា មនុស្សរាប់ពាន់នាក់ដែលគាត់ស្គាល់ថា ត្រូវបានសម្លាប់ក្រៅប្រព័ន្ធតុលាការ ដោយរបបនេះបានរួមគំនិតគ្នាជាមួយជនបរទេស ដើម្បី ផ្តួលរំលំ ប៉ុល ពត។ ផ្ទុយទៅវិញ ភស្តុតាងនៅក្នុងសវនាការ នេះរួមទាំងកំណត់ហេតុរបស់ នួន ជា ខ្លួនឯងផ្ទាល់បានបង្ហាញថាវាជារោគឆ្កួតដែលចេះតែភ័យខ្លាចអ្វីៗជុំវិញខ្លួន និងភាពគ្មានមេត្តារបស់ថ្នាក់ដឹកនាំ ដែលនាំឲ្យមានការសម្លាប់ជនស្លូតត្រង់កម្ពុជាយ៉ាងរង្គាល។ មិនត្រឹមតែមានការចាប់ខ្លួនមនុស្សដោយគ្មានភ័ត្តុតាង និងសច្ចធារណ៍នៃនិរទោសប៉ុណ្ណោះទេ ថែមទាំង «ខ្សែ» រយៈរបស់ពួកគាត់ដែរ ដូចដែល នួន ជា បានប្រើពាក្យថា សាញ់ញាតិ ឬមនុស្សស្គាល់គ្នារបស់ជនណាម្នាក់ដែលគេសង្ស័យ ក៏បានជួបនឹងវាសនាស្រដៀងគ្នានេះដែរ។

## ការធ្វើឲ្យប្រជាជនក្លាយជាទាសករ

នៅក្នុងសហករណ៍ ប្រជាជនមិនមានសេរីភាពទេ

- ខៀវ សំផន

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើ «ការធ្វើឲ្យទៅ ជាទាសករ» ត្រូវបានប្រព្រឹត្តនៅពេលដែលចារីម្នាក់អនុវត្តអំណាចណាមួយ ឬទាំងអស់ដែលភ្ជាប់ទៅនឹងសិទ្ធិជាកម្មសិទ្ធិទៅលើមនុស្សម្នាក់ ឬមនុស្សច្រើននាក់។ ពលរដ្ឋកម្ពុជារាប់លាននាក់ត្រូវបានគេប្រើប្រាស់ជាបាវបម្រើដល់របបនេះ និងបោះបង់ចោលនៅពេលណាគេគិតថាលែងមានគុណសម្បត្តិដល់ម្ចាស់ «អង្គការ» ឬបក្ស។ នេះគឺជាអភិបាលកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ ដែលរឿងផ្ទាល់ខ្លួនត្រូវតែ«ទុកមួយឡែកសិន» ដូច នួន ជា បាននិយាយ។

មនុស្សរាប់លាននាក់ ត្រូវបានរបបនេះបង្ខំឲ្យធ្វើពលកម្មច្រើនម៉ោង នៅតាមសហករណ៍ និងការដ្ឋានជាទីកន្លែងដែលអ្នកទាំងនោះធ្វើការដោយគ្មានប្រាក់កម្រៃ និងនៅក្រោមលក្ខខណ្ឌអមនុស្សធម៌។ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ត្រូវបាន ខៀវ សំផន យាងចុះសួរសុខទុក្ខនៅតំបន់ជនបទនៅចន្លោះខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ខែមេសា ឆ្នាំ១៩៧៦ និងដោយផ្អែកលើលក្ខខណ្ឌដ៏យង់ឃ្នង ដែលបានដាក់ទៅលើប្រជាជន ព្រះបរមរតនកោដ្ឋបានមានព្រះរាជបន្ទូលថា «ជំរំប្រមូលផ្តុំ»។ ដូចបានរៀបរាប់យ៉ាងលម្អិតខាងក្រោមនៅក្នុងវគ្គសវនាការ ស្តីពីសហករណ៍ និងការដ្ឋានគឺកម្មករជាញឹកញាប់ ទទួលទានអាហារមិនគ្រប់គ្រាន់ការស្នាក់នៅជាមូលដ្ឋានអនាម័យនិងការថែទាំវេជ្ជសាស្ត្រត្រូវបានបដិសេធ ហើយធ្វើឲ្យមនុស្សជាច្រើនស្លាប់។ ខណៈដែលមេដឹកនាំសង្ឃឹមថា នឹងសម្រេចបាននូវភាពរុងរឿង ដោយការជួសជុលឡើងវិញភាពថ្កុំថ្កើងតាមរយៈបដិវត្តន៍ជ្រុលនិយមនោះ មេដឹកនាំទាំងនេះមិនខ្វល់ខ្វាយពីការឈឺចាប់ដែលគោលនយោបាយរបស់ខ្លួនបានធ្វើទៅលើប្រជាជនកម្ពុជាធម្មតានោះទេ។ មានតែមេដឹកនាំថ្នាក់កំពូលប៉ុណ្ណោះ ដែលត្រូវបានរបបនេះយកចិត្តទុកដាក់ ចំណែកអ្នកផ្សេងទៀតត្រូវបានរបបនេះចាត់ទុកថា បូជាសម្រាប់បដិវត្តន៍។

ខ្មែរក្រហម បានអនុវត្តអំណាចនៃកម្មសិទ្ធិបន្ថែមទៀត ទៅលើបុគ្គលម្នាក់ៗតាមរយៈបដិសេធសិទ្ធិជាមូលដ្ឋាន។ របបនេះបានបំបែកបំបាក់កូនៗពីឪពុកម្តាយ និងប្តីប្រពន្ធ ដោយបង្ខំ បដិសេធសិទ្ធិជាមូលដ្ឋានក្នុងការរស់នៅជាមួយក្រុមគ្រួសារ។ អ្នកណាដែលហ៊ានរិះគន់របបនេះប្រថុយនឹងការ


សាធារណជនចូលរួមស្តាប់សាវនាការ សាលាក្តីខ្មែរក្រហម

ផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរឬក៏សម្លាប់ៗ នៅក្នុងសំណេររបស់គាត់ ខៀវ សំផន បានទទួលស្គាល់ថារបប «ផ្តាច់ការមិនត្រាប្រណី ចំពោះសំណួរណាមួយសូម្បីតែសំណួរនោះមិនធ្វើឲ្យប៉ះពាល់ ក៏ដោយអំពីសាភាពចរណែនាំរបស់អង្គការ» ហើយក៏មិនអនុ-ញ្ញាតឲ្យមានឯករាជ្យភាពនៃគំនិតណាមួយទាំងអស់ៗ ប្រជា-ជនកម្ពុជាមិនអាចរស់នៅ ឬធ្វើដំណើរទៅទីកន្លែងណាមួយ តាមបំណងប្រាថ្នារបស់ខ្លួនឡើយៗ មនុស្សរាប់លាននាក់ត្រូវ បានបង្ខំឲ្យផ្លាស់ទីលំនៅ ហើយលិខិតដើរផ្លូវចាំបាច់ត្រូវមាន ដើម្បីធ្វើដំណើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយៗ ប្រជាជន ត្រូវបានរបបនេះហាមឃាត់ពីការប្រត្តិបត្តិសាសនារបស់ខ្លួន ប្រាប់អំពីរបៀបស្លៀកពាក់ពីពេលវេលា និងអ្វីដែលត្រូវហូប ចុកៗ

របបនេះសូម្បីតែសិទ្ធិធ្វើទំនាក់ទំនងជាមួយក្រុមគ្រួសារ ធម្មតា ក៏ត្រូវបដិសេធៗ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ បានរំឭករឿងរ៉ាវឡើងវិញរបស់ព្រះអង្គថា កម្ពុជាប្រជាធិប-តេយ្យបានបង្ខំងព្រះអង្គនៅក្នុងព្រះរាជដំណាក់របស់ព្រះអង្គ សំណើររបស់ព្រះអង្គសុំកូនចៅរបស់ព្រះអង្គមកសួរសុខទុក្ខ ក្នុងថ្ងៃចម្រើនព្រះជន្ម ត្រូវបានបដិសេធដោយ ខៀវ សំផន ដែលបានប្រាប់ព្រះអង្គថា៖

សូមកុំឲ្យមានជីវិតគ្រួសារតទៅទៀត ព្រោះឥឡូវ គឺ កុម្មុយនីស្តថ្មីរបស់យើងៗ យើងត្រូវគិតពីប្រទេសយើង ពី មាតុភូមិយើងតែមួយគត់ៗ គ្មានជីវិតគ្រួសារទៀតទេៗ

## កម្មវិធីបង្កើតបរិមាណប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ

- នួន ជា៖

ប្រុសៗតែងតែចង់ជ្រើសរើសយកស្រីស្អាត ហេតុនេះ ហើយបានជាយើងបង្ខំប្រុសៗឲ្យរៀបការ ហើយអង្គការជា អ្នករើសប្រពន្ធឲ្យមេដឹកនាំខ្មែរក្រហមបានស្វែងរកការបង្កើត

ចំនួនប្រជាជនកម្ពុជាយ៉ាងរហ័សតាមរយៈការចាត់ចែងរៀបការឲ្យប្រជាជន ដោយគ្មានការយល់ព្រមរបស់សាម៉ីខ្លួន។ គូស្រករដែលជាញឹកញាប់ សូម្បីតែស្គាល់គ្នាពីមុនមកក៏មិនដែលផងនោះ ត្រូវបានគេបង្ខំឲ្យរៀបការ និងរួមសង្វាសជាមួយគ្នាប្រឆាំងនឹងឆន្ទៈរបស់ខ្លួន។

ទាំង នួន ជា និង ខៀវ សំផន សុទ្ធតែបានជួយលើកកម្ពស់គោលនយោបាយនេះ ដោយបានសង្កត់ធ្ងន់ដល់កម្មាភិបាលនានា អំពីភាពចាំបាច់នៃកំណើតប្រជាជនឆាប់រហ័ស ក្នុងខណៈដែលការពិត គ្រោះទុរ្ភិក្ស និងការសម្លាប់ដែលបានធ្វើឡើងដោយខ្មែរក្រហម បានបណ្តាលឲ្យមានការថយចុះចំនួនប្រជាជនយ៉ាងឆាប់រហ័ស។ នួន ជា បាននិយាយនៅក្នុងបទសម្ភាសន៍នៅក្នុងប្រទេសចិនថា កម្ពុជាប្រជាធិបតេយ្យ «កំពុងតែអនុវត្តគោលនយោបាយមួយក្នុងការបង្កើតចំនួនប្រជាជនរបស់ខ្លួន» និងថាខណៈដែលចំនួនប្រជាជនត្រូវបានប៉ាន់ប្រមាណថា មានចំនួន៧,៧៦០,០០០នាក់ ក្នុងឆ្នាំ១៩៧១ ផែនការបួនឆ្នាំ(១៩៧៧-១៩៨០) មានគោលបំណងបង្កើនចំនួនប្រជាជនរបស់យើងឲ្យបានច្រើន ហើយយ៉ាងតិច១៥,០០០,០០០ នាក់ក្នុងរយៈពេល ៥ ទៅ ១០ឆ្នាំ»។

នៅក្នុងសំណេររបស់ ខៀវ សំផន បានទទួលស្គាល់ថា គោលបំណងរបស់ ប៉ុល ពត គឺដើម្បីបង្កើនចំនួនប្រជាជនកម្ពុជាតាមរយៈកត្តាពីរឬបី ក្នុងរយៈពេល១០ឆ្នាំ។ ខៀវ សំផន បានធ្វើការផ្សារនេះយ៉ាងសកម្មដើម្បីលើកកម្ពស់គោលនយោបាយនេះ។ ក្នុងឆ្នាំ១៩៧៨ ប៉ុល ពត បាននិយាយទៅកាន់មនុស្ស២០,០០០នាក់ រួមមានទាំងតំណាងកងទ័ពបដិវត្តន៍កម្ពុជាផង ដើម្បីប្រារព្ធពិធីជ័យជម្នះ ១៧ មេសា ដោយបានស្នើឲ្យកម្មាភិបាល«ស្វែងយល់ឲ្យបានជ្រួតជ្រាប និងអនុវត្តឲ្យបានល្អនូវផែនការ បង្កើតបរិមាណប្រជាជនឲ្យដល់កម្រិតអតិបរមារបស់ខ្លួនដើម្បីសម្រេចតាមគោលដៅឲ្យមានប្រជាជនចំនួនពី ១៥ ទៅ ២០ លាននាក់នៅក្នុងរយៈពេលពី ១០ ទៅ ១៥ឆ្នាំខាងមុខ» និង «ស្វែងយល់ឲ្យបានជ្រួតជ្រាប និងអនុវត្តឲ្យបានល្អនូវផែនការបង្កើតបរិមាណប្រជាជនសម្រាប់រយៈពេល១ឆ្នាំ ៣ឆ្នាំ ៥ឆ្នាំ និង ១៥ឆ្នាំ។

ជាទូទៅ ដោយសារបរិស្ថានបង្ខិតបង្ខំដ៏ធំធេងដែលបានបង្កើតឡើងដោយខ្មែរក្រហម បានធ្វើឲ្យអ្នកទាំងឡាយដែលរបបនេះ បានជ្រើសរើសឲ្យរៀបការមិនអាចបដិសេធនឹងសេចក្តីណែនាំរបស់អង្គការឡើយ ដោយអ្នកទាំងនោះភ័យខ្លាចថាការធ្វើដូច្នេះអាចឈានទៅដល់ការបង្អត់អាហារ ការចាប់ខ្លួន ឬការសម្លាប់។ ឧទាហរណ៍ ណុប ងឹម គឺជាកម្មាភិបាលដ៏គួរឲ្យទុកចិត្តមួយរូបរបស់ខ្មែរក្រហម ដែលរបបនេះបញ្ជូនពីនិរតីមកកាន់ភូមិភាគពាយ័ព្យក្នុងឆ្នាំ១៩៧៨ ដោយតាម៉ុក។ នៅទីនោះ តាម៉ុក បានចាត់តាំងគាត់ឲ្យកាន់មុខតំណែងដ៏មានអំណាចមួយ គឺអនុលេខាស្រុកសំឡូត ប៉ុន្តែលោកស្រីនៅតែត្រូវបានបង្ខំដោយ តាម៉ុក ដដែល ដែលជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ឲ្យរៀបការជាមួយកងទ័ពពិការម្នាក់។ ណុប ងឹម បានផ្តល់សក្ខីកម្មថា នៅក្នុងពិធីរៀបការនោះ មាន៣៨គូ រៀបការក្នុងពិធីតែមួយដូចគ្នា និងមានអ្នកខ្លះយំ និងបានបន្ថែមថា៖

ខ្ញុំយំដែរហ្នឹង។ ប៉ុនអន់ចិត្តអត់ដឹងខ្លួនសោះ អន់ចិត្តៗ ម៉ាំណាស់ ព្រោះអីអត់ដែលឃើញ ប៉ុន្តែដល់តែចាប់ដាក់អីចឹង ខ្ញុំធ្លាប់អន់ចិត្ត ខ្ញុំចង់រត់ ប៉ុន្តែខ្លាចគេវ៉ៃចោល។

ណុប ងឹម មិនដែលផ្តល់សក្ខីកម្មថា គាត់ធ្លាប់ត្រូវបានរបបនេះ ព្រមានដោយផ្ទាល់អំពីផលវិបាកនៃការបដិសេធនោះទេ។ ប៉ុន្តែ នៅក្នុងរបបមួយដែលសូម្បីតែការធ្វើឲ្យបាក់ស្លាបព្រាមួយ ការខកខានមិនបានធ្វើតាមការណែនាំ ឬការរិះគន់ពីលក្ខខណ្ឌផ្សេងៗអាចនាំឲ្យស្លាប់នោះ សូម្បីតែកម្មាភិបាលថ្នាក់ខ្ពស់ប្រដំប្រសងគ្នា ក៏មិនទាំងហ៊ានបដិសេធផងនោះដោយសារតែគាត់ជឿជាក់ថាការរស់រានមានជីវិតរបស់គាត់ គឺពឹងផ្អែកលើការទទួលយកសេចក្តីសម្រេចរបស់របបនេះ។

អ្នកផ្សេងទៀតដែលរបបនេះ បានជ្រើសរើសឲ្យរៀបការត្រូវបានគំរាមដោយផ្ទាល់បើគាត់បដិសេធមិនរៀបការ ឬមិនព្រមរួមសង្វាស។ ប៉ែន សុចាន់ បានផ្តល់សក្ខីកម្មថា «ឃ្លា

*សម័យនោះ... បើមិនស្រឡាញ់គ្នា គឺមិនដេក គេសម្លាប់ក្នុងពេលហ្នឹង គេធ្វើបាបទារុណកម្ម»។* គាត់បានបញ្ជាក់បន្ថែមថា បន្ទាប់ពីគាត់មិនព្រមចុះសម្រុងនឹងបុរស ដែលគាត់ត្រូវបានបង្ខំឲ្យរៀបការជាមួយនោះ កម្មាភិបាលខ្មែរក្រហមម្នាក់បានប្រាប់ខ្ញុំថា «យប់ទី១គេកសាងខ្ញុំ យប់ទី២ឲ្យខ្ញុំរត់ទៅបានពូជួយ តែយប់ទី៣ខ្ញុំដឹងថាខ្លួនខ្ញុំពេលនេះបែកម៉ែបែកឪហើយខ្ញុំថាខ្ញុំស្លាប់ហើយ»។ ស្រដៀងគ្នានេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតបានផ្តល់សក្ខីកម្មថា នាងព្រមចុះសម្រុងជាមួយប្តីនាងដែលបានបង្ខំឲ្យរៀបការដោយអង្គការ ដោយសារតែនាងខ្លាច ដូចគាត់ពន្យល់យ៉ាងដូច្នេះថា៖

*មានប្អូនស្រីជីដូនមួយឈ្មោះ ហេង វន្នី ហៅ វឿន។ គេបង្ខិតបង្ខំឲ្យមានគ្រួសារ។ ប៉ុន្តែ វាប្រកែកអត់យកមួយលើកពីរលើក ដល់ទៅគេយកវាទៅវាយចោលទៅ។*

ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយចំពោះ «ប្រជាជនថ្មី»

ទស្សនាវដ្តីទង់បដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជា ខែមេសា ឆ្នាំ១៩៧៧ បានសរសេរ

*ត្រូវបែងចែកសមាភាពក្នុងសហករណ៍ឲ្យច្បាស់លាស់ កុំឲ្យប្របូកប្របល់ទៀតគឺ៖*

- *សមាជិកសហករណ៍ពេញសិទ្ធិ*
- *សមាជិកសហករណ៍ត្រៀម*
- *សមាជិក ផ្ញើរបស់សហករណ៍*

របបកម្ពុជាប្រជាធិបតេយ្យ បានហៅជនស៊ីវិលធម្មតាដែលរស់នៅតាមតំបន់ត្រួតត្រាដោយទាហាន លន់ នល់ ក្នុងរយៈពេលស្ទើរតែពេញមួយសង្គ្រាមថា «ប្រជាជនថ្មី» ដោយមើលប្រជាជនទាំងនេះក្នុងសេចក្តីសង្ស័យ និងបានធ្វើទុក្ខបុកម្នេញទៅលើក្រុមនេះ។ ចេតនារបស់របបនេះដែលបដិសេធសិទ្ធិស្មើគ្នារបស់ប្រជាជនថ្មី គឺត្រូវបានបង្ហាញយ៉ាងជាក់ស្ដែងតាមរយៈបញ្ញាខាងលើដែលតម្រូវឲ្យសហករណ៍កំណត់ប្រភេទសមាជិក«ពេញសិទ្ធិ»។

«ប្រជាជនថ្មី» ដែលជួនកាលគេហៅថា «ប្រជាជន ១៧ មេសា» ឬ «ប្រជាជនផ្ញើ» ជាប្រជាជនដែលរបបកម្ពុជាប្រជាធិបតេយ្យមិនទុកចិត្ត ត្រូវបានបដិសេធសិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗទៀតដែលរបបនេះបានផ្តល់ឲ្យ «ប្រជាជនមូលដ្ឋាន» ហើយទំនងជានឹងត្រូវបានចាប់ខ្លួន ឬយកទៅសម្លាប់ចោល។

**ការធ្វើទុក្ខបុកម្នេញចំពោះពុទ្ធសាសនិកជន**

- ឯកសារបក្សកុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥៖

*វត្តអារាមដែលជាបង្អែកព្រះសង្ឃត្រូវបានលះបង់ចោលជាច្រើន។ មូលដ្ឋានបង្អែករបស់ពុទ្ធសាសនាត្រូវលះបង់ចោល ប្រជាជនលែងទៅវត្តលែងធ្វើបុណ្យ...។ ដូច្នេះស្រទាប់ពិសេសនេះ មិនមានអីគួរឲ្យបានរម្កទេ។*

ពុទ្ធសាសនា បង្រៀនមនុស្សឲ្យប្រព្រឹត្តចំពោះមនុស្សគ្រប់រូបដោយក្តីសប្បុរស និងមេត្តាករុណា ព្រមទាំងមិនឲ្យសម្លាប់មនុស្សសត្វ និងប្រព្រឹត្តអំពើហិង្សាបានធ្វើឲ្យការប្រៀនប្រដៅនេះ ខុសគ្នាជាមូលដ្ឋានទៅនឹងការឃោសនារបស់ខ្មែរក្រហម ដែលបញ្ជោះឲ្យមានការស្អប់ខ្ពើមវណ្ណៈ និងអំពើហិង្សាចំពោះ«ខ្មាំង»។ ខ្មែរក្រហមប្រឆាំងចំពោះការអនុវត្តសាសនា ប៉ុន្តែបានដឹងអំពីសារសំខាន់នៃពុទ្ធសាសនានៅក្នុងវប្បធម៌ខ្មែរហើយក៏បានតាំងចិត្ត ដើម្បីបំផ្លិចបំផ្លាញពុទ្ធសាសនានៅកម្ពុជាបន្តិចម្តងៗ។ ដោយសារការប្រកាន់ខ្ជាប់ចំពោះពុទ្ធសាសនារបស់ពលរដ្ឋខ្មែរ និងសារសំខាន់របស់សាសនានៅក្នុងសង្គម និងវប្បធម៌ខ្មែររបបនេះបានព្យាយាមគេចវេះមិនទទួលស្គាល់ជាសាធារណៈ ចំពោះគោលនយោបាយនៃការបំផ្លិចបំផ្លាញរបស់ខ្លួនដោយជំនួសមកវិញនូវការព្យាយាមឃោសនាថា ប្រជាជនខ្មែរខ្លួនឯងទេ ជាអ្នកបោះបង់ចោលសាសនារបស់ខ្លួនដោយស្ម័គ្រចិត្ត។ ប៉ុន្តែភស្តុតាងនៅក្នុងសវនការនោះបានបញ្ជាក់ពីលំនាំស៊ីសង្វាក់គ្នាមួយរបស់កម្ពុជាប្រជាធិបតេយ្យ អំពីការអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ ចំពោះជនណា ដែលហ៊ានអនុវត្តពុទ្ធសាសនានៅទូទាំងប្រទេស។ ព្រះសង្ឃត្រូវបង្ខំឲ្យដោះស្បង់ចីពរ រូបសំណាកព្រះពុទ្ធត្រូវបានបំផ្លាញ វត្តត្រូវបានកម្ទេចចោល ឬ

បង្វែយកទៅធ្វើជាឃ្លាំងមន្ទីរឃុំឃាំង ឬបរិក្ខាសម្រាប់ប្រើប្រាស់ផ្សេងៗហើយបុគ្គលម្នាក់ៗ អាចអនុវត្តសាសនារបស់ខ្លួនបានតែដោយវិធីសម្ងាត់ប៉ុណ្ណោះ។

មាត្រា២០ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យចែងថា៖

«ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជឿជំនឿឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនមានជំនឿអ្វីឬក៏មិនជឿសាសនាណាក៏បាន។ មិនអនុញ្ញាតឲ្យមានសាសនាប្រតិកិរិយាដែលបំផ្លាញកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជាដាច់ខាត»។

នៅក្នុងការអនុវត្តសាសនាទាំងអស់ត្រូវបានចាត់ទុកថាប្រតិកិរិយា និងត្រូវបានលុបបំបាត់។ ពុទ្ធសាសនាត្រូវតែបំបាត់ដោយសារពួកគេយល់ឃើញថាជាស្ថានប័នសង្គម «កេងប្រវ័ញ្ច»មួយ ហើយសំខាន់ជាងនេះ ត្រូវបានមេដឹកនាំខ្មែរក្រហមមើលឃើញថា ជាអ្នកប្រកួតប្រជែងមួយ ក្នុងការដណ្តើមយកភាពស្មោះត្រង់របស់ប្រជាជនកម្ពុជា។ យុន យ៉ាត រដ្ឋមន្ត្រីក្រសួងឃោសនាការបានប្រាប់អ្នកការសែតយូហ្គោស្លាវី ក្នុងកំឡុងទស្សនកិច្ចក្នុងឆ្នាំ១៩៧៨ ថា «ព្រះពុទ្ធសាសនា មិនត្រូវធាតុជាមួយនឹងបដិវត្តន៍ទេ»។

## អំពើប្រល័យពូជសាសន៍ចាម

- ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀម

ក្នុងឆ្នាំ៧៧ ហ្នឹងវិធានការមួយមកពីតំបន់ អីចឹងថាឲ្យរៀបចំការបោសសម្អាតចាម។ អីចឹងខ្ញុំក៏ចាប់អារម្មណ៍ដែរថា យ៉ាងម៉េចបានបោសសម្អាតចាម ឆ្ងល់...។ តែផែនការនេះ ដាក់មកលើខ្ញុំក៏បេះតែអនុវត្តតាមផែនការទៅ។



ខៀវ សំផន



នួន ជា

មេដឹកនាំ កម្ពុជាប្រជាធិបតេយ្យបានបដិសេធក្នុងការទទួលស្គាល់ឬគ្រាប្រណីចំពោះភាពចម្រុះនៃប្រជាជនកម្ពុជា។ នៅក្នុងការបោះពុម្ពផ្សាយឃោសនាមួយ ពួកគេបាននិយាយថា ប្រជាជនកម្ពុជា៩៩ភាគរយនៃជនជាតិភាគតិច ដែលរួមមាន ចិន ចាម និងខ្មែរម៉ូស្លីម វៀតណាម កុលសម្ព័ន្ធភាគតិចតំបន់ខ្ពង់រាប និងក្រុមតូចៗដទៃទៀត មានចំនួនច្រើនជាងនេះយ៉ាងខ្លាំង។ បញ្ញវន្តមួយរូបបានប៉ាន់ប្រមាណថាជនជាតិភាគតិចចាមមានចំណែករហូតដល់២០ភាគរយនៃប្រជាជនសរុបនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ។

ប្រជាជនចាម ដែលជាជាតិពន្ធុ និងជនជាតិភាគតិចនៃសាសនាមួយ មិនយល់ព្រមធ្វើតាមកិច្ចខិតខំប្រឹងប្រែងរបស់របបនេះ ដែលហាមឃាត់ក្នុងការអនុវត្តសាសនារបស់ខ្លួនទេ។ បន្ទាប់មក របបនេះក៏សម្លាប់មេដឹកនាំសាសនាចាម និងអ្នកទាំងឡាយដែលបដិសេធក្នុងការអនុវត្តតាមបញ្ជានានារបស់ខ្លួន។ កងកម្លាំងខ្មែរក្រហមបានបំបែកសហគមន៍នានានៅតាមដងទន្លេមេគង្គ ជាទីកន្លែងដែលចាមជំទាស់នឹងគោលនយោបាយប្រឆាំងសាសនារបស់របបនេះ និងបានអនុវត្តយុទ្ធនាការដើម្បីលុបបំបាត់ចាមនៅតាមតំបន់នានាដែលមានការប្រមូលផ្ដុំច្រើន។

យុទ្ធនាការប្រឆាំងចាមរបស់កម្ពុជាប្រជាធិបតេយ្យ គឺជាអំពើប្រល័យពូជសាសន៍ នៅក្រោមច្បាប់អន្តរជាតិ។ អំពើប្រល័យពូជសាសន៍ ត្រូវបានកំណត់និយមន័យចំពោះអំពើណាមួយក្នុងចំណោមអំពើទាំងប្រាំ រួមមាន ការសម្លាប់សមាជិកនៃក្រុមណាមួយ ដែលបានប្រព្រឹត្តក្នុងចេតនាដើម្បីបំផ្លិចបំផ្លាញក្រុម ជាតិ សាសនា ជាតិពន្ធុ ឬពូជសាសសាន៍ណាមួយ។ របបនេះបានបង្កើតគោលនយោបាយចំពោះចាម ក្នុងគោលបំណងបំផ្លិចបំផ្លាញការរស់រានមានជីវិតរយៈពេលវែងរបស់ចាម ក្នុងនាមជាក្រុមជាតិ ជាតិពន្ធុ និងសាសនាមួយខុសប្លែកពីគេនៅកម្ពុជា។

របបនេះ បានហាមឃាត់ការសំដែងគ្រប់បែបយ៉ាងអំពីអត្តសញ្ញាណចាម រួមទាំង ការអនុវត្តសាសនាអ៊ីស្លាម ការនិយាយភាសាចាម ការស្លៀកពាក់បែបប្រពៃណីចាម និងការអនុវត្តក្នុងការតមអាហារតាមបែបប្រពៃណី ដូចជា ការមិនហូបសាច់ជ្រូកជាដើម។ ដើម្បីពន្លឿនបន្ថែមដល់ការបំបាត់អត្តសញ្ញាណក្រុមរបបនេះក៏បានប្រើការផ្លាស់ប្ដូរទីតាំងដោយបង្ខំ និងការសម្លាប់រង្គាលដើម្បីផ្ដាច់ផ្ដិលសហគមន៍ដែលប្រជាជនចាមប្រមូលផ្ដុំ។ ជនណាដែលនៅតែទទឹងក្នុងការថែរក្សាអត្តសញ្ញាណចាមរបស់ខ្លួននឹងត្រូវបានសម្លាប់ចោល។ ជនណាសម្លាប់សមាជិកនៃក្រុមក្នុងចេតនាដើម្បីបំផ្លិចបំផ្លាញក្រុម គឺជាអំពើមួយនៃអំពើប្រល័យពូជសាសន៍ទាំងប្រាំដែលត្រូវបានហាមឃាត់។

តំបន់នានាដែលមានការប្រមូលផ្ដុំនៃប្រជាជនចាម និងជាទីកន្លែងដែលវប្បធម៌ចាមត្រូវបានរបបនេះបំបែកមេដឹក-នាំ និងសម្លាប់ ហើយប្រជាជនក៏បានខ្ចាត់ខ្ចាយ (ខ.ស្រុកក្រូច


រាប់ពីស្ដាំ នួន ជាជាមួយ

ឆ្មាំ) ឬត្រូវបានដាក់ក្នុងចំណោមមនុស្សដែលត្រូវសម្លាប់វង្គាល ក្នុងចេតនាដើម្បីលុបបំបាត់ចាមទាំងអស់នៅក្នុងតំបន់នោះ(ខ.ស្រុកកំពង់សៀមនិងស្រុកកងមាស)។មេដឹកនាំសាសនាចាម ត្រូវបានកំណត់គោលដៅ ហើយភាគច្រើនត្រូវបានសម្លាប់។ ចំនួនហាកឹម (ប្រធានភូមិ) បានធ្លាក់ចុះពីចំនួន ១១៣ មកនៅត្រឹម២០នាក់ នៅក្នុងអំឡុងនៃសម័យកាលកម្ពុជាប្រជាធិបតេយ្យ ហើយចំនួនទួន (គ្រូសារសាសនាអ៊ីស្លាម) ពីចំនួន៣០០ មកនៅត្រឹម៣៨នាក់។

ក្រុមសាសនា មិនអាចកំណត់បានតាមរយៈឌីអិនអេ (DNA) ឬសែស្រឡាយញាតិឪពុកម្ដាយ ប៉ុន្តែផ្ទុយទៅវិញជាបណ្ដុំនៃចំណែករបស់អ្នកកាន់សាសនា និងរបៀបរបបនៃអ្នកគោរពបូជា។ បើសិនជាអ្នកស្ថិតនៅក្នុងអំណាច អាចបញ្ឈប់ដោយជោគជ័យនូវការអនុវត្តសាសនាជាក់លាក់ណាមួយតាមរយៈការសម្លាប់អ្នកកាន់សាសនា ដែលបដិសេធមិនព្រមលះបង់ចំណែកនៃការអនុវត្តសាសនារបស់ខ្លួននោះ របបនេះនឹងអាចបំផ្លាញសាសនានោះហើយ។ ក្រុមសាសនាមួយនឹងមិនអាចរស់បានឡើយ ប្រសិនបើជនទាំងឡាយដែលជាអ្នកប្រត្តិបត្តិសាសនានោះត្រូវបានសម្លាប់ ហើយក្រុមទាំងមូលមិនអាចរស់រានមានជីវិតឡើយ ប្រសិនបើប្រជាជននៃក្រុមនោះត្រូវបានរបបខ្មែរក្រហមបំបែកឲ្យខ្ចាត់ខ្ចាយ ហើយសមាជិកនៃក្រុមត្រូវបានហាមឃាត់ការនិយាយភាសារបស់ក្រុមខ្លួន និងថែរក្សាទំនៀមទម្លាប់ដែលកំណត់ពីបុគ្គលម្នាក់ៗនៃក្រុមដែលមានលក្ខណៈខុសប្លែកពីប្រជាជនជាទូទៅ។ អ្នកដែលនៅប្រកាន់យកអត្តសញ្ញាណរបស់ក្រុម គឺជាមនុស្សសក្តានុពលនៃការរស់រានមានជីវិតនៃក្រុម។ ដូចអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានពន្យល់យ៉ាងដូច្នេះថា៖


បគណៈប្រតិភូ បរទេស

ជាការបន្ថែម ទំហំជាតួលេខនៃចំណែកដែលគេបានកំណត់គោលដៅ ដែលជាភាពលេចធ្លោរបស់វានៅក្នុងក្រុម អាចយកជាសេចក្ដីពិចារណាមួយដ៏មានប្រយោជន៍។ ប្រសិនបើចំណែកជាក់លាក់ណាមួយនៃក្រុមជាបដិរូបនៃ ក្រុមទាំងមូល ឬមានក្តានុពលចំពោះការរស់រានមានជីវិតរបស់ក្រុមនោះអាចគាំទ្រដល់របកគំហើញដែលថា ផ្នែកនោះ មានគុណវុឌ្ឍិជាផ្នែកសំខាន់គួរសមនៅក្នុងអត្ថន័យនៃមាត្រា៤។

អនុភាពនៃគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យប្រឆាំងចាមត្រូវបានបន្ធូរបន្ថយ ដោយសារតែរបបនេះត្រូវបានផ្តួលរំលំបន្ទាប់ពីបានកាន់អំណាចជិតបួនឆ្នាំ។ ប្រសិនបើគោលនយោបាយទាំងនោះនៅតែបន្តជាច្រើនឆ្នាំទៅមុខទៀត ជាមួយនឹងភាពរាយប៉ាយនៃសហគមន៍ចាម ជាមួយនឹងការហាមឃាត់គ្រប់ការសំដែងទាំងអស់ នៃអត្តសញ្ញាណចាម ហើយជាមួយនឹងជនណាហ៊ានរឹងទទឹងនៅ តែប្រកាន់យកអត្តសញ្ញាណចាម ត្រូវបានខ្មែរក្រហមសម្លាប់ចោលនោះ គេគ្មានមន្ទិលសង្ស័យទេថាលទ្ធផល គឺជាការបំផ្លាញចំពោះចាម «យ៉ាងដូច្នេះ» ក្នុងនាមជាជាតិពន្ធុ និងក្រុមសាសនាខុសប្លែកពីគេមួយនៅក្នុងប្រទេសកម្ពុជា។ ក្មេងចាមជំនាន់

ក្រោយដែលបានរស់រានមានជីវិតជាចុងក្រោយ នឹងត្រូវបញ្ឈប់លែងហ៊ានប្រើអត្តសញ្ញាណចាម ហើយក្រុមនេះជាចុងក្រោយនឹងត្រូវបាត់សូន្យ។

សុះ រំលី ធ្វើការជាស្មៀន នៅក្នុងមន្ទីរឃុំទ្រា ក្នុងស្រុកក្រូចឆ្មា ក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ មន្ត្រីសន្តិសុខតំបន់ម្នាក់ដែលបានទៅមើលមន្ទីរនោះក្នុងឆ្នាំ១៩៧៨ មិនបានដឹងថា សុះ រំលី ជាជនជាតិចាមនោះទេ ហើយបានសួរគាត់ថាតើជនជាតិចាមបានទៅណាអស់ហើយ។ បន្ទាប់ពី សុះ រំលី បានពន្យល់ថាភាគច្រើននៃជនជាតិចាម ត្រូវបានជម្លៀសទៅកាន់ភូមិភាគកណ្តាល ហើយនៅសល់តែប្រមាណ១៥ ភាគតែប៉ុណ្ណោះ នៅក្នុងភូមិមន្ត្រីសន្តិសុខតំបន់នោះបានប្រាប់គាត់ថា «ចាមទាំងអស់ហ្នឹងគេកម្ទេចឲ្យទាំងអស់ហ្នឹង គេមិនឲ្យនៅសល់ទេ»។ សុះ កំរ៉ុ បានផ្តល់សក្ខីកម្មអំពីការប្រជុំមួយដែលគាត់បានចូលរួមនៅក្នុងស្រុកចម្ការលើ ក្នុងឆ្នាំ១៩៧៧ ដែលខ្មាំង និងផែនការកម្ទេចចាមត្រូវបានពិភាក្សា។ ក្រោយមកគាត់បានឃើញកូនសៀវភៅផ្សព្វផ្សាយមួយនៅមន្ទីរឃុំអូរនង់ ដែលបានរៀបរាប់ថា ចាម គឺជា«ខ្មាំងធំជាងគេបំផុតត្រូវបានកម្ទេចចោលទាំងអស់នៅមុនឆ្នាំ១៩៨០»។ វ៉ាន់ ម៉ាត់ បានផ្តល់សក្ខីកម្មថា គាត់បានបើកឡានដឹកប្រធានឃុំទៅប្រជុំនៅការដ្ឋានកំពង់ថ្ម ក្នុងភូមិកណ្តាល ដែលជាកន្លែងកម្មាភិបាលនានាទទួលការណែនាំពីគោលនយោបាយសម្រាប់ «ខ្មាំង» ភូមិភាគបូព៌ា និង ថា «គេដាក់ផែនការឲ្យខាងមេថ្មីមកកាន់នៅភូមិភាគបូព៌ាហ្នឹង ឲ្យអនុវត្តផែនការរបស់អង្គការទាក់ទងនឹងការកម្ទេចចាម»។

អតីតលេខាស្រុកកំពង់សៀម ប្រាក់ យុត បានផ្តល់សក្ខីកម្មថា គាត់បានទទួលបញ្ជាក្នុងឆ្នាំ១៩៧៧ ឲ្យបោសសម្អាតចាម និងបញ្ជូនបញ្ជានោះបន្តទៅកាន់ថ្នាក់ក្រោមរបស់គាត់។ អ្នកស៊ើបអង្កេតម្នាក់មកពី កសចស បាននិយាយទៅកាន់ប្រជាជនក្នុងភូមិចំនួន១២ ក្នុងឃុំទ្រា ស្រុកកំពង់សៀម។ អ្នកទាំងអស់នេះ បានប៉ាន់ប្រមាណថា មានគ្រួសារចាមចំនួនប្រហែលជា២៩២គ្រួសារ នៅក្នុងភូមិទាំង១២នេះ ដែលត្រូវបានបញ្ជូនចេញ និង«បានបាត់ខ្លួន» ដោយមានសាកសពរបស់ពួកគេជាច្រើនត្រូវបានទម្លាក់ ចូលក្នុងអណ្តូងទឹក ឬរណ្តៅគ្រាប់បន្ទុះទុកតែបីនាក់ប៉ុណ្ណោះ នៅរស់រានមានជីវិត។ តាមការប្រើប្រាស់ការប៉ាន់ប្រមាណធម្មតានៃចំនួនប្រាំនាក់ក្នុងមួយគ្រួសារ បុគ្គលប្រមាណ ១.៤៦៤នាក់ ត្រូវបានសម្លាប់ក្នុងភូមិទាំង១២នេះតែឯង។ ទ្រា គ្រាន់តែឃុំមួយក្នុងចំណោមឃុំទាំង១១ នៅក្នុងស្រុកកំពង់សៀមប៉ុណ្ណោះ។

### អំពើប្រល័យពូជសាសន៍វៀតណាម

ប៉ាក សុខ ជាកម្មាភិបាលខ្មែរក្រហមមកពីកំពង់សោម បានឆ្លើយនឹងសំណួរដូចខាងក្រោម៖

សំណួរ៖ តើដោយពិតប្រាកដ តើគ្រូបង្ហាត់... និយាយដូចម្តេច នៅពេលគាត់បង្រៀនអំពីសត្រូវសួរពូជវៀតណាមហ្នឹង? តើគាត់និយាយអំពីអ្វីខ្លះជាខ្លឹមសារ?

ឆ្លើយ៖ បាទជាការពិតណាស់សត្រូវសួពូជហ្នឹងគឺថាសម្លាប់អត់មានទុក សូម្បីតែកូនង៉ែតមួយក៏អត់ឲ្យមានដែរ ព្រោះនេះជាសត្រូវសួរពូជ គឺសម្លាប់ចោលតែម្តង ព្រោះទំនាស់បដិបក្ខ។ បាទនេះជាអង្គសិក្ខាសាលានៅក្នុងមន្ទីរនៃវរសេនាតូចនីមួយៗទទួលផែនការច្បាស់លាស់តែម្តង។

គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះជាតិពន្ធុវៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជាបាន កើតឡើងជាលំដាប់។ ភ្លាមៗនោះក្រោយថ្ងៃជ័យជន្នះ ១៧ មេសារបបនោះ បានបញ្ជូនចេញភាគច្រើននៃជនជាតិវៀតណាមដែលរស់នៅតាមព្រំដែនកម្ពុជាទៅកាន់ប្រទេសវៀតណាម។ ភាគដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា បានរៀបការជាមួយជនជាតិខ្មែរ ឬជាខ្មែរកាត់វៀតណាម។ រដ្ឋាភិបាលកុម្មុយនីស្តក្រុងហាណូយ បានចិញ្ចឹមខបត្តម្ភ ខ្មែរក្រហមពីពេលនៅក្មេងខ្ចី និងបានជួយក្នុងការផ្តួលរំលំ របបសាធារណរដ្ឋខ្មែរ។ ប៉ុន្តែដោយសារភាពភ័យខ្លាចរបស់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យចំពោះអ្នកជិតខាងមានអំណាចនេះហើយ ដែលចេះតែកើតឡើងជាលំដាប់នោះ ក៏ដូចជាអរិយភាពរបស់ខ្លួន ចំពោះជាតិពន្ធុវៀតណាមដែលនៅសល់ក្នុងប្រទេសកម្ពុជាទាំងនោះ

ក៏បានកើតឡើងដែរ។ ប្រហែលជាក្នុងឆ្នាំ១៩៧៧ របបនេះបានអនុម័ត គោលនយោបាយសម្លាប់ជាតិពន្ធុវៀតណាមដែលនៅ សេសសល់ក្នុងព្រំដែលរបស់ប្រទេសខ្លួនសូម្បីតែអ្នកមានប្ដីប្រពន្ធជាខ្មែរ។ ភាពភ័យខ្លាចប្រឆាំងនឹងជាតិពន្ធុវៀតណាម ជាចុងក្រោយបានរីករាលដាលរហូតដល់មានជាយុទ្ធនាការផ្ដោតលើប្រជាជនខ្មែរក្រោមដោយគ្រាន់តែអ្នកទាំងនេះ មានដើមកំណើតមកពីទឹកដីដែលបច្ចុប្បន្នស្ថិត នៅក្នុងព្រំដែលប្រទេសវៀតណាម ហើយអ្នកទាំងនេះត្រូវបានខ្មែរក្រហមគិតជាជាក្រុម «ក្បាលយួន ខ្លួនខ្មែរ»។

មាស វឿន គឺជាអតីតមេបញ្ជាការវរសេនាធំខ្មែរក្រហមដែលបានបម្រើការសន្តិសុខ ការពារ ខៀវ សំផន និងនៅតែមិនមានការសោកស្ដាយអំពីឧក្រិដ្ឋកម្មនានារបស់ខ្មែរក្រហម។ សក្ខីកម្មសវនាការរបស់គាត់នៅក្នុងរឿងក្ដីនេះបានរួមបញ្ចូលការទទួលស្គាល់គួរឲ្យកត់សម្គាល់មួយនេះ៖

សំណួរ៖ តើលោកធ្លាប់ស្ដាប់ឮថាមានផែនការកម្ទេចវៀតណាមដែលនៅរស់នៅកម្ពុជាចន្លោះឆ្នាំ៧៥ដល់៧៩ទេ?

ឆ្លើយ៖ មានៗឮរឿងវៀតណាមនៅក្នុងស្រុកខ្មែរហ្នឹង... អ៊ីចឹងបានន័យថាជាការផែរដែលត្រូវកម្ទេចហ្នឹង ឲ្យប្រជាជនគេឲ្យទៅតាមសម្របសម្រួលហ្នឹងកាលមុនគេឲ្យទៅ តាមសម្រួលដោយតាំងពី៧០នោះ។ រឿងៗវៀតណាមថ្នាក់ដឹកនាំខ្មែរយើងឲ្យទៅតាំងពីឆ្នាំ១៩៧០ រហូតមក៧៥ ក៏ឲ្យទៅដែរ តែគេអត់ចង់ទៅ អាហ្នឹងគេមានទិសដៅឬផែនការ។ អ៊ីចឹងតាមអត្ថភាពអ៊ីចឹងឲ្យតែវៀតណាមត្រូវកម្ទេចអ៊ីចឹង។

អត្ថហេតុដែលថា គោលនយោបាយមកពីថ្នាក់ដឹកនាំមជ្ឈិមនោះ ត្រូវបានគាំទ្របន្ថែមទៀតដោយទូរលេខដែលរស់ ញឹម មេបញ្ជាការភូមិភាគពាយ័ព្យបញ្ជូនទៅកាន់មន្ទីរ ៨៧០ ដែលជាផ្នែកប្រតិបត្តិរបស់គណៈអចិន្ត្រៃយ៍ក្នុងរយៈពេលដ៏ខ្លីមុនពេលការចាប់ខ្លួនគាត់ក្នុងខែមិថុនា ឆ្នាំ១៩៧៨។ ញឹម បានសួរថា៖

ពួកយួនដែលមានប្ដីខ្មែរ មានខ្មែរបានប្រពន្ធយួន ហើយកូនកាន់យួន តើឲ្យសម្រេចយ៉ាងណា? ការនេះមតិអង្គប្រជុំសួរមកអង្គការ៨៧០ទៀត។ បើអង្គការសម្រេច យ៉ាងណាសូមមានមតិណែនាំមកចុះ។

ទស្សនាវដ្ដីទង់បដិវត្តរបស់កម្ពុជាប្រជាធិបតេយ្យបានរាយការណ៍ ក្នុងខែមេសា ឆ្នាំ១៩៧៨ អំពីជ័យជម្នះនៃកម្មវិធីកម្ទេចសហគមន៍វៀតណាមនៅកម្ពុជាថា៖

រហូតដល់ឥឡូវយួនយ៉ាងម៉េច? យួនអត់នៅក្នុងទឹកដីកម្ពុជា។ ពីដើមជិតមួយលាននាក់។ ឥឡូវរកមួយគ្រាប់គ្មានទេ។

### ការបោសសម្អាត-បដិវត្តន៍ស៊ីកូនខ្លួនឯង

ទោះបីជាមានអ្វីកើតឡើងក៏ដោយ យើងត្រូវតែការពារអ្នកដឹកនាំយើង ការបាត់បង់សមាជិក២០០-៣០០នាក់មិនអាចជាការប្រៀបធៀបនឹងការបាត់បង់កម្មាភិបាលដឹកនាំពីរបីនាក់ឡើយ។ ការបាត់បង់សមាជិក២០០-៣០០នាក់ប្រសើរជាងការបាត់បង់សមាជិកពីរទៅបីនាក់។

**នួន ជា, កក្កដា ១៩៧៨**

ដោយហេតុការណ៍កើតឡើងចេះតែញឹកញាប់ មេដឹកនាំកំពូលរបស់របបនោះ បានស្ដីបន្ទោសខ្លាំងខាងក្នុងចំពោះការបរាជ័យរបស់ខ្លួនឯងផ្ទាល់ និងបានចូលរួមក្នុងការបោសសម្អាតកម្មាភិបាលខ្លួនឯង ដែលចេះតែរីករាលដាលឡើង។ មេដឹកនាំខ្មែរក្រហមដើងចាស់ត្រូវបានចាប់ខ្លួន ធ្វើទារុណកម្ម និងបង្ខំឲ្យសារភាពក្នុងផែនការដ៏ខ្លាំងខ្លាពាក់ព័ន្ធនឹងសេអ៊ីអាកាហ្សិបេ និងភ្នាក់ងារវៀតណាម និងដើម្បីកំណត់ឈ្មោះ អ្នកពាក់ព័ន្ធទាំងអស់របស់ពួកគេ។ អ្នកណាដែលពាក់ព័ន្ធនិងអ្នកដែលត្រូវបានចាប់ខ្លួនតាម រយៈការផែរឬ ទំនាក់ទំនងគ្រួសារនោះត្រូវបានចាត់ទុកថាជាផ្នែកមួយនៃ«ខ្សែ» ហើយពួកគេផ្ទាល់ ទំនងជាត្រូវបានចាប់ខ្លួនខណៈដែលរបបនោះឈានឡើងដល់កម្រិតនៃ អំពើហិង្សាបំផ្លាញខ្លួនឯង។

*(នៅមានត)*

*សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

# ភាពវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ
# របស់មជ្ឈមណ្ឌលឯកសារកម្ពុជា




បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅអគារ H
នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរដ្ឋកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។


សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ស៊ាង ចិន្តា ទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥
អ៊ីម៉ែល៖ truthchenda.s@dccam.org

# តើថ្ងៃ២០ ឧសភា ២០១៨ ជាសំណងជាលើកដំបូងរបស់រាជរដ្ឋាភិបាលកម្ពុជាជូនដល់ជនរងគ្រោះនៃរបបខ្មែរក្រហម?

ចាប់តាំងពីឆ្នាំ១៩៨៤ រហូតដល់មានកិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ប្រជាជនកម្ពុជាទូទាំងប្រទេសរួមមានជនរងគ្រោះនៃរបបខ្មែរក្រហម និងអ្នកដែលបានកើតក្រោយឆ្នាំ១៩៧៩តែងតែបានឈប់សម្រាកពីការងារមួយថ្ងៃ នៅថ្ងៃទី២០ ឧសភា ជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធទិវាចងកំហឹង និងរំឭកទៅដល់ការឈឺចាប់ខ្លោចផ្សាពីការបាត់បង់សាច់ញាតិរបស់ខ្លួន នៅក្នុងរបបវាលពិឃាតពីឆ្នាំ១៩៧៥-១៩៧៩។ ទោះបីជាយ៉ាងណាក៏ដោយចាប់ពីឆ្នាំ១៩៩២ទិវាចងកំហឹងត្រូវបានបាត់រូបភាពជាសាធារណៈ ឬក៏ប្រារព្ធឡើងក្នុងកម្រិតតូច និងស្ងៀមស្ងាត់ក្នុងរង្វង់តែគណៈបក្សប្រជាជនតែប៉ុណ្ណោះ នេះប្រហែលជាដោយសារការផ្លាស់ប្ដូរនយោបាយចំពោះក្រុមខ្មែរក្រហមដែលពេលនោះក្រុមខ្មែរក្រហម បានក្លាយជាភាគីនយោបាយស្របច្បាប់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែរ។ បន្ទាប់ពីដួលរលំទាំងស្រុងនៃចលនា និងកងកម្លាំងខ្មែរក្រហមលើកចុងក្រោយបំផុតនៅចុងឆ្នាំ១៩៩៨ ទិវាចងកំហឹង ២០ ឧសភា ត្រូវបានប្រជាជនទូទៅបានស្គាល់ថាជា «ទិវានៃការចងចាំ ២០ ឧសភា»វិញ។



រដ្ឋាភិបាលបានប្រារព្ធទិវាចងចាំ ២០ ឧសភា ២០១៨ នៅសារមន្ទីរប្រល័យពូជសាសន៍បឹងជើងឯក

នៅពីថ្ងៃ១៨ ខែកុម្ភៈ ឆ្នាំ២០១៨ កន្លងទៅរាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹតលេខ១៩ អនក្រ.បក ចុះស្តីពីទិវាជាតិនៃការចងចាំ។ នៅក្នុងអនុក្រឹតនោះ មាន៣មាត្រា៖

មាត្រា១ បានចែងអំពីការកំណត់យកថ្ងៃ២០ ឧសភា ជារៀងរាល់ឆ្នាំជា «ទិវាជាតិនៃការចងចាំ» ដែលជាថ្ងៃបុណ្យជាតិផ្លូវការមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ជាការរំឭកដល់ជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្មដែលបានកើតមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

មាត្រា២ ទិវាជាតិនៃការចងចាំនេះត្រូវបានកំណត់ជាថ្ងៃឈប់សម្រាកសាធារណៈ។ ប្រជាពលរដ្ឋគ្រប់រូប ត្រូវបានផ្តល់ឱកាសឲ្យរៀបចំពិធីតាមជំនឿសាសនា ឬទំនៀមទម្លាប់របស់ខ្លួន។ បន្ទាប់ពីរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យ ២០១៨ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេចក្តីប្រកាស ស្តីពីការឈប់សម្រាកទិវាជាតិនៃការចងចាំ។ ដោយសម្រេច ប្រការ១ ត្រូវបានអនុញ្ញាតិឲ្យកម្មករនិយោជិកនៃសហគ្រាស គ្រឹះស្ថានទាំងអស់ដែលមានចែងក្នុងមាត្រា១នៃច្បាប់ស្តីពីការងារដោយមានប្រាក់ឈ្នួល នៅថ្ងៃទី២០ ខែឧសភា ជារៀងរាល់ឆ្នាំ។

ក្នុងឱកាសទិវានៃការចងចាំ២០ ឧសភា ឆ្នាំ២០១៨ នៅសារមន្ទីរឧក្រិដ្ឋកម្មបឹងជើងឯកដែលមានប្រជាជនចូលរួមប្រមាណជា៧.០០០នាក់ ក្នុងនោះរួមមានព្រះសង្ឃ២០១ អង្គផងដែរ។ បន្ទាប់ពីការថ្លែងវិយោគកថា ក៏មានការសម្តែងល្ខោនអំពីខ្មែរក្រហមធ្វើទារុណកម្ម សម្លាប់ប្រជាជន និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ចូលមករំដោះប្រជាជនចេញពីរបបយង់ឃ្នងនេះ។

អ្នកចូលរួមក្នុងកម្មវិធីទិវាជាតិនៃការចងចាំ ២០ ឧសភា នៅបឹងជើងឯកភាគច្រើនមានការពេញចិត្តនឹងអបអរសាទរ


សាធារណជនចូលរួមប្រារព្ធពិធីទិវានៃការចងចាំ២០ឧសភា ២០១៨

ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានចេញអនុក្រឹត្យចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៨ និងអនុញ្ញាតិឲ្យប្រជាជនទូទាំងប្រទេសបានឈប់សម្រាកជាសាធារណៈមួយថ្ងៃដោយមានប្រាក់ឈ្នួល។

និស្សិតនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញឈ្មោះ ម៉ី សោភ័ណ ដែលបានចូលរួមក្នុងកម្មវិធីនេះបានបង្ហាញពីការចាប់អារម្មណ៍ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់យកថ្ងៃ២០ ឧសភា ជារៀងរាល់ឆ្នាំជាថ្ងៃឈប់សម្រាក និងប្រារព្ធទិវាជាតិនៃការចងចាំ ដែលមានភាពក្តុកក្តួល និងបង្ហាញពីការសោកស្តាយចំពោះជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិត។ ការឈប់សម្រាកនេះក៏ជាសំណាងមួយក្នុងកាស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ និងការរំឭកសោកនាដកម្មដែលបានកើតឡើងពីអតីតកាល។ ក្នុងនាមជាយុវជនជំនាន់ក្រោយ សោភ័ណ បានបន្តថាមិនចង់ឲ្យរបបខ្មែរក្រហមនេះកើតឡើងម្តងទៀតទេ។


ស្តូបបឹងជើងឯក ប្រារព្ធទិវានៃការចងចាំ ២០ ឧសភា ២០១៨

ឈ្មោះ ពៅ ស៊ីថា អាយុ៦៤ឆ្នាំ មានតួនាទីជាក្រុមប្រឹក្សាសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ បានចូលរួមក្នុងទិវាជាតិនៃការចងចាំនៅជើងឯក ដើម្បីរំឭកពីរបប ប៉ុល ពត ដែលសម្លាប់ប្រជាជនស្លូតត្រង់ និងធ្វើការគោរពវិញ្ញាណក្ខន្ធ ឧទ្ទិសកុសលដល់ជនរងគ្រោះ ដែលបានស្លាប់។ ស៊ីថា បានបាត់បង់សាច់ញាតិបងប្អូន ឪពុកម្តាយទាំងអស់ ៨នាក់ ស្លាប់នៅក្នុងខេត្តពោធិ៍សាត់ ដែលត្រូវរបប ប៉ុល ពត បានសម្លាប់។ ស៊ីថា បានយល់ឃើញថា រាជរដ្ឋាភិបាលកម្ពុជាចេញអនុក្រឹត ដែលបានអនុញ្ញាតិឲ្យប្រជាជនឈប់សម្រាកទូទាំងប្រទេសកម្ពុជា នៅថ្ងៃ២០ឧសភាជាការល្អ ព្រោះវាជាសំណាងមួយដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ហើយប្រជាជនក៏មានពេលមួយថ្ងៃ ដើម្បីប្រារព្ធពិធីទិវានៃការចងចាំទូទាំងប្រទេស។

លោក សុខ សារឿន មានអាយុ ៧៥ ឆ្នាំដែលមាន ស្រុកកំណើតនៅភ្នំឌិន ស្រុកគីរីវង្ស ខេត្តតាកែវ។ បច្ចុប្បន្នគាត់រស់នៅទីក្រុងភ្នំពេញ បាននិយាយរៀបរាប់ពីការ បាត់បង់កូនពីរនាក់ និងការបាត់បង់សមាជិកគ្រួសារ បងប្អូនជីដូនមួយដែលបានស្លាប់នៅក្នុងសម័យខ្មែរក្រហម។ សារឿន បានចូលរួមក្នុងពិធីប្រារព្ធទិវានៃការចងចាំ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨ នៅបឹងជើងឯកនេះ គឺដើម្បីគោរពដល់វិញ្ញាណក្ខន្ធជនរងគ្រោះ។ សារឿន បានបន្ថែមថាគាត់បានចូលរួម ទិវា ២០ ឧសភា ជារៀងរាល់ឆ្នាំ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨ នេះ សារឿន នៅតែមានអារម្មណ៍ឈឺចាប់ពីបាត់បង់ក្រុមគ្រួសារ ឪពុកម្តាយហើយ ក៏មិនដឹងថា អ្នកទាំងនោះស្លាប់នៅទីណាដែរ។ សារឿន មិនបានដឹងអំពីអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា កំណត់ឲ្យប្រជាជនឈប់ទូទាំងប្រទេសនៅថ្ងៃ២០ ឧសភា ឡើយ។ ប៉ុន្តែ សារឿន រីករាយនៅពេល ដែលរាជរដ្ឋាភិបាលអនុញ្ញាតឲ្យឈប់សម្រាកមួយថ្ងៃ។ **ដារ៉ារដ្ឋ មេត្តា**

# ព្រលឹងមាសម្តាយ

*(តចប់)*

ចំពោះខ្ញុំវិញ តើគូខ្ញុំជានរណា? ខ្ញុំគ្មាននិស្ស័យចង់បានគ្រួសារទាល់តែសោះ ខ្ញុំត្រដរអាត្មារស់ស្ទើរពុំបានផងៗ នៅពេលដែលបុរសនោះលូកដៃកាន់ដៃខ្ញុំ ខ្ញុំបានសួរថា មិត្តបងជាអ្នកស្រុកណា? កូនចៅអ្នកណា? ចម្លើយទៅនឹងសំណួរនេះបានធ្វើឲ្យយើងទាំងពីរនាក់ភ្ញាក់ផ្អើលយ៉ាងខ្លាំង មិនគួរឲ្យជឿសោះថា បុរសនោះជាបង កនៗ បុរស ដែលអង្គការបានប្រកាសថា ជាគូរបស់ខ្ញុំនោះពិតជាពុំមែនឈ្មោះនេះទេ ទាំងមាឌ ទាំងកម្ពស់ ក៏ពុំមែនដែរៗ បាតុភូតវង្វេងគូនេះ ក៏ធ្លាក់មកលើខ្ញុំដែរ ប៉ុន្តែអាចរាប់ថា ជាភ័ព្វសំណាងដែលទេវតាបានដឹកដៃបងប្អូនជីដូនមួយយើងឲ្យជួបគ្នា តែក៏អាចជាអកុសល ដែលយើងអាចនឹងត្រូវអង្គការសម្លាប់ចោលដែរខ្ញុំមិនអាចទទួលយកបងកន ទេរឿងគាត់រៀនសូត្របានតិចជាងខ្ញុំលែងនិយាយរួចទៅហើយ ប៉ុន្តែរឿងដែលមិនអាចលាក់បាំងបាននោះ គឺខ្ញុំស្អប់ខ្ពើមសារធាតុគាត់ណាស់ ដែលសូម្បីតែបងប្រុសបង្កើតរបស់គាត់ក៏ គាត់អាចលើកដៃបាញ់ប្រហារ




*អ៊ុន វណ្ណា*

បានដែរ ប្រវត្តិរបស់គាត់មិនអាចលាក់កំបាំងជាមួយខ្ញុំបានទេ ខ្ញុំមិនអាចបំភ្លេចព្រឹត្តិការណ៍នេះបានទេ ទំនួញចុកចាប់របស់ អ៊ំ សៀន ដោយសារកូនបាញ់គ្នាឯង នៅតែលាន់ឮរំពងពេញក្នុងត្រចៀកខ្ញុំ។ តែគួរឲ្យសរសើរ និងគោរពណាស់ដែរ ពីព្រោះ បង កន មិនបានបង្ខំចិត្តខ្ញុំទេ។ យើងរស់នៅដោយលួចលាក់នឹងភ្នែកអង្គការ ដោយក្លែងសម្តែងដូចជាគូស្រករមែនទែន។ យើងបារម្ភណាស់ ពីព្រោះអង្គការមានភ្នែកច្រើនដូចម្នាស់ តើយើងអាចបិទបាំងអាថ៌កំបាំងនេះបានយូរប៉ុណ្ណា។ យប់មួយ យើងបានដឹងខ្លួន ថាមានកងឈ្លបមកលបស្តាប់ ការសន្ទនារបស់យើងតែងតែប្រុងប្រយ័ត្នខ្ពស់ក្នុងការរក្សាអាថ៌កំបាំងនេះ។ ពិតមែនព្រឹត្តិការណ៍ដ៏គួរឲ្យព្រួយបារម្ភមួយបានកើតឡើងមកលើក្រុមគ្រួសារយើងទៀតហើយព្រលឹមស្រាងៗឡើងស្រាប់តែអង្គការចាត់ឲ្យបង កន ទៅកាន់ភ្នំដងរែក ដើម្បីតាមស្ទាក់យកកងចល័ត និងប្រជាជនរត់ចូលដីសៀមឲ្យយកមកសហករណ៍វិញ។ ខ្ញុំបានរៀបចំជូនបងនូវប្រដាប់ប្រដារប្រើប្រាស់ផ្ទាល់ខ្លួនតាមបក្សកំណត់ កម្មសិទ្ធិសួនតួសមរម្យរបស់ យុទ្ធមិត្តបដិវត្តន៍ គឺមានតែ «មួយកូនស្បោងតូច»ដែលក្នុងនោះរួមមានទាំងកូនសៀវភៅ និងប៊ិករបស់បងផង។ មុននឹងចាកចេញទៅបងបានដកកូនសៀវភៅនោះ ហុចមកឲ្យខ្ញុំវិញដោយទឹកមុខ ស្រពាប់ស្រពោន បងបើកបបូរមាត់ញ័ររខុប និយាយមករកខ្ញុំថាសូមអូនអានវាផង។ ខ្ញុំទទួលកូនសៀវភៅ ពីដៃបង កន ដោយឥតហ៊ានទទូចសួរ អំពី អ្វីតទៅទៀតឡើយក្រៅពីជូនពរសូមឲ្យបងប្រកបតែ នឹងសេចក្តីសុខ និង ឆាប់បានវិលមកវិញ។

ពេលយប់ខែភ្លឺខ្ញុំបានលួចបើកសៀវភៅបង កន ដើម្បីបានដឹងថាតើគាត់មានសរសេរពីអ្វីដែលចង់ធ្វើទុកឲ្យខ្ញុំនោះ។ ក្រៅពីកំណត់ត្រា ទាក់ទងនឹងផែនការបទបញ្ជាបដិវត្តន៍ ខ្ញុំប្រទះឃើញមានការដកស្រង់នូវកំណាព្យ ច្បាប់ ក្រមនិងពាក្យស្លោកបុរាណល្អៗ ជាច្រើនអន្លើ ដូចជាប្រយោគថា វី នឹងចេះឯង ដូចអ្នកវង្វេង កណ្តាលអធ្រាតពុំនោះដូចខ្វាក់តែម្នាក់អាត្មាចរចេញយាត្រា ឥតអ្នកដឹកដៃ។ ត្រង់នេះខ្ញុំគិតថាប្រហែលជា បង តូចចិត្តនឹងជីវិត ខ្លួនឯងដែលបានរៀនសូត្រស្ទួចស្ទើងហើយមកធ្វើបដិវត្តន៍ដែលមានសភាពសឹងតែអាចនិយាយបានថាជាការល្ងង់ខ្លៅ ក្រៅវិស័យ ដូចជាក្រុមអ្នកវង្វេងកណ្តាលព្រៃជ្រៅយ៉ាងនោះឯង។ មានប្រយោគមួយនោះ ប្រហែលជាបងនឹកដល់អ្នកម្តាយ សៀន យ៉ាងខ្លាំងហើយ បង សរសេរថាកូនរស់មាន ម៉ែ ដូចឈើ ផ្លែលាក់សន្ទឹក កូនឃ្លាតអ្នកម្តាយ វែងរលីក វិស័យផ្កាយ ព្រឹកលែងរះ។ ពុទ្ធោអើយ! បងក៏នៅមានចំណែកបេះដូង ជាកូនមាសព្រលឹងរបស់អ្នកម្តាយ សៀន ដែរ ឱ!បងជាទីគោរពម្តេចក៏បងអភ័ព្វម្ល៉េះ។

## ចលនារត់ទៅព្រំដែនសៀម

ក្នុងអំឡុងចុងឆ្នាំ១៩៧៨ នេះចលនារត់ទៅព្រំដែនសៀមរបស់ប្រជាជនថ្មីដោយមានទាំងការចូលរួម ឬដឹកនាំពីសំណាក់យោធារំដោះខ្លះផង បានកើតមានជារឿយៗ។ មួយអាទិត្យមកហើយបាត់ ដំណឹងពី បង កន សូន្យឈឹង ពោរពេញដោយក្តីបារម្ភចំពោះសុវត្ថិភាពខ្លួនឯងថែមទៀត ព្រោះពេលនោះ ការវាយសម្លាប់ទាំងខ្សែៗ បំពេញរណ្តៅដែលមានទំហំធំៗប៉ុនស្រះរបស់អ្នកបដិវត្តន៍ មិនអាចលាក់បំបាំងពីភ្នែកម្នាស់របស់ប្រជាជន ១៧ មេសា បានឡើយ។

ខ្ញុំក៏ដាច់ចិត្តរត់ទៅរកព្រំដែនសៀមជាមួយនឹងមនុស្សមួយក្រុម។ យើងជួបនឹងការតាមស្ទាក់បាញ់ពីសំណាក់យោធាយើងបានរត់បាក់បែកគ្នាវង្វេងផ្លូវនៅលើភ្នំដងរែក។ នៅទីនោះ យើងបានដឹងថា មានមនុស្សជាច្រើនស្នាក់ពួនអាស្រ័យនៅហើយពពួកយោធារំដោះហាក់ដូចជាលែងសូវសាហាវស៊ីសាច់ហុតឈាម ដាក់យើងពេកហើយ។ ពួកគេគ្រាន់តែបាញ់ស្ទាក់មិនឲ្យយើងត្រឡប់មកសហករណ៍វិញតែប៉ុណ្ណោះ។ ខ្ញុំបន់ស្រន់សូម បានជួបនឹងបងកន ជាថ្មីឡើងវិញ ខ្ញុំ បារម្ភណាស់ខ្លាចតែមានរឿងមិនល្អកើតឡើងចំពោះគាត់។

កំពុងតែក្រាបលួនគេចវេះពីការដេញស្ទាក់ដែលខ្ញុំ ខំសម្ងំលួចរំពៃរកក្រែងលោទេវតាអាចដឹកដៃឲ្យជួបនឹ បង កន ម្តងទៀតយើងប្រទះនឹងទួលដំបូកដ៏ធំមួយនៅលើភ្នំ ដែល

មានកងទ័ពអង្គុយដំកង់ជុំវិញ ជើងដំបូកនោះ កំពុងកសាងកម្មាភិបាលយោធាម្នាក់ ដែលគេដាក់ឲ្យអង្គុយនៅលើទួលខ្ពស់បំផុតនៃដំបូក យើងលួចសម្លឹងរកមើលក្រែង ឃើញបងកន ផងនិងចង់ដឹងថាកម្មាភិបាលដែលគេកំពុងធ្វើសតិអារម្មណ៍នោះមានឋានៈជាអ្វី យើងផ្ទៀងត្រចៀកស្តាប់ពួកយោធាទាំងនោះនិយាយថា សមមិត្តយ៉ាន ឯងរត់ចោលសហករណ៍យ៉ាងនេះទោសត្រូវប្រហារជីវិត សមមិត្តដឹងស្រាប់ហើយ កង់ប្រវត្តិសាស្ត្របដិវត្តន៍មិនដែលអត់ទិនអភ័យទោសឲ្យខ្មាំងម្តងណាទេ សមមិត្ត ចង់រត់ចោលបដិវត្តន៍ សមមិត្ត គឺជាខ្មាំងតែដោយសភាពការណ៍ពេល នេះយើងកំពុងត្រូវការកម្លាំងរួបរួមគ្នាអង្គការ បានអនុញ្ញាតឲ្យយើងដូរទិសពីការសម្លាប់មកត្រឹមការកសាងសតិអារម្មណ៍ឲ្យតែសមមិត្តព្រមទទួលសារភាពកំហុស និងហ៊ានធ្វើសេចក្តីប្តេជ្ញាចិត្តចំពោះបដិវត្តន៍សាជាថ្មីមកចុះៗ ពុទ្ធោ គឺ ជាពូ យ៉ាន ប្រធានសហករណ៍យើងក៏រត់ដែរ សមមិត្តពូ យ៉ាន បានសារភាព និងធ្វើសេចក្តីប្តេជ្ញាចិត្តជូនអង្គការថា ខ្ញុំបាទសូមសារភាពពីកំហុសខុសឆ្គងរបស់ខ្ញុំបាទ ដែលចាញ់កលឃោសនាខ្មាំង ប៉ុនប៉ងរត់ទៅស្រុកសៀមតាមខ្មាំង បុគ្គលខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ និងចំពោះបដិវត្តន៍ដែល បានមិនត្រឹមតែលើក លែងទោសឲ្យបុគ្គលខ្ញុំប៉ុណ្ណោះទេ ថែមទាំងបានអនុញ្ញាតឲ្យខ្ញុំវិលត្រឡប់ទៅកាន់សហករណ៍វិញ រួមដៃបន្តកិច្ចការបដិវត្តន៍ឡើងវិញទៀតផង ប្តេជ្ញា! ប្តេជ្ញា! ខ្ញុំសូមប្តេជ្ញា!

យើងខំរំលាក់ខ្លួនចាកចេញពីទីនោះមកដោយខ្លាចពួកគេប្រទះនឹងយើង ខ្ញុំនៅតែមិនអស់ចិត្តសោះ ដែលនៅក្នុងចំណោមយោធាមួយក្រុមនោះ គ្មានបង កន ទេៗ វារចេញពីទីនោះប្រមាណកន្លះគីឡូម៉ែត្រ ពុទ្ធោ! ខ្ញុំទួញទ្រហោ ដោយក្តីចុកចាប់កកគាំង ទោះបីជាសាកសពនេះកំពុងពេញហើមក៏ខ្ញុំនៅតែស្គាល់ច្បាស់ថាជាបង កន ដែរ ទាំងទម្រង់កិនភាគ ទាំងសម្លៀកបំពាក់ ទាំងក្រមាក្រហមរបស់គាត់ ដែលខ្ញុំបានរៀបចំជូន ដំណើរចុងក្រោយរបស់គាត់គឺនៅស្រស់ៗណាស់ សាក់កាដូមួយនៅស្តាយដាប់ពីចំហៀងខ្លួនបង និងក្រដាសសៀវភៅមួយដុំប្រឡាក់ដោយឈាមជ្រះនៅជិតដៃបងមានទាំងស្លាបប៉ាកាមួយនៅក្បែរផង ទំនងជាបងដាច់ខ្យល់ស្លាប់ក្នុងពេលដែលបងក្តាប់វាក្នុងដៃ ហើយវាបានជ្រុះចេញ នៅពេលដែលសាកសពហើមឡើង ធ្វើឲ្យកណ្តាប់ដៃរលាចេញៗ

សៀវភៅ និងប៊ិករបស់បងជាវត្ថុដែលខ្ញុំចាប់អារម្មណ៍ជាងគេ ខ្ញុំចាប់រើសវាឡើង ខ្ញុំបើកទំព័រវាឡើង លិខិតកាព្យ ១បទ ដែលស្តីពីវិប្បដិសារីដ៏ធ្ងន់របស់បង វាមានអត្ថន័យកាត់ថ្លៃពុំបាន វាគឺជាចំណងចុងក្រោយដ៏ចុកចាប់ និងផ្អែមល្ហែមរបស់បងកនសម្រាប់អ្នកម្តាយរបស់គាត់និងក៏សម្រាប់ខ្ញុំក្នុងឋានៈជាប្អូនស្រីជីដូនមួយផង និងជាគូឥតវាសនាផងៗ

យើងមិនបានសម្រេចទិសដៅនៃដំណើរទេ យើងត្រូវកងយោធាមួយក្រុមភ្ជង់កាណុងបង្ខំឲ្យត្រឡប់មកសហករណ៍ដើមវិញៗ ខ្ញុំខិបដាប់នឹងដើមទ្រូង និងរក្សាទុកយ៉ាងខ្ជាប់ខ្ជួនដោយក្តីឈឺចុកចាប់រីងរៃនូវលិខិតកាព្យទាំងពីរបទរបស់បង កន ដែលខ្ញុំចាត់ទុកថាវាមានតម្លៃដូចគ្រាប់ពេជ្រសម្រាប់ជីវិតខ្ញុំ និងក្រុមគ្រួសារខ្ញុំៗ ខ្ញុំបន់ស្រន់សូមឲ្យស្រុកបានសាន្តត្រាណ ខ្ញុំនឹងបានវិលទៅស្រុកកំណើតវិញ នាំយកសារលិខិតបង កន ទៅជូនអ៊ំ សៀន ដែលខ្ញុំតែងតែចាត់ទុកថា ជាតួឯកនមោតាពិភពលោកប្រចាំដួងចិត្តខ្ញុំៗ មិនដឹងថាជាពាក្យស្តីបន្ទោសរបស់ខ្ញុំទៅលើបង វាចាក់ដោតស្មារតីបងឲ្យចុកចាប់យ៉ាងណាទេ រហូតដល់បងត្រូវប្រើប្រាស់ពេលវេលារៀបស្លាប់ផ្តាំចេញពីចរន្តលោហិតរបស់បងគាត់តែងនូវលិខិតកាព្យទាំងនេះទុកជាចំណងដៃដ៏ផ្អែមល្ហែមនិងជ្រាលជ្រៅរបស់បង ខ្ញុំមិនអាចបាត់បង់វាជាដាច់ខាតៗ ខ្ញុំរស់នៅពោរពេញដោយវិប្បដិសារីចំពោះរាល់អ្វីៗដែលខ្ញុំបានធ្វើទៅលើបងកនពុទ្ធោ! បង កន អើយ ខ្ញុំស្តាយណាស់ ប្រសិនបើនៅជិតគ្នា បងចេះនិយាយពាក្យទាំងនេះឲ្យខ្ញុំបានឮ ខ្ញុំពិតជាស្រឡាញ់ បងស្រឡាញ់ ស្រឡាញ់យ៉ាងស្មោះស្ម័គ្រស្មោះពេញដួងចិត្ត ខ្ញុំត្រូវខិបទុកនូវវិប្បដិសារីនេះពេញមួយជីវិតហើយ! ខ!គូឥតវាសនាខ្ញុំអើយ!

## ស្នូរកាំភ្លើងនៃអំណរសាទរ

នៅឯសហករណ៍ដូចជាគ្មានការប្រែប្រួលអ្វីទាំងអស់ ការសម្រុកកសាងនៅតែជា ផែនការដ៏នឹងនររបស់អង្គការ ដដែលៗ ស្នូរជួងម៉ោង៤ភ្លឺបន្លឺឡើងលាន់មួយបទហើយ ហ៊ុង ចុកក្រដាសត្រចៀកៗ

ងើបឡើងៗៗៗ បងប្អូនអើយៗភ្ញាក់ កុំស្ពឹកស្រពន់ទម្រន់ ស្ទុកដល់ណាទៀតៗ សម្រែកល្ហើយៗរបស់យាយមេការ កងចល័តប្រចាំសហករណ៍ភូមិថ្មីក្រកោះ គាត់ជាអ្នកជម្លៀស ថ្មីដែរ តែដោយមាននិស្ស័យនឹងអ្នកតស៊ូចាស់ គាត់បានទទួល ងារជាមេកងថ្មីៗ កសិករថ្មីដ៏មានដំណើរប៉ក់ល្ហើយទ្រេតទ្រោត ស្ថិតក្នុងសម្លៀកបំពាក់កណ្ដោចកណ្ដែង ស្ទើរជ្រៀកង្កៀត បានដើរចេញពីជម្រកខ្ទមស្បូវដ៏ទ្រុឌទ្រោម ទាំងរញីរញ៉ូវ មកតម្រង់ជួរពីមុខយាកាបទគោរពទង់ជាតិ ត្រូវបានចាក់ ឡើងតាមឃោសនសព្ទថា ក្រោកឡើងអស់ អ្នកក្រីក្រ ខ្ញុំគេ ទាំងប៉ុន្មាន ក្រោកឡើងៗ អស់អ្នកក្រីក្រតោកយ៉ាកគ្រប់ប្រាណ! តស៊ូនេះ ដើម្បីគ្រាចុងបំផុត អាំងទែរ ពណាស្យូណាល់ជា សង្គមអនាគតៗ

ខែមករា នៃរដូវវស្សា ឆ្នាំ១៩៧៩ យប់នេះវេលាម៉ោង ១យប់ វេនបោកស្រូវរបស់កងតូចខ្ញុំបានមកដល់មេកងក្រុម មុនបានដាស់មេកងក្រុមយើងឲ្យក្រោកឡើង ដើម្បីដាស់កូន ចៅខ្ជួនបន្តឲ្យងើបធ្វើការៗ នៅទីលានដែលមានចម្ងាយប្រមាណ ពាគីឡូម៉ែត្រពីថ្នល់ជាតិ ស្រាប់តែឃើញភ្លើងរថយន្តតូចធំ រាប់សិបគ្រឿងបើកក្នុងល្បឿនដូចហោះ ពីទិសខាងត្បូង ទៅ ជើង ដោយមានស្នូរកាំភ្លើងតូចធំបន្លឺឡើងពីខេត្តពោធិ៍សាត់ៗ រថយន្តបន្ទាប់បានឈប់ទំនងជាជួយមើលគ្នាប្រហែល១០នាទី រួចក៏បោលទៅមុខយ៉ាងលឿន តើមានហេតុអ្វីកើតឡើង? ឬ មួយមានការបែកបាក់ក្នុងជួរអង្គការ ឬមួយមានចលនារំដោះ ជាតិថ្មីផ្ទុះចេញពីណាមក? ទោះជាយ៉ាងណាក៏ប្រាកដជាគ្មាន



របបគ្រប់គ្រងណាអាក្រក់ដូចរបបនេះទេ ឱ! សូមឲ្យដួងព្រលឹងបុព្វបុរសទាំងអស់លោកកុំនៅស្ងៀមឡើយ សូមលោកជួយរុញច្រានឲ្យមានចលនាបដិវត្តន៍ថ្មីមួយមកដឹកឫសរំលីងគល់បដិវត្តន៍ទ្រុសក្បត់បែបនេះចេញឲ្យទៅឆ្ងាយទៅ។

ដាច់វេនបោកស្រូវនៅម៉ោង៣យប់ ទោះជាងោកងុយយ៉ាងណា ទោះជាមានការហែវហត់អស់កម្លាំងយ៉ាងណា ក៏ពួកយើងមិនអាចបិទភ្នែកសម្រាន្តបានឡើយយប់នេះ ហាក់មានកម្លាំងថាមពលអ្វីដ៏ចម្លែកមួយមានរិទ្ធិអំណាចអាចលើសកម្លាំងកាយកម្លាំងចិត្ត កងចល័តក្រកោះ យើងឲ្យរឹងប៉ឹងវិញបាន។ យើងបបួលគ្នាយកមុងទៅអូសត្រីតាម ស្នាមក្រោះបណ្តោយផ្លូវជាតិមើលក្រែងបានដឹងហេតុការណ៍អ្វីមួយ។

នៅក្បែររថយន្តបែកកង់នេះកងទ័ពមួយក្រុមដែលមានសម្លៀកបំពាក់ខ្មៅ បង់កក្រមាថ្មី មានសាច់ឈាមស្រស់ថ្លាទ្រលុកទ្រលន់កំពុងរិះរកមធ្យោបាយប៉ះកង់ឡានៗ ពួកគេប៉ះកង់ឡានបណ្តើរពិភាក្សាគ្នាបណ្តើរៗ យើងលួចស្តាប់មើលតើគេនិយាយគ្នាពីអ្វី។

យប់មិញនេះមានកប៉ាល់មុជទឹករបស់សូវៀតជាច្រើនបានងើបនៅទន្លេបួនមុខៗ សំឡេងកងយោធានិយាយគ្នា។ អំណរព្រឺព្រួចផុសចេញពីក្នុងពោះអ្នកអូសត្រីយើង ច្បាស់ជាមានការប្រែក្រឡាស់ហើយ ក្តីស្រមៃរបស់យើង ច្បាស់ជាក្លាយជាការពិតហើយ ទេវតាបានបរានូវរបបដឹកនាំដែលជាន់ឈ្លីដោតវាសនាប្រជាជាតិឯងក្នុងពេលនេះហើយមើលទៅ។ វាចាររបស់ក្រុមអ្នកអូសត្រី។

មិនយូរប៉ុន្មាន ចរន្តនៃលំហូរយោធាពីភូមិភាគនិរតីដែលគេស្គាល់ថាជាក្រុម និយាយរដឹន ចូលមកសមាហរណកម្មជាមួយនឹងយោធាពាយ័ព្យបានកើតឡើងដោយមិនប្រាប់មូលហេតុ។ ប្រជាជនថ្មីចាស់នៅខេត្តបាត់ដំបងទាំងមូល ក៏បានក្លាយទៅជាអ្នកភៀសខ្លួននៅក្នុងស្រុករបស់ខ្លួនឯង។

កងទ័ពរំដោះបានភ្ជង់កាំភ្លើង បង្ខំឲ្យប្រជាជនថ្មីឡើងភ្នំជាមួយខ្លួន ដើម្បីជារបាំងការពារនឹងការប្រយុទ្ធរបស់គូបដិបក្ខ។ ប្រជាជនពេលនោះសុទ្ធតែមានស្មារតីរត់ចេញបញ្ច្រាសទិសពីកងទ័ពបដិវត្តន៍ដែលមានពណ៌ខ្មៅតាំងពីសម្លៀកបំពាក់រហូតទៅដល់ចិត្តខាងក្នុង ហើយរង់ឲ្យចាំតែកងទ័ពថ្មីមកដល់នឹងសម្តែងនូវការអបអរសាទរ។

កម្ពុជាប្រជាធិបតេយ្យបានស្រាយទង់ប្រាសាទកំពូលបីនិងទង់បក្សកណ្តៀវ និងញញួររត់ខ្វាត់ខ្វាយទៅហើយ។ សាធារណរដ្ឋប្រជាមាណិតកម្ពុជាបានលើកទង់ប្រាសាទកំពូលប្រាំបង្ហូតឡើងឲ្យបក់រវេវិចៗ នៅថ្ងៃ៧ មករា ឆ្នាំ១៩៧៩។

ប្រជាពលរដ្ឋខ្មែរបានរំដោះផុតពីរបបគុកឥតជញ្ជាំង ៣ឆ្នាំ ៨ខែ ២០ថ្ងៃ តាមដងផ្លូវជាតិ ប្រជាជនមូលមីរព្រោងព្រាតខ្លះស្ពៀកមុង ខ្លះស្ពៀកភួយ ឬខោអាវជ្រៀកជ្រៀត រែកល្អី កញ្ច្រែង ចានក្បាន ធ្វើដំណើរថ្មើរជើងរាប់រយគីឡូម៉ែត្រវិលទៅលំនៅឋាន និងស្រុកកំណើតវិញ នៅរដ្ឋធានីភ្នំពេញ ទីផ្សារ វត្ត មន្ទីរពេទ្យ សាលារៀនដុះព្រៃទ្រុបទ្រុល គេហដ្ឋាននានា បាក់បែក របើកជញ្ជាំង របើកដំបូល ខ្លះឆេះរោលមើលមិនយល់។ រថយន្តខូចប្រងើងប្រងាង ត្រូវគេបោះបង់ចោលនៅតាមបណ្តោយផ្លូវឬទទឹងផ្លូវរប៉ាត់រប៉ាយគ្មានសណ្តាប់ធ្នាប់ ឱ!ទីក្រុងខ្មោច ទីក្រុងរហោឋាន ឱ!ភ្នំពេញជាទីស្នេហាអើយ ខ្ញុំបានជួបអ្នកវិញមានតែជញ្ជាំងថ្ម និងថ្នល់កៅស៊ូ គ្មានអ្វីហូបទេ យើងត្រូវតែបន្តដំណើរទៅស្រុកកំណើត ដើម្បីធ្វើស្រែយកស្រូវចិញ្ចឹមជីវិត យកបាយហូបឲ្យគ្រប់គ្រាន់កុំឲ្យការអត់ឃ្លានមកលងបន្លាចជីវិតយើងបានទៀត។ របបចង្ក្រានបាយរួមបានរលំរលាយទៅ ហើយយើងទទួលបានសិទ្ធិសេរីរស់នៅជួបជុំក្រុមញាតិ ក្នុងជីវិតមានកម្មសិទ្ធិឯកជនឡើងវិញហើយ។

ប៉ុន្មានខែក្រោយមក យើងបានត្រឡប់ទៅដល់ស្រុកកំណើតវិញ ពូ សន ត្រូវបានសម្លាប់ក្នុងរបបវាលពិឃាត ទៅហើយ តែអ៊ំ សៀន នៅមានជីវិតនៅឡើយ។ ជាមួយនឹងលិខិតកាព្យរបស់បង កន អ៊ំ សៀន បានប្រវាចាប់ឱបខ្ញុំក្នុងដើមទ្រូងដ៏កក់ក្តៅរបស់អ៊ំ ជាមួយនឹងក្តីសោកសង្រេងយ៉ាងតឹងដ្អឹះ អ៊ំយំមិនចេញទេ ទឹកភ្នែកអ៊ំបានកកគាំងយ៉ាងល្វីងជូរចត់។

យើងរស់ជិតអ៊ំរហូតមកដល់អំឡុងឆ្នាំ២០០៥ ពេលដែលច្បាប់ស្តីពីការបង្កើតតុលាការវិសាមញ្ញដើម្បីកាត់ទោស

អតីតមេដឹកនាំខ្មែរក្រហម ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ត្រូវបានអនុម័តិរោគាពាធបានមកសន្ទុំគ្របសង្កត់លើជីវិតអ៊ំ សៀន យ៉ាងធ្ងន់ធ្ងរក្នុងជន្មាយុ៧៩ឆ្នាំ។ អ៊ំបានសម្ដែងនូវសេចក្ដីសោកស្ដាយដ៏ធ្ងន់២ចំណុចៈ

ទី១ ចំពោះប្រការដែលអ៊ំមិនអាចបន្តនៅរង់ចាំលទ្ធផលនៃការកាត់ទោសនេះបាន

ទី២ ចំពោះករណីលោកឪពុកខ្ញុំដែលត្រូវខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧២ យ៉ាងព្រៃផ្សៃ និងបង គង់ ដែលត្រូវបានខ្មែរក្រហមវះពោះច្រកស្មៅ ក្នុងឆ្នាំ១៩៧៣ មិនបានស្ថិតនៅក្នុងដែនយុត្តាធិការ នៃច្បាប់កាត់ទោសខ្មែរក្រហមឡើយ នោះគឺជាប្រការដ៏សោកសៅបំផុត សម្រាប់ជីវិតចុងក្រោយនៃការបំពេញកាតព្វកិច្ចជាពលរដ្ឋ ក្នុងភ្នក់ភ្លើងសង្គ្រាម និងលើឆាកនយោបាយដ៏គ្រលិកគ្រលុកឥតន័យនេះ។ ពេលដែលដឹងខ្លួនថា មច្ចុរាជនឹងកាត់ផ្ដាច់យកជីវិតអ៊ំក្នុងពេលយ៉ាងខ្លីខាងមុខ អ៊ំបានទាញដៃខ្ញុំឲ្យខិនស្ដាប់សព្វទូន្មាន និងបណ្ដាំដ៏ពិស្ដាររបស់អ៊ំ។ ខ្ញុំអាចវិភាគបានថា ក្នុងអារម្មណ៍ និងដួងវិញ្ញាណអ៊ំ មានប្រធានបទដ៏សំខាន់ពីរដែលអ៊ំចង់ថ្លែងប្រាប់សកលលោកៈ

ទី១ អ៊ំចង់ប្រាប់ថា កូនប្រុសសម្លាញ់អ៊ំទាំងបី ដែលបម្រើឲ្យនិន្នាការមនោគមន៍វិជ្ជាពីរដែលប្រឆាំងគ្នានោះ ការពិត គឺមានទិសដៅតែមួយសោះ។ អ៊ំបានប្រៀបអ្នកបម្រើ មនោគមន៍ទាំងពីរនេះ ទៅនឹងសត្វទន្សាយ និងរាជសីហ៍ ដែលលង់ស្នេហាចំពោះព្រះចន្ទ្រាយ៉ាងងប់ងល់ ហើយច្បាំងតតាំងនឹងគ្នាដើម្បីដណ្ដើមយកព្រះចន្ទ្រាដែលជាសម្បត្តិចក្រវាឡទាំងមូលមកធ្វើជារបស់ខ្លួនតែម្នាក់ឯង ដែលក្នុងនោះក្ដីរំពឹងដ៏ដាក់លាក់របស់អ៊ំ គឺអ៊ំប្រាថ្នាចង់ឃើញតែការរួបរួមគ្នា និងការចេះសន្ដោសយោគយល់គ្នាប៉ុណ្ណោះ។

បន្ទាប់ពីការខិតខំរៀបរាប់នូវមេរៀនជីវិតដ៏ជូរចត់ ដែលអ៊ំចង់ចងក្រងជាដំបូន្មានដ៏ពិស្ដារនេះ អ៊ំមានអាការៈហត់ដង្ហក់បាត់មាត់ឈឹងទៅហើយ កូនចៅទាំងអស់ទ្រហោយំលាន់រំពងយើងគិតថា មច្ចុរាជបានផ្ដាច់យកសង្ខារអ៊ំឲ្យចាកចោលយើងទៅហើយ ប៉ុន្តែមួយសន្ទុះមកជីវិតអ៊ំប្រៀបបាននឹងអណ្ដាតភ្លើងចង្កៀងប្រេងកាត នៅពេលជិតអស់ប្រេងបានស្ទុះឆ្ពោរឡើង អ៊ំបានខិតខំប្រឹងដង្ហោយ ក្នុងសំឡេងខ្សាវៗហៅរកខ្ញុំឲ្យខិនចុះតាមត្រងត្រាប់បណ្ដាំអ៊ំជាថ្មីម្ដងទៀត អ៊ំសុំឲ្យគតិបណ្ឌិតនៃដួងព្រលឹងខ្មែរនៃផ្នត់ចិត្តគំនិត ផ្នត់វប្បធម៌ខ្មែរ គោលការណ៍ខ្មែរត្រូវបានថែរក្សា និងធ្វើសំយោគជាមួយនឹងវប្បធម៌ទំនើបយ៉ាងត្រឹមត្រូវប្រកបដោយគតិបណ្ឌិត។ អ៊ំបានដង្ហោយសុំឲ្យអ្នកជំនាន់ក្រោយជួយចងចាំ នូវអ្វីដែលបានធ្វើឲ្យកូនប្រុសទាំងបី របស់អ៊ំរងទុក្ខទោស ឲ្យចៀសវាង នូវអ្វីដែលជាកំហុសប្រវត្តិសាស្ត្ររបស់កូនសម្លាញ់ទាំងបីរបស់អ៊ំ និងឲ្យជួយស្ដាជញ្ជាត់ យកដួងព្រលឹងជាតិខ្មែរពិតៗ ដែលអ៊ំ ក៏ដូចជាបុព្វបុរសនារីដើម បានខិតខំស្ថិតស្ថាងសាងទុកមក។

បណ្ដាំមិនទាន់ចប់ស្រួលបួលផង មច្ចុរាជអើយអ្នកក្របួចយកជីវិតអ៊ំខ្ញុំទៅហើយ។ អ្នកម្ដាយអើយ ពេលនេះអ្នកលែងវិលមករកកូនស្រីវិញហើយ មានតែពាក្យពេជន៍អ្នកប៉ុណ្ណោះដែលកូនប្ដេជ្ញានឹងប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ជាពិសេសកូនចងចាំច្បាស់នូវអ្វីដែលជា សេចក្ដីឈឺចាប់របស់អ្នកម្ដាយទៅលើអ្វីដែលបានកើតឡើងចំពោះបងជីដូនមួយប្រុស ទាំងបីរបស់កូន។ អ្នកម៉ែ! អ្នកម៉ែសៀន! ស្ដាយណាស់ខ្ញុំទើបនឹងនិយាយពាក្យនេះចេញ នៅពេលដែលអ្នកម៉ែសៀនលាលោកទៅហើយ! អ្នកម្ដាយអើយ អ្នកម្ដាយដែលត្រូវសង្គ្រាមពុះទ្រូងរូងយកបេះដូង សួត ថ្លើម ប្រមាត់ មកចិញ្ច្រាំហែកពុះច្រៀកជាមួយរយចម្រៀកកូននឹងខិតខំត្រងត្រាបតាមដំបូន្មានអ្នកម្ដាយ ចៀសចេញឲ្យឆ្ងាយនូវអ្វីដែលជាការឈឺចាប់របស់ម៉ែ ហើយនឹងខំឲ្យអស់ ពីលទ្ធភាព សមត្ថភាព និងស្មារតីកូនដើម្បីប្រែក្លាយឆន្ទៈអ្នកម្ដាយឲ្យទៅរកការពិត។

## រស់រួសរករស់ រស់ដែលមិនមាយា រស់ក្នុងសុមារយាន និងសុឆន្ទៈ

ដើម្បីធ្វើខ្លួនជាកូនស្រីកត្តញ្ញូរបស់អ្នកម៉ែ សៀន របស់មាតាខ្មែរទាំងអស់ ក៏ដូចជា ក្រោមដំបូលនៃមនសិការរបស់

ស្ត្រីក៏ជាមាតាពិភពលោកទាំងមូលនេះ ដែលតែងចាត់ទុកបុត្រធីតាថាជា «ព្រលឹងមាសរបស់អ្នកម្ដាយ»នោះ ក្រោយការរស់ឡើងវិញ ពីរបបប្រល័យសាសន៍ឯង និងក្រោមឧបការគុណនៃមហាជោគជ័យ និងស្មារតី៧ មករា ១៩៧៩ មារយាទ ខ្ញុំបានជ្រើសរើសយក មុខរបរជាអ្នកអប់រំ។

ស្មារតី និងសុឆន្ទៈ ជាអ្នកបង្រៀនអក្ខរកម្មរបស់លោកឪពុកជាទីស្រឡាញ់របស់ខ្ញុំ ដែលដង្ហែតាមគោលនយោបាយ និងការអំពាវនាវរបស់ព្រះករុណាព្រះបាទ នរោត្តម សីហនុ កាលពីសម័យសង្គមរាស្ត្រនិយម នៅតែលាន់ឮរំពងក្នុងដួងចិត្តខ្ញុំ។ សកម្មភាពអុចបង្កៀងមាំងសុង បង្រៀនអក្ខរកម្មរបស់លោកឪពុក កូននៅតែស្ញើចសរសើរ និងចងចាំជាប់ក្នុងចិត្ត មិនអាចបំភ្លេចបានឡើយដរាបណា ចរន្តលោហិតរបស់អ្នកម៉ែ សៀន និងលោកឪពុក សាយ នៅតែរត់ក្នុងសារពាង្គកាយកូន ដរាបនោះ កូននៅតែរស់ក្នុងស្មារតី និងសុឆន្ទៈរបស់លោកឪពុក និងអ្នកម្ដាយជានិច្ច។

តាំងពីដើមឆ្នាំ១៩៧៩ មកការបួសរៀនបានចាប់ផ្ដើមឡើងវិញ យ៉ាងកក្រើករំពើក វិស័យអប់រំក្នុងសុឆន្ទះសង្គ្រោះមនុស្សចេញពីការល្ងង់ខ្លៅនេះ បានដំណើរការឡើង និងបោះជំហានយ៉ាងលឿនមុនវិស័យណាណាទាំងអស់នេះ ជាសច្ចធម៌ និងសុឆន្ទៈពិតៗរបស់អ្នករួចរស់ជីវិតពីរបបប្រល័យ



*សាសន៍ឯង ដែលយើងបន់ឲ្យតែមានឱកាសបម្រើជាតិតាមសុឆន្ទៈ យើងនឹងប្រឹងប្រែងចែករំលែកការចេះដឹង ការជួយសង្គមដោយឥតលាក់លៀមឡើយ។ ចាប់ផ្តើមតាំងពីពេលដែលបក្ស និងរដ្ឋទើបនឹងមានលទ្ធភាពផ្តល់ជូនលោកគ្រូ អ្នកគ្រូ នូវរបបអង្ករ តែ២០គីឡូក្នុងមួយខែម្ល៉េះ ខ្ញុំចាប់ផ្តើមដើរពីផ្ទះមួយទៅផ្ទះមួយសុំចុះឈ្មោះប្អូនៗកុមារឲ្យចូលទៅកាន់សាលារៀនវត្តស្ពោរបស់ខ្ញុំ សូម្បីតែសិស្សដែលគ្មានអាវពាក់ ក៏ខ្ញុំនៅតែខំលើកទឹកចិត្តគេឲ្យចូលរៀនដែរ។ មួយឆ្នាំក្រោយមក សិស្សប្រមាណ៦០នាក់ អាចអានបាន សរសេរបាន យ៉ាងលឿនមិនគួរឲ្យជឿបាន ព្រោះម៉្យាងពួកគេភាគច្រើនសុទ្ធសឹងតែមានអាយុច្រើនជាងអាយុដែលត្រូវចូលរៀនថ្នាក់ដំបូងផង និងម៉្យាងទៀត រាប់ថាជាសម័យភ្ញាក់រលឹកខ្លះមួយ ពីព្រោះថា ការចងចាំអំពីយុគងងឹតដ៏ខ្មៅអប្រិយ៍ នៃរបបប្រល័យពូជសាសន៍កំពុងតែនៅឆេះធំក្តៅគគុកក្នុងចិត្តពលរដ្ឋខ្មែរគ្រប់ស្រទាប់នៅឡើយ។ មាតាបិតាជាច្រើនបានថ្លែងពីសេចក្តីរីករាយ របស់ពួកគាត់ចំពោះកែវភ្នែកដ៏ភ្លឺថ្លា និងភ្លឺ-ស្វាងរបស់កូនចៅគាត់។*

*ក្រោមស្មារតីនៃកិច្ចព្រមព្រៀងក្រុងប៉ារីស និងក្រោមសុឆន្ទៈនៃការបង្រួបបង្រួមជាតិ បញ្ចៀសប្រជាជាតិខ្មែរពីសង្គ្រាមត្រដាក់ដ៏រាំរ៉ៃ រវាងជាតិសាសន៍ឯងនេះ រាជរដ្ឋាភិបាល និងព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងវិញនៅឆ្នាំ១៩៩៣ ជាឆ្នាំនៃកំណើតលើកទី២ នៃរបបរាជានិយម។ សិទ្ធិសេរីភាពនៃការបង្កើតអង្គការ សមាគមន៍ ត្រូវបានបើកទូលាយ។*

*១៣ឆ្នាំ ក្នុងជីវិតជាគ្រូបង្រៀន និង១៧ឆ្នាំ ក្នុងជីវិតជាអ្នកអប់រំអំពីតួនាទីយេនឌ័រ នៅក្នុងអង្គការក្រៅរដ្ឋាភិបាលដ៏មានអត្ថន័យមួយ គឺមជ្ឈមណ្ឌលសំឡេងស្ត្រីខ្មែរ ខ្ញុំ និងមិត្តរួមការងារទាំងអស់ យើងធ្វើដំណើរពីខេត្តមួយទៅខេត្តមួយ ពីស្រុកមួយទៅស្រុកមួយ ពីភូមិមួយទៅភូមិមួយ នាំយកនូវវីដេអូដែលផ្ទុកនូវសិល្បៈចម្រៀង កំណាព្យ រឿងកំប្លែងខ្លីៗ ដើម្បីធ្វើការអប់រំ និងបំផុសការចូលរួម ពីប្រជាពលរដ្ឋគ្រប់ស្រទាប់ តាមរយៈសំណួរ ចម្លើយស្តីពីសារៈសំខាន់នៃតួនាទីយេនឌ័រ រួមមានការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ និងរាល់ទម្រង់នៃអំពើរើសអើងលើស្ត្រី អំពើហិង្សាគ្រប់រូបភាពទៅលើស្ត្រី ត្រូវចាប់ផ្តើមពីខ្លួនយើងម្នាក់ៗឡើងទៅ។ ការប្រឹងប្រែងទាំងនេះ ពីព្រោះតែយើងមានការជឿជាក់លើគុណតម្លៃស្ត្រី យើងចង់ឃើញប្រជាពលរដ្ឋទាំងបុរស ទាំងស្ត្រី រស់នៅក្នុងគុណតម្លៃយេនឌ័រ រស់ដោយសុមារយាទ រស់ក្នុងឆន្ទៈ និងចាកផុតពីសភាពចាញ់កលមាយាជីវិតទេ។*

*ក្តីបារម្ភដ៏ធំបំផុតមួយទៀតរបស់មជ្ឈមណ្ឌលសំឡេងស្ត្រីខ្មែរ ក៏ដូចជាក្តីបារម្ភរបស់ អ្នកម្តាយលើពិភពលោកដែរ នោះគឺភាពងាយរងគ្រោះរបស់កូនស្រី។ ច្បាប់បុរាណបានចងច្បាប់ស្រីដោយខ្សែក និងច្បាប់ប្រុសដោយខ្សែក ប៉ុន្តែព្រលឹងមាសម្តាយ គឺជាច្បាប់នៃស្មារតីយេនឌ័រ ចង់ឃើញកូនស្រីបានរស់ក្នុងសេចក្តីសុខសាន្ត និងថ្លៃថ្នូរ ក្នុងនាមមជ្ឈមណ្ឌលសំឡេងស្ត្រីខ្មែរ យើងត្រូវតែអប់រំកូនប្រុសស្រី ទៅតាមស្មារតីស្របគ្នាមួយ ពោលគឺអប់រំតាមស្មារតីយេនឌ័រ ដែលកូនស្រីគួរតែមានស្មារតីរឹងប៉ឹងឡើង ពីព្រោះថាសិទ្ធិស្ត្រី គឺជាសិទ្ធិមនុស្ស សិទ្ធិទាំងអស់ ដែលបុរសទទួលបាន ស្ត្រីក៏ត្រូវតែទទួលបានដូចគ្នា ហើយកូនប្រុសក៏ត្រូវតែទទួលស្គាល់នូវតួនាទីសំខាន់របស់ស្ត្រី និងត្រូវតែដឹងថាការបៀតបៀន ហិង្សាទៅលើស្ត្រី គឺជាអំពើកំសាកហួសសម័យគួរឲ្យខ្មាស់អៀន ជាមាយាវាំងស្ទះការ អភិវឌ្ឍសង្គម និងអាចជាទោសឧក្រិដ្ឋដែលគួរឲ្យស្អប់ខ្ពើម។*

*ខែធ្នូ ឆ្នាំ២០០៨ កន្លងទៅនេះ យើងនាំយកកំណាព្យព្រលឹងមាសម្តាយ ទៅជូនបងប្អូនជនជាតិភាគតិចនៅខេត្តរតនគិរី។ ការរៀបចំសំណួរចម្លើយ បន្តឱកាសចូលរួមឲ្យយុវជន នារីបានចូលរួមវិភាគបកស្រាយ ហាត់គិតពិចារណាអំពីល្បិចកលបោកប្រាស់ក្មេងស្រី ដែលមនុស្សពាលប្រើ-ប្រាស់ក្នុងសម័យនេះឲ្យពួកគេយល់ដឹង និងចេះការពារខ្លួនទល់នឹងល្បិចកិច្ចកលទាំងនោះ។*

**អ៊ុង វណ្ណា**

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណៈជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណៈជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង មី បូរី តាមរយៈទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthborey.m@dccam.org។





















# រឿងគុកក្នុងគុក

## វគ្គ ១

នៅមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅភ្នំពេញ និងតាមបណ្តាខេត្តនានាគឺដូចគ្នា យើងឮសូរតែសំឡេងគ្រាប់កាំភ្លើងផ្ទោងចេញចូលស្ទើរគ្មានចន្លោះម៉ោងឡើយៗ ប្រជាជននាំគ្នានិយាយខ្សឹបខ្សៀវតៗគ្នា (ក្អែក១ ជាក្អែក១០) ថា បន្ទាប់ពីសង្គ្រាមចប់ ប្រទេសជាតិ និងសាន្តត្រាន្ត មានសុខសន្តិភាពប្រទេសលែងមានចម្បាំង និងសម្បូររុងរឿងៗ ទីបំផុតថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ក៏មកដល់ អ្វីៗដែលគិតថា ល្អប្រែរជាអាក្រក់រកស្មានមិនដល់ៗ ទាំងនេះហើយគឺការផ្លាស់ប្តូរទីក្រុងទាំងមូលធ្លាប់ស្រស់បំព្រង បែរជាស្ថិតក្នុងភាពងងឹតគ្មានពន្លឺនាពេលរាត្រីៗ ប្រជាជនចាប់ផ្តើម ចាកចេញពីក្រុងឆ្ពោះទៅទីជនបទតាមបញ្ជារបស់អង្គការនិងកងទ័ពអាវខ្មៅដោយមិនអាចប្តូរទិសបាន មិនអាចសុំអ្វីបានទាំងអស់ៗ អ្នកជំងឺដែលកំពុងសម្រាកក្នុងមន្ទីរពេទ្យក៏ត្រូវចាកចេញដែរ ហើយអ្នករឹងទទឹងត្រូវបានសម្លាប់ៗ ក្នុងចិត្តប្រជាជនជ្រួលច្របល់រកស្មានមិនត្រូវៗ គ្រួសារនីមួយៗរៀបចំខ្លួន ចាកចេញទាំងអារម្មណ៍តឹងណែន ភ័យខ្លាច ហើយម្នាក់ៗមិនអាចយកស្បៀងអាហារជាប់តាមខ្លួន លើសពីមួយសប្តាហ៍បានឡើយៗ ដំណើរឆ្ពោះទៅទីជនបទ តាមបញ្ជាអង្គការដោយគ្មានគោលដៅច្បាស់លាស់ឡើយៗ ពីធ្លាប់ប្រើទឹកម៉ាស៊ីនមកប្រើទឹកអណ្តូង ហើយអណ្តូងខ្លះមានខ្មោចស្លាប់ក្នុងនោះទៀតផងៗ ការប្រយុទ្ធគ្នារវាងយោធាខ្មែរក្រហម និងកងទ័ព លន់ នល់ កន្លងមកបានបន្សល់ខ្មោច ស្លាប់ហូរហែរមិនសូវដាច់នៅតាមផ្លូវៗ មនុស្សរាប់លាននាក់បានសម្រុកចាកចេញពីទីក្រុងឆ្ពោះទៅជនបទៗ រយៈពេលបីថ្ងៃកន្លងផុត អ្នកជម្លៀសនឹកគិតថានឹងបានត្រឡប់មកភ្នំពេញវិញតាមពាក្យឃោសនា ប៉ុន្តែខុសស្រលះៗ អង្គការបានកុហក និងដេញប្រជាជនទៅមុខរហូតគ្មានថ្ងៃ ត្រឡប់ក្រោយៗ

ពេលវេលាបានកន្លងផុតទៅគ្រួសារខ្ញុំបានធ្វើដំណើរមកដល់ភូមិក្រាំងធំ ឃុំបាក់រនាស់ ស្រុកត្រាំខ្នារ ខេត្តតាកែវៗ នៅទីនោះ ហើយដែលគ្រួសារខ្ញុំចាប់ផ្តើមស្គាល់ពាក្យបដិវត្តន៍ដូចជា មិត្ត សមមិត្ត មេកង អ្នក១៧មេសា អ្នកមូលដ្ឋានចាស់ អ្នកមូលដ្ឋានថ្មី មិត្តនារី មិត្តយុវជន កងចល័ត លត់ដំ នាយទុន...ៗលៗ ពាក្យខ្លះយើងធ្លាប់តែឮតែពេលនេះយើងយល់ពីន័យវាហើយ ចង់មិនចង់ត្រូវតែប្រើវាៗ យើងប្តូរពីធ្លាប់ប្រើទឹកម៉ាស៊ីន មកទឹកអណ្តូង ទឹកស្រះ ស្ទឹង បឹង ត្រពាំង កន្លែងខ្លះទឹកល្អក់ដូចទឹកដោះគោ ដូច្នេះត្រូវដង យកមកទុកឲ្យរងដើម្បីទទួលទាន ពីធ្លាប់ប្រើភ្លើងអគ្គិសនីមកប្រើចង្កៀងប្រេងកាតចន្លុះខ្លាញ់ត្រី...មិនបានមួយខែផង ប្រជាជនចាប់ផ្តើមអត់អាហាររកអ្វីថ្លៃងពុំបានៗ ពីទីនេះហើយដែលគ្រួសារខ្ញុំបានស្គាល់ពីវប្បធម៌សិល្បៈចម្រៀងបែបបដិវត្តន៍ៗ

មានយប់មួយក្នុងភូមិមានការជួបជុំបែបក្មេងៗក្នុងភូមិនារាត្រីខែភ្លឺ ម្តាយខ្ញុំឲ្យបងប្អូនខ្ញុំទៅមើលៗ យើងឃើញក្មេងប្រុសស្រីក្នុងសម្លៀកបំពាក់ខោខ្មៅ អាវខ្មៅ ច្រៀងចម្រៀងបដិវត្តន៍ក្នុងកាយវិការរឹងៗ លោតៗ លើកដៃបោះទៅលើបែបប្តេជ្ញាចិត្ត ហើយស្រែះគ្នាៗ យើងឮសូរតែពាក្យ ឈាមក្រហមយុទ្ធមិត្ត ពលី...ៗលៗ យប់នោះមានបទច្រើន ដែលខ្ញុំមិនដែលឮ រីឯចង្វាក់ក៏ខុសៗគ្នាដែរ គ្មានទេបទបែបប្រពៃណី ឬសង្គមសេរី ខ្ញុំនៅបន្តមើលរហូតជិតចប់ទើបត្រឡប់មកផ្ទះវិញៗ មកដល់ផ្ទះម្តាយខ្ញុំសួរបងស្រីខ្ញុំថា តើសិល្បៈគេយ៉ាងម៉េចដែរ បងខ្ញុំឆ្លើយថា មិនដឹងយ៉ាងណាទេ មិនចេះមើល ស្តាប់មិនចូលត្រចៀកទេៗ សិល្បៈមានតែក្មេងៗទេដែលទទួលបានលឿន បើក្មេងៗដូចខ្ញុំ និងបងៗខ្ញុំទទួលមិនបានផង ម្តាយឪពុកខ្ញុំកាន់តែមិនអាចទទួលយកបានទៀតៗ

បីខែកន្លងផុតទៅការអត់អាហារ ក៏កាន់តែខ្លាំងឡើងៗ កុំថាឡើយអ្នក១៧មេសា សូម្បីអ្នកមូលដ្ឋានចាស់ក៏ចាប់ផ្តើម

អត់ស្បៀងអាហារដែរ។ អង្គការខ្មែរក្រហមចាប់ផ្ដើមផ្ដល់អង្ករស បន្ទាប់មកអង្ករក្រហម បន្ទាប់មកស្រូវសាលី ហើយអស់ពីស្រូវសាលី ផ្ដល់ពោតដំនួសអង្ករ។ ប្រជាជនមិនថាក្មេងចាស់មានជំងឺឈឺស្លាប់ជាបណ្ដើរៗ ជីដូនខ្ញុំក៏បានទទួលវាសនាដូចគ្នានឹងប្រជាជនទូទៅដែរ គឺទទួលរងនូវភាពអត់អាហារ ហើយក៏មានជំងឺឈឺស្លាប់នៅភូមិនោះតែម្ដង។ ពិត-មែនហើយ បន្លែគឺជាអាហារផ្ដល់ជីវជាតិដើម្បីទ្រទ្រង់រាងកាយតែបើគ្មានត្រីសាច់ អង្ករ អំបិលស្ករទេ យើងក៏ពិបាករស់ដែរ។ ពេលនោះយើងត្រូវយកផ្ទីបន្លា ស្លឹកដំឡូងមី ទំពាំងមកទទួលទានបន្គ្រប់ដើម្បីចម្អែតក្រពះ។ ចំណែកអង្គការគិតតែពីបង្ខំប្រជាជនឲ្យធ្វើការ អ្នកមិនចេះធ្វើការងារស្រែចម្ការចាត់ទុកថា ជានាយទុន សក្តិភូមិ និងត្រូវបានសម្លាប់។ មានពេលមួយ អង្គការរៀបចំធ្វើមីទ្ទីងធំរយៈពេលបីថ្ងៃនៅវត្តបាក់រនាស់ ដើម្បីផ្សព្វផ្សាយពីគោលនយោបាយបដិវត្តន៍។ ខ្ញុំនៅក្មេងស្ដាប់មិនចូលទេ ដឹងតែពីឃ្លានបាយ។ ពេលនោះចុង-ភៅដាំបាយឲ្យហូប សម្រាប់មនុស្សរាប់ពាន់នាក់ដែលកំពុងតែអត់បាយ ក៏ដណ្ដើមបាយគ្នាហូប។ ខ្ញុំនិងអ្នកទាំងនោះគ្មានអ្វីខុសគ្នាទេ គឺដណ្ដើមគ្នាដូចបោះបាយបិណ្ឌឲ្យនរកប្រេតនាពេលភ្ជុំបិណ្ឌ។

ថ្ងៃនេះជាថ្ងៃ១៧ មេសា ២០១៦ ខ្ញុំនឹកឃើញថ្ងៃនោះមិនគួររស់មកដល់ថ្ងៃនេះទេ។ អ្នកដែលរស់មកដល់សព្វថ្ងៃពិតជាទឹកដោះម្ដាយថ្លៃឬជាមនុស្សអច្ឆរិយៈ។ ប្រជាជនដែលជន្លៀសពីភ្នំពេញច្រើនមិនអាចធ្វើដំណើរបានឆ្ងាយទៅដល់គោលដៅដែលអង្គការកំណត់ចង់បានឡើយ ដូច្នេះ ត្រូវដឹក



ទុយ វណ្ណារ័ត្ន

ជញ្ជូនចេញពីតំបន់ដែលមានមនុស្សច្រើនទៅកាន់តំបន់ដែលពុំសូវមានមនុស្ស គឺពីភូមិភាគនារតីទៅកាន់ភូមិភាគពាយ័ព្យ។ ចេញពីភូមិក្រាំងធំ យើងបានធ្វើដំណើរកាត់តាមដើងភ្នំស្រង់ ឃើញទេសភាពដើងភ្នំនាពេលព្រលប់មានអាប់ អាកាសធាតុក៏ត្រជាក់មើលទៅគួរឲ្យត្រជាក់ចិត្តណាស់។ ផ្ទុយទៅវិញបែរជាធ្វើឲ្យអារម្មណ៍ក្នុងចិត្តម្នាក់ៗ មិននឹងន មិនដឹងជាអង្គការយកទៅទីណា ម្នាក់ៗលួចខ្សឹបប្រាប់គ្នាថាគេឲ្យយើងត្រឡប់ទៅភ្នំពេញវិញ ការពិតគ្មាននរណាម្នាក់ដឹងឡើយ។

យើងទាំងអស់គ្នាក៏បានមកដល់ផ្លូវជាតិលេខ៤ ហើយរង់ចាំប្រហែលពាថ្ងៃទើបមានរថយន្តយោធាដែលមានដំបូលតង់បិតជិតមានតែទ្វាររូតនិងបង្អួចសម្រាប់អ្នកជិះចូលអង្គុយមកទទួល។ យើងធ្វើដំណើរតាមផ្លូវជាតិលេខ៤ឆ្ពោះមកភ្នំ-ពេញឆ្លងកាត់ពោធិចិនតុង តាមផ្លូវសហព័ន្ធរុស្ស៊ីមកដល់ស្តុបទួលគោក ឪពុកខ្ញុំបានលើកខ្ញុំឲ្យមើលតាមបង្អួចរថយន្ត។ ខ្ញុំសម្លឹងមើលមកផ្លូវកម្ពុជាក្រោមត្រង់ស្តុបសាលាសន្ធរមុខជាសាលាដែលខ្ញុំធ្លាប់រៀន យើងឃើញមានតែយោធាពីរនាក់ដើរបណ្តើរឆ្កែរមួយក្បាល មើលទៅគួរឲ្យខ្លាចផ្សារណាស់ ហាក់បីដូចទីក្រុងខ្មោចៗ ធ្វើដំណើរតាមផ្លូវសហពន្ធ័រុស្ស៊ី បត់ទៅមុខមន្ទីរពេទ្យកាល់ម៉ែត្រ តាមក្រោមស្ពានជ្រោយចង្វារតាមផ្លូវជាតិលេខ៥ ឆ្លងកាត់ភូមិស្រុកជាច្រើននៃខេត្តកណ្តាលនិងកំពង់ឆ្នាំង គ្រួសារខ្ញុំក៏មកដល់ខេត្តពោធិ៍សាត់។ មកដល់ពោធិ៍សាត់ យើងឃើញមានរថយន្តយោធាច្រើនរយគ្រឿងដែលដឹកអ្នកជន្លៀសមកកាន់ទីនេះ។

ពេលឃើញទេសភាពស្ទឹងពោធិ៍សាត់ ដំបូងនាខែវស្សាខ្ញុំរំភើបចិត្តណាស់ចង់ទៅឈរជិតមាត់ស្ទឹង តែត្រូវម្តាយខ្ញុំឃាត់ខ្លាចធ្លាក់ទឹក។ ខ្ញុំនិងបងខ្ញុំឈរពីត្រើយម្ខាងសម្លឹងមើលទៅត្រើយម្ខាងទៀត ឃើញអ្នកនេសាទកំពុងបង់សំណាញ់ខ្លះឈរលើក្បាលទូកយកថ្នាំងធំមកដងត្រី ហើយពេលលើកឡើងម្តងៗ យើងឃើញបានត្រីរៀលត្រីលិញម្តងពី១០ទៅ១៥ក្បាល។ សម័យនោះស្ទឹងពោធិសាត់សម្បូរត្រីណាស់ ជាង៤០ឆ្នាំទៅហើយ ខ្ញុំនៅតែចងចាំមិនភ្លេចៗ រយៈពេលជាង៣ខែហើយដែលខ្ញុំមិនដែលបានទទួលទានត្រីស្រស់ហូបៗ ខ្ញុំក៏មិនដឹងថាម្តាយរបស់ខ្ញុំបានត្រីនោះមកហូប ដោយការទិញដូរយ៉ាងណាដែរ ព្រោះការលក់ដូរគ្មានទេពេលនោះ។

គ្រួសារខ្ញុំ ស្នាក់នៅទីរួមស្រុកបាកាន ខេត្តពោធិ៍សាត់ជិតមួយសប្តាហ៍រង់ចាំអ្នកភូមិយករទេះមកទទួល យើងគ្មានជម្រើសទេ ព្រោះយើងមិនដែលស្គាល់ភូមិសាស្ត្រទីនោះច្បាស់ តែឪពុកម្តាយខ្ញុំបានលួចសួរអ្នកភូមិចាស់ៗទីនោះថា តើទៅនៅភូមិណាដែលសម្បូរស្រូវអង្ករ ត្រីសាច់ជាងគេ? អ្នកភូមិប្រាប់ថាមានភូមិមួយគឺភូមិក្បាលឈើពុក ភូមិនោះសម្បូរជាងគេ តែថៃដន្យភូមិនោះអាចទទួលបានតែ១គ្រួសារប៉ុណ្ណោះ។ គ្រួសារខ្ញុំមានគ្នាដល់ទៅ២០នាក់ដូច្នេះត្រូវបំបែកជាពីរគ្រួសារ ឲ្យម្តាយមីង និងពូៗខ្ញុំទៅភូមិក្បាលឈើពុកនោះ ហើយគ្រួសារខ្ញុំទៅភូមិក្បែរនោះគឺភូមិព្រៃស្រគុំ ហើយពេលទឹកទន្លេធំឡើងម្តងៗជិតដល់ដូចគ្នា។ យើងចេញពីទីរួមស្រុកដោយជិះរទេះគោអ្នកភូមិ ផ្ទុកឥវ៉ាន់ពេញ ឥវ៉ាន់នៅសល់បង និងឪពុកម្តាយខ្ញុំទូល ខ្លះរែក យើងធ្វើដំណើរទៅដល់ភូមិប្រហែលម៉ោង៤ល្ងាច យើងស្នាក់នៅផ្ទះអ្នកភូមិ១រយៈទើបប្រធានកងចាត់ចែងរកផ្ទះឲ្យនៅផ្សេងៗគ្នា។

## វគ្គ ២

មកដល់ភូមិព្រៃស្រគុំដំបូង អ្វីៗហាក់ស្រស់ថ្មោះជាងកាលនៅខេត្តតាកែវ ទាំងធម្មជាតិនិងដំណាំហូបផ្លែ តែក៏ខុសរដូវកាលគ្នាដែរ។ កាលយើងទៅភូមិក្រាំងធំ ខេត្តតាកែវចំពេលរដូវប្រាំង តែពេលនោះជារដូវវស្សា យើងឃើញផ្លែដូងទុំ និងក្រូចឆ្មារជ្រុះពេញក្រោមដើម ហើយយើងរើសយកទៅញាំមិនអស់ រួមទាំងបន្លែស្លឹកបាស ផ្លែននោងៗល។ ត្រី ខ្យងក្តាមតាមស្រែក៏សម្បូរ បើប្រៀបធៀបទៅនឹងខេត្តតាកែវ។ ដំបូងអ្វីក៏ល្អជាងភូមិក្រាំងធំ ខេត្តតាកែវដែរ តែលុះបានបន្តិចក្រោយមក គឺដូចតែគ្នា ព្រោះយើងស្ថិតក្រោមការគ្រប់គ្រងរបបអាវខ្មៅតែមួយ។ ការបង្អត់អាហារ ការស៊ីរួម ដេករួម ការបង្ខំធ្វើការជាទំងន់ ការបែងចែកកុមារ យុវជន ចាស់ៗចាស់ជរាឲ្យនៅដាច់ពីគ្នា ការគៀបសង្កត់ស្មារតី សិទ្ធិសេរីភាព

ជំនឿសាសនា គ្រប់បែបយ៉ាងក៏បានកើតឡើងដែរ។ ឋានៈត្រឹមតែប្រធានកង ប្រធានភូមិ មានសិទ្ធិអំណាចយកមនុស្សទៅសម្លាប់បានដោយគ្មានការជំនុំជម្រះ។ មានពាក្យមួយដែលអង្គការតែងតែរំឭកប្រជាជនថា «ត្រូវដាំដើមគ» ខ្ញុំនៅក្មេងឮពាក្យទាំងនេះយល់តិចណាស់ ម្តាយខ្ញុំប្រាប់ថាកុំនិយាយអីផ្តេសផ្តាស់។

ការលំបាកពីមួយថ្ងៃទៅមួយថ្ងៃចេះតែកើនឡើង គឺគ្មានថ្ងៃថយឡើយ។ គ្រួសារនីមួយៗត្រូវបែងចែកតាមវ័យ រស់នៅជាក្រុម ជាកង ខ្ញុំត្រូវរស់នៅដាច់ពីឪពុកម្តាយ នៅកងកុមារ ចំណែកបងៗខ្ញុំនៅកងចល័ត។ ដំបូងអង្គការចាត់តាំងឲ្យខ្ញុំឃ្វាលគោ លុះគោដាច់ចំណងក៏មិនចំណាំថាមួយណាជារបស់ខ្លួនដែរ ព្រោះមើលទៅគោដូចៗគ្នា។ មានការងារបន្តបន្ទាប់មិនចេះខ្វះទាំងប្រាំង ទាំងវស្សា ការងារធំៗបំផុតរបស់អង្គការគឺ លើកទំនប់ ជីកប្រឡាយ ធ្វើស្រែ ច្រូតស្រូវ។ ម្នាក់ត្រូវតែបញ្ចេញកម្លាំងឲ្យអស់ពីខ្លួន បើលាក់ពុតក៏ត្រូវបានអង្គការយកទៅធ្វើទារុណកម្មឬសម្លាប់ដែរ។ ការពោលពាក្យដឹងដល់អង្គការក៏ត្រូវបានសម្លាប់។ ម្តាយខ្ញុំប្រាប់ខ្ញុំថា មានមនុស្សម្នាក់ពោលពាក្យ (ធ្វើស្រែប្រវាស់មេឃស៊ីបាយ ធ្វើស្រែប្រវាស់ប្រលាយស៊ីបបរ) នោះក៏ត្រូវបានយកទៅសម្លាប់ដែរ។

### វគ្គ ៣

ប្រជាជនក្នុងភូមិនីមួយៗ ខំប្រឹងរស់រង់ចាំតែសេចក្តីស្លាប់ អង្គការមិនខ្វល់នឹងការដែលមានមនុស្សស្លាប់ទេ។ ការស្លាប់នៅសម័យនោះមានច្រើនបែប ប៉ុន្តែភាគច្រើន គឺស្លាប់ដោយការចោទថាជាអ្នកក្បត់អង្គការ ហើយយកទៅសម្លាប់ និងអត់អាហារ បាក់កម្លាំង ឈឺស្គមរីងរៃ គ្មានថ្នាំព្យាបាល ដូចបងប្រុសខ្ញុំម្នាក់ គ្រោះថ្នាក់ធ្លាក់ពីលើដើមឈើបាក់ជើង ហើយគ្មានថ្នាំព្យាបាលក៏ស្លាប់ទៅ។ គ្រួសារខ្ញុំបានស្លាប់ បាត់បង់ជីវិតសមាជិកអស់ចំនួន ៨នាក់ ក្នុងចំណោម ១៩នាក់ ហើយក៏ជាសោកនាដកម្មមួយ ដែលប្រជាជនខ្មែរផ្សេងទៀតបានជួបប្រទះ និងមិនអាចបំភ្លេចបានដែរ។ អ្វីដែលខ្ញុំនៅចងចាំមិនភ្លេចនាសម័យនោះគឺទុក្ខធ្ងន់ធ្ងរ។ នៅគ្រាមួយវេលាថ្ងៃត្រង់ជាពេលសម្រាកពីពលកម្ម បងស្រីខ្ញុំខ្ចីស្បៃមុងអ្នកភូមិបាន ក៏បបួលខ្ញុំទៅរកត្រី។ យើងក៏ដើរ អូសពីកន្លែងមួយទៅកន្លែងមួយ លុះទៅដល់កន្លែងមួយឃើញមានមាត់ត្រីច្រើន ក៏នាំគ្នាចុះអូសដោយគ្មានខ្វល់អ្វីទាំងអស់ ប៉ុន្តែត្រចៀកយើងផ្ទៀងស្តាប់តែសំឡេងជួងដល់ម៉ោងធ្វើពលកម្ម យើងនឹងប្រញាប់មកធ្វើការវិញ។ មិនទាន់ដល់ម៉ោងផង យើងឃើញកងយោធាពីរនាក់ដើរតាមខ្នងប្រឡាយមកដល់សួរយើងថា ម៉េចមិត្តឯង អូសត្រីក្នុងស្រែ? បងខ្ញុំនិងខ្ញុំហាក់មានអារម្មណ៍ភ្ញាក់ព្រឺត ព្រោះអូសត្រីក្នុងស្រែធ្វើឲ្យខូចស្រូវអង្គការ។ បងខ្ញុំឆ្លើយថាកន្លែងនេះទឹកជ្រៅសន្ទូងរលួយអស់ហើយ យោធានោះថែមទៀតថាបន្តថា មកពីមិត្តឯងអូសត្រីបានជាស្រូវគេងាប់



និងសួរប្អូនឯងនៅភូមិណា? ខ្ញុំក៏ចង្អុលទៅភូមិព្រៃស្រគុំៗ យោធា នោះបាននិយាយថា ប្អូនឯងទាំងពីរគេចវេសពលកម្ម ធ្វើឲ្យខូចស្រូវត្រូវយកទៅមន្ទីរសន្តិសុខកែប្រែពីរបីថ្ងៃ។ បងខ្ញុំប្រកែក អត់ទេបងខ្ញុំទៅធ្វើការឥឡូវហើយ មិត្តថាទេទៅជាមួយ ខ្ញុំទុករបស់នៅទីនេះហើយដោយស្ពាយត្រីផង ហើយមុងអូស ក៏ជារបស់ខ្ទីគេ ទើបបងខ្ញុំ និងខ្ញុំមិនបានធ្វើតាមកងយោធា។ យើងកាន់មុងអូសមកតាម ហើយឈៀងចូលយកមុងផ្ញើរសងគេវិញ។ យើងទាំងពីរដើរតាមយោធាទាំងពីរនាក់ទាំង អារម្មណ៍ភ័យព្រួយ។ យើងដើរបណ្ដើរ ហើយពេលជួបអ្នកស្គាល់ក៏ផ្ដាំផ្ញើឲ្យជួយផ្ដល់ដំណឹងដល់ម្ដាយខ្ញុំ ព្រោះយើងទាំងពីរនាក់ត្រូវកងសន្តិសុខយកទៅមន្ទីរសន្តិសុខពីរបីថ្ងៃ។

យើងធ្វើដំណើរឆ្លងកាត់ភូមិធ្លកភូមិក្បាលឈើពុក ឆ្ពោះទៅមន្ទីរសន្តិសុខ។ យើងដើរលើភ្លឺស្រែ ហើយកន្លែងខ្លះទឹកហូរដាច់ភ្លឺស្រែ យើងក៏ឆ្លងកាត់ទឹកទទឹកស្ទើរពាក់កណ្ដាលខ្លួនទៅហើយ ទើបដល់មន្ទីរសន្តិសុខ។ មន្ទីរសន្តិសុខនោះគឺជាវត្តដែលមានឈ្មោះថា វត្តលោកយួន។ យើងទៅដល់ទីនោះប្រហែលម៉ោង៤ល្ងាច កងយោធានិយាយថា នៅទីនេះសិនហើយ ខ្ញុំគ្មានវាចាអ្វីទាំងអស់គឺធ្វើតាមតែបញ្ជា។ មួយសន្ទុះក្រោយមក យោធាក៏បញ្ជាខ្ញុំ និងបងខ្ញុំឲ្យធ្វើការ។ ការងារក្នុងមន្ទីរឃុំឃាំង និងក្រៅមន្ទីរឃុំឃាំងគ្មានអ្វីខុសគ្នាទេ ព្រោះប្រជាជនខ្មែរនាសម័យនោះទូទាំងប្រទេស រស់នៅក្នុងគុកឥតជញ្ជាំងស្រាប់ទៅហើយ។ ការងារនោះ គឺយើងយកដីដំបូកមកដំឲ្យល្អិតម៉ត់លាយជាមួយអាចម៍គោ និងដើមទន្ទ្រានកន្ទ្រៀងខែត្រសម្រាប់ធ្វើជីរដាក់ស្រែ និងដំណាំបន្លែ។



នៅក្នុងមន្ទីរសន្តិសុខ យើងឃើញមានមនុស្សក្មេង ចាស់ ប្រុស ស្រី នៅធ្វើការលាយឡំគ្នាមិនប្រកាន់ការងារដូចខាងក្រៅគុកឡើយ។ យើងនាំគ្នាធ្វើយ៉ាងម៉ត់ចត់មិនប្រកាន់ការងារចាស់ក្មេង ហើយដល់ម៉ោងបាយល្ងាចយើងក៏ទៅហូបរួមគ្នា រីឯរបបអាហារក៏គ្មានអ្វីខុសគ្នានៅក្រៅគុកដែរ គឺពេលខ្លះទទួលបានបបររាវ ហើយពេលខ្លះទៀតទទួលបានបបរខាប់បន្តិចៗ លុះទទួលទានអាហាររួចហើយ អារម្មណ៍ខ្ញុំហាក់ចាប់ផ្ដើមភ័យ មិនដឹងថាយប់ទី១នេះត្រូវដេកក្នុងគុកនេះដោយរបៀបណាទេ ម្យ៉ាងនឹកដល់ឪពុកម្ដាយនៅឯផ្ទះមិនដឹងថាគាត់បានដឹងថា កូនៗនៅក្នុងគុកនេះឬទេ។ អារម្មណ៍មិនល្អនាំឲ្យយើងនឹកដល់រឿងអាក្រក់ៗដែលនឹងកើតឡើងនៅយប់នេះ។ ក្រោយមកកងយោធាក៏ដើរសំដៅមករកខ្ញុំ (ត្រង់ចំណុចនេះខ្ញុំហាក់ដូចជាភ្លេច តែខ្ញុំនៅចាំបានថាកងយោធាមានហុចរបស់មួយមកខ្ញុំ មិនដឹងថាជាខោអាវសម្រាប់អ្នកទោសឬក៏របស់អ្វីទេ ព្រមទាំងនិយាយថា អ្នកទាំងពីររកកន្លែងដេកនៅទីនេះព្រមទាំងលើកដៃចង្អុលទៅកុដិឈើមួយ រួចហើយក៏ដើរចេញទៅ)។ ខ្ញុំឈរសម្លឹងមើលកុដិដោយអារម្មណ៍អល់អែក មិនហ៊ានចូលទេ បងស្រីខ្ញុំដើរចូលទៅមុន រួចក៏ចេញមកវិញ ប្រាប់ខ្ញុំថានៅខាងក្នុងមានមនុស្ស (អ្នកទោសច្រើន) ណាស់។

ពុដូច្នេះអារម្មណ៍ភ័យខ្លាចរបស់ខ្ញុំរឹតតែកើនឡើង ព្រោះកុដិទាំងមូលមើលពីខាងក្រៅហាក់គ្មានមនុស្ស ចុះហេតុអ្វីក៏មានអ្នកទោសច្រើនបែបនេះ។ លុះព្រលប់បន្តិចទើបខ្ញុំនាំគ្នាចូល។ ថ្ងៃបន្ទាប់មកទើបដឹងថាមានអ្នកទោសធ្ងន់និងអ្នកទោសស្រាលនៅទីនោះ។ ខ្ញុំក៏មិនដឹងថា ការចាត់ថ្នាក់ទោសធ្ងន់ ឬស្រាលមានលក្ខណៈបែបណាដែរ គ្រាន់តែដឹង ថាក្នុងកន្លែងឃុំឃាំងតែមួយ មានខ្លះជាប់ខ្នោះជើងទាំងថ្ងៃទាំងយប់ អ្នកខ្លះជាប់ខ្នោះតែពេលយប់ ហើយពេលថ្ងៃចេញក្រៅធ្វើការបាន។ អ្នកទោសខ្លះទៀតអត់ជាប់ខ្នោះទេ ខ្ញុំនិងបងស្រីខ្ញុំក៏មិនបានជាប់ខ្នោះដៃខ្នោះជើងដែរ។ ទោះជាប់ឬមិនជាប់ខ្នោះក៏ដោយក៏អ្នកទោសទាំងអស់ ព្រោះពេលយប់ស្ថិតក្នុងកុដិឃុំឃាំងតែមួយ និងមានបម្រាមតែមួយ គឺហាមមិនឲ្យចេញបន្ទោរបង់នៅខាងក្រៅកន្លែងឃុំឃាំងដាច់ខាត ទោះចង់ចេញក៏មិនបាន ព្រោះកុដិត្រូវបានចាក់សោរយ៉ាងរឹងមាំ ការបន្ទោរបង់គឺមាននៅចំកណ្តាលកុដិនោះតែម្តង។

## វគ្គ៦

នៅក្នុងមន្ទីរឃុំឃាំងនេះ បានរយៈពេលពីរយប់បីថ្ងៃ ខ្ញុំស្គាល់ភូមិសាស្ត្រនៅទីនេះបានខ្លះ ហើយយើងចាំមិនភ្លេចផ្លូវដែលកងយោធាយកយើងមកទីនេះ។ បន្ទាប់មក ខ្ញុំក៏បានស្គាល់អ្នកទោសម្នាក់ទៀត ជាក្មេងអាយុប្រហែលខ្ញុំដែរ តែក្មេងនោះមើលទៅជាក្មេងរហ័សរហួនជាងខ្ញុំ ហ៊ានជាងខ្ញុំ ប៉ុន្តែយើងទាំងពីរមានរូបរាងស្គមដូចគ្នា។ ខ្ញុំសួរក្មេងម្នាក់នោះថាហេតុអ្វីមកជាប់នៅទីនេះ? ក្មេងនោះឆ្លើយថា គាត់មិនធ្វើការក៏ទៅចាប់ត្រីនៅក្បាលហុងក៏ត្រូវកងយោធាចាប់យកមកទីនេះតែម្តង (ក្បាលហុងគឺជាទំនប់ទឹកដ៏ធំ១របស់ស្ទឹងពោធិសាត់នាសម័យ ប៉ុល ពត ដែលទីនោះ ខ្ញុំស្គាល់ច្បាស់ដែរ)។ បន្ទាប់មកខ្ញុំប្រាប់គាត់ពីហេតុផល ដែលខ្ញុំមកកាន់ទីនេះដល់គាត់វិញដែរ។ លុះស្គាល់គ្នាជិតដិត ក្មេងម្នាក់នោះក៏បបួលខ្ញុំរត់ចេញពីគុក ពុភ្លាមខ្ញុំហាក់ ស្ទាក់ស្ទើរ ខ្ញុំសួរគាត់ថារត់ចេញទៅយ៉ាងម៉េច? គាត់ក៏ប្រាប់ខ្ញុំពីវិធីរត់ចេញ ពេលវេលា និងកន្លែងដែលត្រូវរត់ចេញ។ ខ្ញុំក៏ឆ្លើយថាមិនហ៊ានទេ ពេលពុចម្លើយខ្ញុំហើយ គាត់ថាកុំខ្លាចមិនអីទេ។ ទោះយ៉ាងណាក៏ខ្ញុំនៅតែមិនហ៊ាន ព្រោះគ្រាន់តែពុបេះដូងខ្ញុំស្ទើរលោតខុសចង្វាក់ទៅហើយ។ ខ្ញុំក៏បានប្រាប់រឿងនេះដល់បងស្រីខ្ញុំ បងខ្ញុំឃាត់មិនឲ្យខ្ញុំធ្វើតាមក្មេងនោះទេ។ យើងក៏នាំគ្នាធ្វើការធម្មតាតែអារម្មណ៍ខ្ញុំហាក់នៅនឹកគិតរឿងទាំងអស់ ដែលនឹងកើតឡើងនៅពេលខាងមុខ។

មិនយូរប៉ុន្មានពេលរាត្រីក៏ចូលមកដល់ ជាទូទៅកងយោធា តែងតែចូលមកចាក់សោរខ្នោះជើងរាល់អ្នកទោសណាដែលគេគិតថាជាអ្នកមានទោសធ្ងន់ ហើយអ្នកទោសផ្សេងទៀតរកកន្លែងសម្រាករៀងៗខ្លួន។ មិត្តខ្ញុំក៏ស្ថិតក្នុងចំណោមអ្នកទោសធ្ងន់ដែរគឺជាប់ខ្នោះជើងម្ខាង។ ខ្ញុំសួរគាត់ថា ចង់រត់ធ្វើម៉េចកើត? គាត់ក៏បង្ហាញខ្ញុំពីវិធីដកជើងចេញពីខ្នោះព្រោះខ្នោះនោះសម្រាប់ដាក់មនុស្សធំ ប៉ុន្តែគាត់ក្មេងជើងតូចអាចដកជើងចេញបាន។ បន្ទាប់មកខ្ញុំសម្លឹងមើលផ្លូវដែលគាត់បម្រុងរត់ចេញ ទីនោះមានសសរកុដិមូលមួយ ហើយក្បែរសសរនោះ ខ្មែរក្រហមបានចោះប្រហោងសម្រាប់ឲ្យអ្នកទោសបន្ទោរបង់។ ប្រហោងនោះធំល្មមអាចសម្រូតខ្លួនចុះទៅក្រោមបាន ហើយនៅខាងក្រោមមានបាំងជញ្ជាំងក្តារមួយបន្ទះពុកផុយទៅហើយ ល្មមអាចទាញចេញបាន។ យប់នេះក៏មិនខុសពីយប់សព្វមួយដងដែរ អ្នកទោសខ្លះដេកអង្គុយខ្លះដេកទាំងជាប់ខ្នោះជើង។ យូរៗម្តងយើងឮសូរសំឡេងអ្នកទោសខ្លះស្រែកថ្ងូរឈឺចាប់ ខ្លះប្រែប្រួលដេកមិនលក់ ខ្លះទៀតនិយាយខ្សឹបៗ។ យូរៗម្តងធំក្លិនផ្សែងបារីហើរមកប៉ះច្រមុះមានន័យថាគឺមានកងយោធានៅយាមក្បែរៗដូច្នេះអ្នកទោសទាំងអស់ត្រូវប្រុងប្រយត្ន័។ យប់ជ្រៅបន្តិច យើងឮសូរសំឡេងវាយធ្វើបាប អ្នកទោសនៅខាងក្រោមកុដិ។ អារម្មណ៍ភ័យខ្លាចរបស់ខ្ញុំក៏កើតឡើង តែទោះជាយ៉ាងណា ដោយសារអស់កម្លាំងផងខ្ញុំក៏លង់លក់ទៅ។ លុះយប់ជ្រៅបន្តិចនឹកគិតដល់រឿងរត់ចេញក៏ស្រាប់តែមានដៃមួយរាវមកប៉ះជើងខ្ញុំ ខ្ញុំក៏ស្ទុះងើបអង្គុយ ទើបដឹងថាជាដៃមិត្តខ្ញុំដល់ពេលវេលាដែលត្រូវរត់ចេញ។ គាត់កេះខ្ញុំម្តងហើយម្តងទៀតព្រមទាំងចង្អុលផ្លូវ

ដែលត្រូវចេញ តែខ្ញុំគ្រវីក្បាលលើកទី៣។ គាត់ក៏ដាច់ចិត្តសម្រូតចុះតាមសសរចេញចោលខ្ញុំទៅ។ យប់ងងឹតរកមើលអ្វីមិនយល់ខ្ញុំមើលតាមបង្អួចឃើញ តែពន្លឺហ្វូងផ្កាយ នឹកដល់មិត្តខ្ញុំដែលកំពុងរត់ចេញៗ ខ្ញុំខំផ្ទៀងស្តាប់សំឡេងផ្នែកខាងក្រោមក្រែងលមានអ្វីកើតឡើងចំពោះមិត្តខ្ញុំ ប៉ុន្តែមិនឮសូរសំឡេងអ្វីកើតឡើងទេ ហើយ មួយសន្ទុះក្រោយមកខ្ញុំក៏លង់លក់ក្នុងស្បែរាត្រីនោះទៅ។

## វគ្គ៧

លុះភ្លឺឡើងអ្នកទោសទាំងអស់ចេញធ្វើការតាមធម្មតា ខ្ញុំចាំមើលថាតើកងយោធាសួររកមិត្តខ្ញុំដែលរត់ចេញកាលពីយប់មិញដែរឬទេ។ ខ្ញុំធ្វើការបណ្តើរភ្នែកនិងត្រចៀកចាំស្តាប់អ្នកនៅក្បែរបណ្តើរ តែមើលទៅគ្មាននរណាម្នាក់ដឹងថាមានអ្វីកើតឡើងទេកាលពីយប់មិញ សូម្បីបងស្រីខ្ញុំក៏មិនដឹងដែរ។ កាលដែលកងយោធាចាប់យើងមកទីនេះ ថាយកយើងមកនៅមន្ទីសន្តិសុខកែរប្រែខ្លួនពីរបីថ្ងៃប៉ុណ្ណោះ។ ថ្ងៃនេះជាថ្ងៃទីបីហើយ បងខ្ញុំនិងខ្ញុំរង់ចាំមើលកងសន្តិសុខយ៉ាងអន្ទះសា។ លុះកងយោធាដើរមកជិត យើងនឹកគិតថាឲ្យយើងត្រឡប់ទៅផ្ទះវិញ ស្រាប់តែពេលមកដល់បែរជាសួររកថា មានឃើញមិត្តជាទេ? អ្នកទោសនៅក្បែរនោះឆ្លើយថាអត់ឃើញទេ រួចហើយកងយោធាក៏ត្រឡប់ទៅវិញ។ បន្ទាប់មកអ្នកទោសម្នាក់សួរបន្តមកខ្ញុំ មានឃើញមិត្តជាទេអាយុប្រហែលអូនឯង ខ្ញុំក៏ធ្វើជាមិនសូវស្គាល់ច្បាស់ ហើយឆ្លើយថាអត់ឃើញទេ។ រីឯបងស្រីខ្ញុំកាលបើអត់ទាន់ឃើញកងយោធាអត់ទាន់ឲ្យត្រឡប់ទៅផ្ទះវិញ គាត់ក៏បបួលខ្ញុំរត់ចេញពីមន្ទីសន្តិសុខ ខ្ញុំក៏នៅតែស្ទាក់ស្ទើ អារម្មណ៍ភ័យ ក៏កើតឡើងម្តងទៀតហើយភ័យខ្លាំងជាងកាលពីមិត្តខ្ញុំបបួលរត់លើកមុនទៅទៀត។ ខ្ញុំនឹកគិតគ្រប់បែបយ៉ាង ប្រសិនបើរត់មិនរួច ហើយត្រូវយោធាចាប់បានមកវិញ ឬក៏ទៅដល់ភូមិ ហើយយោធាទៅតាមចាប់ត្រឡប់មកវិញ



យើងនឹងមានទោសបន្ថែមមួយកម្រិតទៀត។

ទីបំផុតខ្ញុំក៏សម្រេចចិត្តឲ្យបងខ្ញុំរត់ចេញទៅមុន ខ្ញុំនឹងរត់ចេញតាមក្រោយ ម៉ោងប្រហែល២រសៀល បងខ្ញុំក៏លួចរត់ចេញ អារម្មណ៍ភ័យក៏កើនឡើងបន្ថែមទៀត តែទោះបីជាយ៉ាងណាក៏ខំលាក់មិនឲ្យគេដឹងដែរ។ មួយសន្ទុះអ្នកនៅធ្វើការជិត សួរថាបងអូនឯងទៅហូបទឹកយូរហើយមិនឃើញមកវិញ ខ្ញុំក៏ឆ្លើយថាមិនដឹង។ ឆ្លើយរួចខ្ញុំក៏ខំធ្វើការតាមធម្មតា ចិត្តមួយខ្លាច ចិត្តមួយចង់ទៅតាមបងដែរ។ ទីបំផុតខ្ញុំក៏សម្រេចចិត្តថា ពេលព្រលប់ និងរត់ចេញពីមន្ទីសន្តិសុខនេះដែរ។ កំពុងតែគិតរឿងរត់ចេញ ស្រាប់តែកងយោធាមួយដើរមកជិតហើយសួរថា ម៉េចមិត្តអូនធ្វើការនៅទីនេះ? ខ្ញុំធ្វើទឹកមុខញញឹមៗហើយឆ្លើយថាអត់អីទេ។ យោធាសួរបន្តថា បងមិត្តឯងទៅណា? ខ្ញុំឆ្លើយថាអត់ដឹងប្រហែលគាត់ទៅហូបទឹកនៅឯនោះ ហើយដៃខ្ញុំចេះតែចង្អុលទៅ។ បន្ទាប់មកកងយោធាបន្តថា មិត្តឯងហៅបងមិត្តឯងមក តាមខ្ញុំទៅជួបបងមេកង ភ័យរកអ្វីផ្ទឹមពុំបាននឹកក្នុងចិត្ត បងរត់មុននេះបន្តិចគេចាប់បានទេដឹង ឬក៏គេសួរនាំរឿងអ្វីផ្សេង ឬក៏ឲ្យទៅផ្ទះវិញព្រោះដល់ថ្ងៃកំណត់បីថ្ងៃហើយ។ ខ្ញុំគិតដល់ចំណុចនេះក្នុងចិត្តធូរស្រាលបន្តិច ប៉ុន្តែយ៉ាងណាភ័យច្រើនជាងអរ។ ពេលទៅដល់មិនហ៊ានមើលមុខមេកងត្រង់ៗទេ ឃើញទឹកមុខមេកងយោធាញញឹមក្នុងចិត្តរៀងធូរបន្តិច។ គាត់សួរថា យ៉ាងម៉េចដែរប៉ុន្មានថ្ងៃនេះ? ខ្ញុំឆ្លើយដូចមុនអត់អីទេ។ យោធានោះបន្តថា មើលហៅបង មិត្តឯងត្រឡប់ទៅផ្ទះវិញ។ គ្រាន់តែឮប្រយោគនេះក្នុងចិត្តខ្ញុំត្រេកអររកអ្វីផ្ទឹមពុំបាន។ យោធានោះបន្ថែមថា មិត្តឯងស្គាល់ផ្លូវទៅផ្ទះទេ? ខ្ញុំបានឆ្លើយថាបាទស្គាល់ ខ្ញុំឆ្លើយយ៉ាងរហ័ស។ មេកងយោធានិយាយបន្តទៀតថា មើលទៅដល់ភូមិខំធ្វើការកុំគេចវេះទៀត។ ខ្ញុំឆ្លើយបាទ រួចហើយខ្ញុំឱនក្បាលចុះពីរដងក្នុងន័យគោរពលា ហើយគេចចេញយ៉ាងរហ័សខ្លាចយោធានោះសួរដេញដោលរកបងស្រីខ្ញុំនាំតែពិបាកដោះស្រាយ។ ខ្ញុំដើរមកដល់កន្លែងធ្វើការវិញ ខ្ញុំជម្រាបលាអ្នកទោសក្មេងចាស់ទាំងអស់ដោយប្រាប់ថា មេកងយោធាឲ្យខ្ញុំទៅផ្ទះវិញហើយ។ អ្នកខ្លះជួយអរខ្ញុំ អ្នកខ្លះទឹកមុខក្រៀមក្រំ រួចហើយខ្ញុំដើរចេញមកដោយបន្សល់ទុកនូវការនឹករឭកដល់អ្នកទោសទាំងអស់នេះ ថាតើថ្ងៃណាទើបអ្នកទាំងអស់បានចេញពីទីនេះដូចខ្ញុំដែរ។

ខ្ញុំដើរបណ្ដើរនឹកគិតចង់បញ្ជូនដំណឹងនេះទៅដល់បងស្រីខ្ញុំដែលលួចរត់ចេញទៅមុនឲ្យបានរហ័សដើម្បីកុំឲ្យគាត់ភ័យខ្លាំង។ មិនបង្អង់យូរ ខ្ញុំដើរផងរត់ផង គាត់វាលស្រែពោរពេញដោយទឹកនារដូវវស្សា។ ខ្ញុំមានអារម្មណ៍សប្បាយ ដើរបណ្ដើរផ្លូតទឹកតាមភ្លឺស្រែបណ្ដើរ ទទឹកខ្លួនដោកគិតយ៉ាងណាទៅឲ្យដល់ភូមិមុនថ្ងៃលិច។ និយាយអំពីបងស្រីខ្ញុំវិញ កាលបើគាត់រត់មកដល់ភូមិមុន គាត់មិនទាន់ហ៊ានទៅកងកុមារវិញទេ។ គាត់ចូលទៅកន្លែងកង បន្ទៃដែលមានម្ដាយមីងខ្ញុំនៅទីនោះ រីឯម្ដាយមីងខ្ញុំក៏មិនដឹងថា ក្មួយស្រីគាត់ទើបរត់ចេញពីមន្ទីសន្តិសុខដែរ ព្រោះអីបងស្រីខ្ញុំភ័យពេកមិនបានប្រាប់ការពិតដល់គាត់។ នៅពេលដែលខ្ញុំទៅដល់ទើបម្ដាយមីងខ្ញុំដឹងរឿងពិតថា ក្មួយប្រុសស្រីគាត់ ត្រូវបានយោធាចាប់យកទៅមន្ទីសន្តិសុខ រីឯបងស្រីខ្ញុំហាក់មិនចង់ជឿខ្ញុំថា កងសន្តិសុខដោះលែងតាមធម្មតា។ គាត់សួរខ្ញុំហើយសួរទៀតខ្ញុំថា បងកុំភ័យយោធាដោះលេងយើងឲ្យមកភូមិវិញហើយ។ ម្ដាយមីងខ្ញុំកាលបើដឹងរឿងក្មួយទាំងពីរហើយទើបគាត់ភ័យជាក្រោយ រួចហើយខ្ញុំក៏ចុះផ្លូតទឹករាវគ្រុំ និងខ្ទៅជាមួយម្ដាយមីងខ្ញុំក្នុងស្ទឹងក្បែរនោះមកហូបចម្អែតក្រពះ។ លុះព្រលប់ទើបម្ដាយខ្ញុំមកជួប នាំយកបងប្អូនយើងទាំងពីរត្រឡប់ទៅចូលកងកុមារវិញ។

## វគ្គ៨

នៅពេលដែលខ្ញុំ និងបងស្រីត្រឡប់មកពីមន្ទីសន្តិសុខវិញម្ដាយខ្ញុំបានទៅជួបមេកងកុមារសុំឲ្យបងប្អូនយើងទាំងពីបានចូលទៅកងកុមារវិញ។ យើងក៏បានធ្វើការតាមធម្មតាម្នាក់ៗហាក់មិនដឹងថារយៈពេលបីបួនថ្ងៃកន្លងមកនេះ ខ្ញុំបានធ្វើអ្វីនៅឯណាទេព្រោះអីក្នុងកងកុមារនេះមានកុមារជាងពី៥០ទៅ៦០នាក់ ដូច្នេះយើងមិនអាចស្គាល់គ្នាអស់ទេ។ មិនយូរ

ប៉ុន្មានរដូវវស្សាកន្លងផុតទៅ រដូវប្រាំង ស្រូវទុំក៏ឈានចូលមកដល់ៗ ភាពអត់ឃ្លានលំបាកតោកយ៉ាកនារដូវវស្សាក៏បានថយចុះ ព្រោះយើងលែងទទួលទានបបររាវលាយគល់ចេក គល់ល្ហុង មកហូបបបរសុទ្ធខាប់ និងឈានទៅរកបាយបណ្តើរៗ ហើយពេលខ្លះយើងលួចសួរគ្នាឯងថាថ្ងៃនេះបបរឬក៏បាយទៀត។

នៅចុងឆ្នាំ១៩៧៨ កងចល័តយុវវ័យចេញចាក់ឆ្ងាយពីភូមិអស់ នៅសល់តែមនុស្សចាស់ និងកុមារៗ អង្គការក៏បានប្តូរក្រុមយើងខ្ញុំពីកងកុមារ ទៅជាកងចល័តកុមារ ហើយម្តងនេះយើងបានចេញពីភូមិទៅច្រូតស្រូវរហូតដល់វាលព្រៃនាមក្បែរទន្លេសាបៗ ទីនោះហើយដែលយើងបានស្គាល់ (ស្រូវវារ ស្រូវប្រាំង ស្រូវវស្សា)។ មិនយូរប៉ុន្មានសភាពការណ៍ក៏ហាក់ចាប់ផ្តើមប្រែប្រួលពីតឹងតែងការងារ មកធូរស្រាលបន្តិចម្តងៗ មិនរឹតត្បិត ដូចកាលមុនៗ យើងធ្វើការបណ្តើរត្រចៀកប្រឹងស្តាប់ យើងឮសូរសំលេងគ្រឹមៗ ហាក់ដូចជាផ្គរលាន់បន្តិចកាំភ្លើងធំបន្តិចលាន់ឮល្វើយៗ ម្តងខ្លាំងម្តងខ្សោយៗ ម្នាក់ៗខ្សឹបខ្សៀវគ្នាថានឹងមានកងទ័ពរំដោះ ឬខ្មែរសេរី (ខ្ញុំនៅក្មេង ពាក្យទាំងនេះមិនសូវយល់ទេ ដូចម្តេចដែលហៅថាកងទ័ពរំដោះ ឬខ្មែរសេរី គឺខ្ញុំស្តាប់ចងចាំក្នុងចិត្ត)។

រយៈពេលជាង១សប្តាហ៍មកហើយ ដែលកុមារទាំងអស់ចេញមកធ្វើការដោយគ្មានមេកងចេញមកចាត់ចែងការងារៗ ដូច្នេះអ្នកខ្លះធ្វើការ អ្នកខ្លះអង្គុយតាមចិត្ត ព្រោះបាត់មេកងដឹកនាំទាំងអស់ រីឯស្នូរកាំភ្លើងធំឮកាន់តែជិតឡើងៗ។ ទីបំផុតកុមារទាំងអស់គ្នាក៏សម្រេចចិត្តបំបែកគ្នាត្រឡប់មកភូមិរកឪពុកម្តាយរៀងៗខ្លួនវិញ។ មកដល់ភូមិឪពុកខ្ញុំប្រាប់ថាខ្មែរក្រហមឲ្យដឹកត្រង់សេ ប៉ុន្តែមិនបានបីថ្ងៃផង ព្រឹកព្រលឹមស្រាងៗឡើងយើងឮសូរគ្រាប់កាំភ្លើងតូចធំខ្លាំងៗលន់ពេញភូមិ។ ម្នាក់ៗភ័យខ្លាំងណាស់ យើងនាំគ្នារត់ចុះរកទីសុវត្ថិភាព។ ស្នូរកាំភ្លើងស្ងប់បន្តិច ឪពុកខ្ញុំនិងចាស់ៗក្បែរផ្ទះនាំគ្នាលូនចេញទៅមើលសភាពការណ៍ក្រៅភូមិ។ ពេលមកវិញឪពុកខ្ញុំប្រាប់ថា មានកងរំដោះ តែសុទ្ធតែជាកងទ័ពយួនពាក់មួកដួនៗ បន្តិចក្រោមមកទើបយើងឃើញមានកងទ័ពខ្មែរពីរបីនាក់មកជាមួយ ប្រាប់ឲ្យប្រជាជនទាំងអ្នកមូលដ្ឋានចាស់ ថ្មីទាំងអស់ឲ្យចាក់ចេញពីភូមិ និងគេចចេញពីតំបន់គ្រោះថ្នាក់ ហើយធ្វើដំណើរទៅខេត្តពោធិសាត់ៗ ថ្ងៃនោះយើងមិនអាចធ្វើដំណើរដល់ខេត្តតាមបញ្ជាកងទ័ពរំដោះបានទេ យើងបានទៅដល់ត្រឹមតែទីរួមស្រុកកណ្តៀងតែប៉ុណ្ណោះ ហើយស្នាក់នៅទីនោះមួយរយៈ ទើបបន្តដំណើរទៅខេត្តពោធិសាត់ៗ

**ទុយ វណ្ណារ័ត្ន**

# មជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលឯកសារ ឡោះ កូសែម

ខ្ញុំបាទ ឆាំង យុ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកស្រី ណាទីយ៉ា ដែលបានប្រគល់ឲ្យខ្ញុំបាទនូវឯកសារដ៏ច្រើនសន្ធឹកសន្ធាប់របស់ឧត្តមសេនីយ៍ ឡោះ កូសែម។ ឯកសារទាំងនេះមានតម្លៃជាប្រវត្តិសាស្ត្រ ក៏ដូចជាជីវិតរបស់ឧត្តមសេនីយ៍ ឡោះ កូសែម ដែលមិនអាចកាត់ថ្លៃបានឡើយ។

ឯកសារទាំងនេះ រួមទាំងឯកសារយ៉ាងហោចណាស់ជាង១លាន២សែន ដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានសារសំខាន់ដល់សិស្សានុសិស្ស អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាដែលនៅតែមានជីវិតនាពេលបច្ចុប្បន្ន ហើយក៏នឹងរួមដំណើរជាមួយប្រជាជនកម្ពុជាទាំងអស់ ក្នុងការថែរក្សាសន្តិភាព និងការអភិវឌ្ឍន៍ប្រទេសទៅក្នុងថ្ងៃអនាគត។

**ឆាំង យុ**

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

កង គីម មានអាយុ២៧ឆ្នាំគិតត្រឹមឆ្នាំ១៩៧៥ ជាអតីតទាហានពលទោ មានស្រុកកំណើត នៅស្រុកដង្កោ ខេត្តកណ្ដាល ជាកូនរបស់ពូ ដួន គង់ និងមីង ឡាញ់ ខាត់ មានប្រពន្ធឈ្មោះ ចិន សាវឿន។ តាមឯកសារបង្ហាញថា ខ្មែរក្រហមចាប់ខ្លួន គីម នៅស្រុក១៥៤ នៅថ្ងៃទី១៩ ខែ.... ឆ្នាំ១៩៧៧។ គីម ជាប់គុកទួលស្លែងក្នុងផ្ទះ ក០៧ បន្ទប់ធំ ១០។ ពុំមានឯកសារបង្ហាញពីខែចាប់ខ្លួនទេ។

កង ឆន ហៅ សេន ហៅ ស៊ីន ជាសហករណ៍ ឃុំក្នុងស្រុក៥១ តំបន់៣៣។ មានប្រភពឯកសារផ្សេងគ្នាបង្ហាញថា កង ឆន ត្រូវបានខ្មែរក្រហមបញ្ជូនពីតំបន់៣៣ ភូមិភាគបស្ចិម ហើយចូលដល់គុកទួលស្លែងនៅថ្ងៃទី៦ ឬ៧ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ កង ឆន នៅ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។ កង ឆន ជាប់គុកទួលស្លែង អស់រយៈពេល ១៦២ ឬ១៦៣ ថ្ងៃ។

កង ប៉ាង ហៅ សារ៉េន ឬ សារ៉េត ជាកងទ័ពនៅក្នុងកងពល១៧០ (ចាស់) និងកងពល ៥០២ (ថ្មី) ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅកងពល៥០២ និងបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃ ១៧ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមដាក់គុក កង ប៉ាង ១៩ថ្ងៃ ទើបយកទៅសម្លាប់នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ ដដែល។

កងប៉ាត់ជាកម្មករចាស់ធ្វើការនៅរថភ្លើង។ ខ្មែរក្រហមចាប់ខ្លួន កង ប៉ាត់ នៅកន្លែងរថភ្លើង រួចបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី២២ ឬ២៨ ខែកញ្ញា ឆ្នាំ១៩៧៦ (ព្រោះមានឯកសារបង្ហាញខុសគ្នា អំពីថ្ងៃមកដល់គុកទួលស្លែង)។ ខ្មែរក្រហមសម្លាប់ កង ប៉ាត់ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំដដែល បន្ទាប់ពីជាប់គុកទួលស្លែងបាន ៥៨ថ្ងៃ ឬ៦០ថ្ងៃ។

កង ប៉ូច មានអាយុ២៦ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបន្ទាយមាស ខេត្តកំពត ជាកូនរបស់ពូ កង ប៉ាត់ និងមីង ខាន់ មិញ មានប្រពន្ធឈ្មោះ ទុំ ង៉ាន់ មានកូនប្រុស ១ និងកូនស្រី៣នាក់។ ខ្មែរក្រហមចាប់ខ្លួនថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៧៦ ក្រោយពីចាប់ខ្លួនឪពុក កង ប៉ាត់ បានប្រហែល ១ខែ។ ខ្មែរក្រហមបញ្ជូន កង ប៉ូចមកដល់គុកទួលស្លែងនៅថ្ងៃបន្ទាប់។ កង ប៉ូច ជាប់គុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ១ បន្ទប់តូច ១០ បាន ៩៨ថ្ងៃ ទើបខ្មែរក្រហមយកទៅសម្លាប់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។

កង លាប ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦ នៅកងពល១៧០ ហើយបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃដដែល។ ខ្មែរក្រហមសម្លាប់ កង លាប នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់គុកទួលស្លែងអស់រយៈពេល ៨០ថ្ងៃ។

កង លឿម ហៅ ម៉ៅ មានអាយុ៣១ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុកជីក្រែង ខេត្តសៀមរាប ជាកូនរបស់ពូ នឹង និងមីង ប៉ុល មានប្រពន្ធឈ្មោះ រុំ ជាអ្នកនៅស្រុក ជីក្រែងជាមួយគ្នា។ កង លឿម ជាយុទ្ធជន នៅអង្គភា៣៨៥១ កងពល១៤ នៅមុនថ្ងៃ១៧ មេសា និង ជាអនុនយោបាយកងធំ ក្នុងអង្គភា៣១៨០ ក្នុងអំឡុងនៃរបបខ្មែរក្រហម។ ខ្មែរក្រហមចាប់ខ្លួន កង លឿម នៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៧៦ នៅស្រុកជីក្រែង (ឯកសារផ្សេងបង្ហាញពីការចាប់ខ្លួនមកពីក្រសួងការបរទេស)។ ពុំមានឯកសារបង្ហាញពីកាលបរិច្ឆេទនៃការសម្លាប់ឡើយ ក៏ប៉ុន្តែមានឯកសារបង្ហាញថា កង លឿម ជាប់គុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ៥ តូច២។

កង សាវឿន ជាប្រពន្ធរបស់ យស់ សាវឿន ត្រូវបាន

ខ្មែរក្រហមឃាត់ខ្លួននៅកន្លែងរទេះភ្លើង ថ្ងៃទី២៩ ខែតុលា ឆ្នាំ ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃបន្ទាប់ គឺថ្ងៃទី៣០។ កូនរបស់ យស់ សារឿន ឈ្មោះ កង ណូ ជាមួយនឹងឪពុកត្រូវបានខ្មែរក្រហមចាប់ខ្លួនព្រមគ្នាជាមួយម្តាយ និងប្រពន្ធ នៅកន្លែងរទេះភ្លើងដូចគ្នា ក៏ប៉ុន្តែសម្លាប់កូននៅថ្ងៃទី២៨ខែមករា ឆ្នាំ១៩៧៧ ក្រោយម្តាយ ៦០ថ្ងៃ។ ឯឪពុកវិញ គឺពុំទាន់មានឯកសារបង្ហាញពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

កង សុខុន ហៅ ឡា អាយុ២២ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកងមាស ខេត្តកំពង់ចាម ជាកូនរបស់ពូ កង ឈឺន និងមីង ជ្រៀញ ផន។ ខ្មែរក្រហមចាប់ខ្លួន កង សុខុន នៅយ២១ នៅថ្ងៃទី២៨ ខែមករាឆ្នាំ១៩៧៧ មកដាក់គុកទួលស្លែងផ្ទះ ង បន្ទប់ធំ ៥ តូច ៩។

កង់ ចាន់នី ជាកូនរបស់កម្មកររទេះភ្លើង ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅកន្លែងរទេះ ភ្លើងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៦។

ការ បូនី អាយុ៣៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៥ ស្រុកកំណើតនៅខេត្តព្រៃវែង ជាកូនរបស់ពូ ការ ឆោម និងមីង ឡុង យ៉ុន មានប្រពន្ធឈ្មោះ នាង សាវ៉ាន់ ហៅ ញ៉ ជាអ្នកស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានកូនប្រុសម្នាក់ និងស្រីម្នាក់។ ខ្មែរក្រហមចោទ ការ បូនី ថាជាទាហ៊ានសក្តិ៥ និងចាប់ឃាត់ខ្លួនគាត់នៅភូមិខ្នា ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅមន្ទីរស២១ (គ) និងបញ្ជូនបន្តទៅដល់គុកទួល ស្លែង នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ នៅគុកទួលស្លែង ការ បូនី ត្រូវបានខ្មែរក្រហមដាក់ឃុំក្នុងផ្ទះ ក បន្ទប់ធំ៦ បន្ទប់តូច៣។ ពុំទាន់មានឯកសារបង្ហាញពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

កាន់ គឹមស្រេង ហៅ ពក មានអាយុ២៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្ទួង ខេត្តកំពង់ចាម ជាកូនរបស់ពូ កាន់ គឹម ផ្លូន និងមីង ហៅ គឹម យេង មានប្រពន្ធឈ្មោះ គ្រី វណ្ណា ហៅ មុំ អ្នកភ្នំពេញ។ ខ្មែរក្រហមចោទកាន់ គឹមស្រេង ថាជាទាហ៊ានសក្តិ៣ ហើយចាប់ឃាត់ខ្លួននៅភ្នំស្រុក ខេត្តបាត់ដំបង ថ្ងៃទី១២ ខែមករា ឆ្នាំ ១៩៧៦។ កាន់ គឹមស្រេង ត្រូវបានខ្មែរក្រហមបញ្ជូលមកដល់គុកទួលស្លែងនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយ ដាក់ឃុំក្នុងផ្ទះ ក១ បន្ទប់ធំ ៧។ បន្ទាប់ពីជាប់គុកទួលស្លែងបាន ៩៣ថ្ងៃ ខ្មែរក្រហមសម្លាប់ កាន់ គឹមស្រេង នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦។

កាន់ លាន មានអាយុ២៣ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅមេមត់ ខេត្តកំពង់ចាម ជាយុទ្ធជន ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួននៅព្រៃសរ ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៦ ហើយបញ្ជូនមកដាក់នៅគុកទួលស្លែងក្នុងផ្ទះ ក៥ បន្ទប់ធំ ៣។

កាន់ សុខា ឬ កាន់ សុផា ហៅ ជ្រូក មានអាយុ១៩ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក២០ តំបន់២៥ (កោះធំខេត្តកណ្តាល) ជាកូនរបស់ពូ ម៉ៅ គ្រាន់ និងមីង ឈឹម សាត ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួននៅរោងចក្រអិដ្ឋ អ.៣ ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៧។ ពុំទាន់មានឯកសារបង្ហាញពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ការ ឬ ស្រីតការ ហៅ សឹង ជនជាតិសៀម ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួននៅ កំពង់សោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ ហើយសម្លាប់នៅថ្ងៃទី២៤ ខែឆ្នាំដដែល។ ការ ជាប់នៅ គុកទួលស្លែងអស់រយៈពេល ១៧ថ្ងៃ។

កាំ ដាន់យ៉ា ហៅ ដាំ មានអាយុ៣៩ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅទ្រាំង ខេត្តតាកែវ ជាកូនរបស់អ៊ំ កាំ ខុំ និងអ៊ំស្រី ចាន់ គឹមយ៉ន ជាសមាជិករណៈសិរ្សរួបរួមជាតិ) ប៉េកាំង មានប្រពន្ធឈ្មោះ ហែម ប៊ុនណារ៉េត ហៅ ម៉ុន មានកូនស្រីម្នាក់។ កាំ ដាន់យ៉ា និងប្រពន្ធ ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅទីក្រុងភ្នំពេញ ថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៧ ហើយនៅថ្ងៃដដែល ប្តីប្រពន្ធមួយគូនេះ ត្រូវបានខ្មែរក្រហមបញ្ជូនមកដល់គុកទួលស្លែង។ ឯកសារបង្ហាញថា កាំ ដាន់យ៉ា ត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់គុកទួលស្លែង នៅក្នុងផ្ទះ យ បន្ទប់ធំ ២ តូច ១០ អស់រយៈពេល ១៣០ ថ្ងៃ។

កាំង ហ៊ែល មានអាយុ២៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រះស្តេច ខេត្តព្រៃវែង ជាកូនរបស់ពូ លេង

កាំង និងមីង គង់ ឈន មាននាទី អនុស្នងការនយោបាយវរ-សេនាតូច៧៣២។ កាំង ហ៊ែល ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅច្បារអំពៅ ថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧៦។ យោងឯកសារផ្សេងៗបង្ហាញថា កាំង ហ៊ែល ត្រូវបានខ្មែរក្រហមបញ្ជូនមក ដល់គុកទួលស្លែងនៅថ្ងៃទី១៩ ឬ២៣ ហើយត្រូវបានសម្លាប់នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់គុកទួលស្លែងក្នុងផ្ទះ ០៤ បន្ទប់ធំ ៥ អស់រយៈពេល៨៤ថ្ងៃ។

កិច ហួយ ត្រូវជាប្រពន្ធរបស់កម្មកររោងចក្រតម្បាញ ជាម្តាយរបស់ សុខ ឃឹម ដែលមានប្រពន្ធឈ្មោះ ទ្រី មួយ។ អ្នកទាំងបីត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅរោងចក្រតម្បាញ ត១០ ក្នុងឆ្នាំ១៩៧៦ និងបញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី៤ ខែតុលា ទាំងអស់គ្នា។ ខ្មែរក្រហមសម្លាប់ម្តាយមុន នៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៦ គឺមួយថ្ងៃបន្ទាប់ពីចាប់ឃាត់ខ្លួន។ ចំពោះកូនប្រុសឈ្មោះ សុខ ឃឹម ត្រូវបានខ្មែរក្រហមសម្លាប់ក្រោយគេគឺនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់គុកទួលស្លែងអស់រយៈពេល ៦៣ថ្ងៃ។ ចំណែកឯកូនប្រសារស្រី ត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៧៦ គឺ ៤ ថ្ងៃបន្ទាប់ពីម្តាយក្មេក។

កិម សុផានី ហៅ យន មានអាយុ៣៩ឆ្នាំគិតត្រឹមឆ្នាំ ១៩៧៥ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាកូនរបស់ពូ កិម វិន និងមីង នូ ឆឹម ជាកម្មកររោងចក្រកៅស៊ូកង់ឡាន ក១ មានប្រពន្ធឈ្មោះ អ៊ុំ សាម៉ុន អ្នកស្រុកកៀនស្វាយ ខេត្តកណ្តាល មានកូនប្រុស ១ កូនស្រី ២នាក់។ កិម សុផានី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រកៅស៊ូកង់ឡាន ក១ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនមកដាក់គុកទួលស្លែងក្នុងផ្ទះ ក០៨ បន្ទប់ធំ ៤។ ក្រោយជាប់គុកទួលស្លែងបាន ១៥៩ថ្ងៃ ខ្មែរក្រហមសម្លាប់ កិម សុផានី នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦។

កិម ឪ ហុក ហៅ អាង៉ូវ មានអាយុ៣១ឆ្នាំគិតត្រឹមឆ្នាំ ១៩៧៦ មានស្រុកកំណើតនៅហុងកុង ជាកូនរបស់លោក កិម យិវ និងលោកស្រី វង់ ស៊ី មានប្រពន្ធឈ្មោះ ឃីក វ៉ា ហៅ វ៉ាន់ ឌី ជាអ្នកភ្នំពេញ មានកូនប្រុស ១ នាក់។ អាង៉ូវ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រជួសជុល ផ្សារកណ្តាល ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយបញ្ជូនមកដាក់គុកនៅគុកទួលស្លែងក្នុងផ្ទះ ០៦ បន្ទប់ធំ ១៨។

កុក ដាន់ មានអាយុ២៤ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក ៥៦ តំបន់ ៣៣ (ស្រុកបាទី ខេត្តតាកែវ) ជាកូនរបស់ពូ ប៉ៅ កុក និងមីង សាយ ជុំ ជាយុទ្ធជននៅ ភូមិភាគពិសេស ក្រោយមកកងពល ៥០២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ៥០២ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។

កុក លន មានអាយុ៣០ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក២០ (ស្អាង) ខេត្តកណ្តាល ជា កូនរបស់ពូ បាំង កុក និងមីង គង់ ឆាយ ជាអ្នកស្រែក្នុងសហករណ៍ មានប្រពន្ធឈ្មោះ ម៉ៅ ណយ លែងគ្នា។ កុក លន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុក១៦ ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៦។ មានឯកសារផ្សេងៗបង្ហាញពីថ្ងៃចាប់ខ្លួនផ្សេងគ្នាបីទៀត គឺ ថ្ងៃទី១៣, ២០, ២២ ខែមីនា ឆ្នាំ១៩៧៦។ ដូចគ្នានឹងថ្ងៃចាប់ខ្លួនដែរ ថ្ងៃសម្លាប់ កុក លន ត្រូវបានបង្ហាញ ដោយឯកសារផ្សេងៗ គឺនៅថ្ងៃទី២៣, ២៧ ខែឧសភា ឆ្នាំ១៩៧៦។

កុក សារឹម មានអាយុ២៣ឆ្នាំ គិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃវែង ខេត្តព្រៃវែង ជាកូនរបស់ពូ កុក សាឿន និងមីង ដាន់ ណាន់ មាននាទីជាយុទ្ធជន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកកៀនស្វាយ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ ១៩៧៦ ហើយបញ្ជូនមកដាក់គុកនៅគុកទួលស្លែង ក្នុងផ្ទះ ១០ បន្ទប់ធំ ១។

កុង ណេន មាននាទីជាស្នងការកងហានៃកងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ឃាត់ខ្លួន នៅកងពល៥០២ ក្នុងឆ្នាំ ១៩៧៦។

កុយ ប៉ុក ហៅ ប៊ិន មានអាយុ៣២ឆ្នាំ គិតត្រឹមឆ្នាំ ១៩៧៦ ជាអតីតទាហានយន្តហោះ ស័ក្ត១ មានស្រុកកំណើត នៅកៀនស្វាយ ខេត្តកណ្តាល ជាកូនរបស់ពូ កុយ អឹម និងមីង ឃ្លោក ស៊ិន មានប្រពន្ធឈ្មោះ អួង ប៉ារី ជាអ្នកស្រុកកៀនស្វាយ មានកូនប្រុស ២នាក់ និងកូនស្រី១នាក់។ កុយ ប៉ុក នៅធ្វើស្រែត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព្រះនេត្រព្រះ បាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦។ ឯកសារខ្មែរក្រហមបង្ហាញថា កុយ ប៉ុក ត្រូវបានបញ្ជូនទៅដល់មន្ទីរស-២១ គ មុននឹងខ្មែរក្រហមសម្លាប់គាត់នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៦។

កុយ ស៊ិន ហៅ រុន មានអាយុ២៥ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅមោង ខេត្តបាត់ដំបង ជាកូនរបស់ពូ កុយ មុល និងមីង សាន់ ជាអ្នកទទួលខុសត្រូវរោងចក្រ ប១ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦ នៅរោងចក្រ ប១ ហើយបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃបន្ទាប់។ ខ្មែរក្រហមសម្លាប់ កុយ ស៊ិន នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។ កុយ ស៊ិន រស់បាន ១៥០ថ្ងៃ នៅក្នុងគុកទួលស្លែង។

កូង ប៉ូច ជាកម្មករនៅរទេះបំណាន់ ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅទីនោះ ថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៧៦។

កូវ ផល្លា មានអាយុ២០ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រែកប្រសប់ ខេត្តក្រចេះ ជាកូនរបស់ពូ កូវ ស្រ៊ុន និងមីង ឈឹម ភុំ ជាយុទ្ធជនកងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅគុមិក្តុល ដងទង់ ជាយក្រុងភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៦ ហើយបញ្ជូនដល់គុកទួលស្លែងនៅថ្ងៃទី៤ ខែធ្នូ ក្នុងផ្ទះ ឆ បន្ទប់ធំ៣ បន្ទប់តូច១៣។ កូវ ផល្លា ត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ ១៩៧៧ បន្ទាប់ពីរស់បាន ៥៨ថ្ងៃនៅក្នុងគុកទួលស្លែង។

កួយ យ៉ត មានអាយុ២២ឆ្នាំ ស្រុកកំណើតនៅស្រុក ២០ (ស្អាង) ខេត្តកណ្តាល ជាកូនរបស់ពូ កួយ ទួយ និងមីងមួយ មុនឆ្នាំ១៩៧៥ ជាយុទ្ធជនកងពល៧០៣ និងក្រោយមកជាយុទ្ធជនស-២១យ ត្រូវបានខ្មែរចាប់ខ្លួននៅស-២១យ។

កើត រ៉ែម ហៅ ម៉ុម មានអាយុ៤១ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសណ្តាន់ ខេត្តកំពង់ធំ ជាកូនរបស់ពូ កើត អោម និងមីង កែវ ចាន់ ជាប្រធានពាណិជ្ជកម្មតំបន់៤៣ មានប្រពន្ធឈ្មោះ ស្វាយ ឡេង មានកូនប្រុស ៤នាក់ និងកូនស្រី ២នាក់ ត្រូវបានខ្មែរក្រហម ឃាត់ខ្លួននៅស្រុកសន្ទុក ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនដល់គុកទួលស្លែង នៅថ្ងៃទី៩ ខែវិច្ឆិកា។ កើត រ៉ែម ត្រូវបានខ្មែរក្រហមសម្លាប់ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់នៅគុកទួលស្លែងអស់រយៈពេល ១៨៥ថ្ងៃ។

កៀត ដារា ជាកូនស្រីរបស់កម្មករចាស់ ត្រូវបានខ្មែរក្រហម ឃាត់ខ្លួននៅរោងចក្រអគ្គីសនី ផ្សារតូចក្នុងឆ្នាំ ១៩៧៦ ហើយបញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃបន្ទាប់។

កៀត ថាវ ហៅ ចាត់ មានអាយុ៣៩ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រែកប្រសប់ ខេត្តក្រចេះ ជាកូនរបស់ពូ កៀត ច្រិល និងមីង ញ៉ឹក ប៊ី ជាយុទ្ធជនក្នុងកងពល៣១០ មានប្រពន្ធឈ្មោះ សៅ ហេង នៅកងពល៣១០ជាមួយគ្នា មានកូនស្រី១នាក់។ កៀត ថាវ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ ១៩៧៧។

***វ៉ាន់ថាន់ ពៅដារ៉ា***

***មជ្ឈមណ្ឌលឯកសារកម្ពុជា***




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 221, May 2018 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 0291 P.M/99, 2 August 1999.